Federal Office for Economic Affairs and Export Control

Partners in Transformation
Helpdesk Business and Human Rights

# គោលការណ៍ណែនាំ

## កិច្ចសហប្រតិបត្តិការក្នុងខ្សែចង្វាក់ផ្គត់ផ្គង់រវាងសហគ្រាសជាប់កាតព្វកិច្ច និងអ្នកផ្គត់ផ្គង់




កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Implemented by: giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

IGS INITIATIVE FOR GLOBAL SOLIDARITY

RESPONSIBLE BUSINESS HUB CAMBODIA
RBH NETWORK

EUROCHAM CAMBODIA

**បោះពុម្ពដោយ**
Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH
ការិយាល័យ GIZ ភ្នំពេញ
អគារការិយាល័យ Oval Office ជាន់ទី 10 អគារលេខ 1 ផ្លូវ 360 សង្កាត់បឹងកេងកង 1
ប្រអប់ P.O. លេខ 81 លេខកូដតំបន់ 120102 រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ៖ +855 23 860 110
អ៊ីមែល៖ giz-kambodscha@giz.de
គេហទំព័រ៖ www.giz.de/cambodia

**គម្រោង៖**
FABRIC Cambodia

**អ្នកនិពន្ធ៖**

នេះគឺជាឯកសារសម្រួលជាខេមរភាសា នៃគោលការណ៍ណែនាំស្ដីពី «កិច្ចសហប្រតិបត្តិការក្នុងខ្សែចង្វាក់ផ្គត់ផ្គង់រវាងសហគ្រាសជាប់កាតព្វកិច្ច និងអ្នកផ្គត់ផ្គង់» ដែលបានបោះពុម្ពដោយ ការិយាល័យសហព័ន្ធសម្រាប់កិច្ចការសេដ្ឋកិច្ច និងការត្រួតពិនិត្យការនាំចេញ (BAFA) និងកម្មវិធីជំនួយគាំទ្រ លើធុរកិច្ច និងសិទ្ធិមនុស្ស។ ឯកសារបកប្រែជាភាសាខ្មែរនេះ ត្រូវបានប្រែសម្រួលដោយ មជ្ឈមណ្ឌលធុរកិច្ចប្រកបដោយទំនួលខុសត្រូវនៅកម្ពុជា (Responsible Business Hub Cambodia)។

**រចនាដោយ៖**
Tinkerbelle GmbH, Berlin

**រូបភាពប្រើប្រាស់៖**
រូបភាពគម្របដោយ៖ Marta Shershen/iStock

**ឯកសារយោង (URL)៖**
ទំនួលខុសត្រូវលើខ្លឹមសារព័ត៌មាននៃគេហទំព័រតាមតំណដែលឯកសារយោងត្រូវបានធ្វើឡើង ស្ថិតលើអ្នកផ្ដល់ព័ត៌មាននីមួយៗទាំងស្រុង។ GIZ ពុំមានការទទួលខុសត្រូវណាមួយលើខ្លឹមសារនេះឡើយ។

**តំណាងឲ្យ**
ក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ)
Division 120 - Sustainable Supply Chains
Reinhard Junker, Berlin

រាជធានីភ្នំពេញ 2024

# តារាងមាតិកា

សេចក្ដីសង្ខេប ....................................................................................................3
I. សេចក្ដីផ្ដើម ....................................................................................................3
II. កំណត់សម្គាល់ទូទៅ ....................................................................................................3
III. លម្អិតពាក់ព័ន្ធនឹងការត្រួតពិនិត្យភាពត្រឹមត្រូវ....................................................................................................4
IV. អនុសាសន៍សម្រាប់កិច្ចសហការនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ ....................................................................................................6

គោលការណ៍ណែនាំស្ដីពីកិច្ចសហការនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់....................................................................................................10
I. កាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវរបស់ក្រុមហ៊ុន និងច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ ...........10
II. ឥទ្ធិពលនៃច្បាប់ស្ដីពីសហគ្រាសមិនជាប់កាតព្វកិច្ច.................................................................................... 11
1. ឥទ្ធិពលនៃច្បាប់ស្ដីពីសហគ្រាសមិនជាប់កាតព្វកិច្ច .................................................................................... 12
2. វិធានការទប់ស្កាត់.................................................................................... 13
3. វិធានការតម្រូវ.................................................................................... 14
4. នីតិវិធីបណ្ដឹង .................................................................................... 15
III. ព្រំដែនទៅលើការប្រើប្រាស់អ្នកផ្គត់ផ្គង់របស់សហគ្រាសជាប់កាតព្វកិច្ច....................................................................................16
1. គោលការណ៍នៃភាពសមស្រប និងប្រសិទ្ធភាព .................................................................................... 16
2. ព្រំដែនសម្រាប់ការផ្ទេរកាតព្វកិច្ចពីច្បាប់ទៅអ្នកផ្គត់ផ្គង់.................................................................................... 18
IV. ការណែនាំសម្រាប់កិច្ចសហការនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ ....................................................................................24
1. វិធីសាស្ត្រសម្រាប់ការវិភាគ .................................................................................... 25
2. វិធីសាស្ត្រសម្រាប់វិធានការទប់ស្កាត់.................................................................................... 30
3. វិធីសាស្ត្រសម្រាប់វិធានការតម្រូវ.................................................................................... 35
i. ការបែងចែកថ្លៃចំណាយសមស្រប 39
ii. កិច្ចសហការក្នុងការអនុលោមតាមច្បាប់ស្ដីពីការប្រកួតប្រជែងរបស់អាឡឺម៉ង់ 43
4. វិធីសាស្ត្រសម្រាប់នីតិវិធីបណ្ដឹង.................................................................................... 44
V. គន្លឹះសម្រាប់អ្នកផ្គត់ផ្គង់ដើម្បីអនុវត្តនីតិវិធីត្រួតពិនិត្យភាពត្រឹមត្រូវ ....................................................................................45
ឧបសម្ព័ន្ធ៖ ទិដ្ឋភាពរួមជាមួយនឹងឯកសារយោងសម្រាប់សេវាជំនួយដែលមានស្រាប់....................................................................................48

RESPONSIBLE BUSINESS HUB CAMBODIA
RBH NETWORK

# សេចក្តីសង្ខេប

## I. សេចក្តីផ្តើម

ច្បាប់ស្តីពីកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវ (due diligence) ក្នុងខ្សែចង្វាក់ផ្គត់ផ្គង់តម្រូវឱ្យសហគ្រាសដែលមានទំហំជាក់លាក់ (ចាប់ពីឆ្នាំ2023 ដែលមានបុគ្គលិកយ៉ាងតិច 3,000នាក់ នៅក្នុងប្រទេសអាឡឺម៉ង់ ពីឆ្នាំ 2024 ដែលមានបុគ្គលិកយ៉ាងតិច 1,000នាក់ នៅក្នុងប្រទេសអាឡឺម៉ង់) គោរពកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកសិទ្ធិមនុស្ស និងបរិស្ថានមួយចំនួន (សហគ្រាសជាប់កាតព្វកិច្ច)។ ជាងនេះទៅទៀត ច្បាប់នេះមានប្រសិទ្ធភាពទៅលើសហគ្រាសក្រៅវិសាលភាព ដែលមានទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់ដោយផ្ទាល់ ឬដោយប្រយោល ព្រោះច្បាប់ស្តីពីការត្រួតពិនិត្យភាពត្រឹមត្រូវក្នុងខ្សែចង្វាក់ផ្គត់ផ្គង់តម្រូវឱ្យសហគ្រាសជាប់កាតព្វកិច្ចសហការជាមួយអ្នកផ្គត់ផ្គង់របស់ខ្លួន ដើម្បីបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវ ទោះបីជាអ្នកផ្គត់ផ្គង់ទាំងនេះមិនមានកាតព្វកិច្ចផ្ទាល់ខ្លួន យោងទៅតាមច្បាប់ស្តីពីការត្រួតពិនិត្យភាពត្រឹមត្រូវក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ក៏ដោយ។ **នៅក្នុងបរិបទនេះ ពេលខ្លះ សហគ្រាសជាប់កាតព្វកិច្ចបង្កើតតម្រូវការដែលធំទូលាយ (ខ្លាំងពេក) ចំពោះអ្នកផ្គត់ផ្គង់របស់ខ្លួន។**

ឯកសារនេះបង្ហាញអំពីលទ្ធភាព និងព្រំដែនដែលច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវបានកំណត់ទៅលើតម្រូវការទាំងនេះ។ ម៉្យាងវិញទៀត វាមាននូវការណែនាំសម្រាប់កិច្ចសហប្រតិបត្តិការក្នុងគោលដៅស្ថាបនា។ ការិយាល័យសហព័ន្ធសម្រាប់កិច្ចការសេដ្ឋកិច្ច និងការត្រួតពិនិត្យការនាំចេញ (Bundesam t für Wirtschaft und Ausfuhrkon trolle, BAFA) បានផ្សព្វផ្សាយបន្ថែមនូវសៀវភៅគំរូដែលមានសំណួរ និង ចម្លើយសំខាន់ៗ បំផុតសម្រាប់សហគ្រាសធនតូច និងមធ្យម (SMEs) និង - រួមជាមួយនឹងផ្នែកផ្តល់ជំនួយ អំពីអាជីវកម្ម & សិទ្ធិ មនុស្ស- សេចក្តីសង្ខេប ប្រតិបត្តិនៃគោលការណ៍ណែនាំនេះជាឯកសារដាច់ដោយ ឡែកមួយ។[1]

## II. កំណត់សម្គាល់ទូទៅ

ក្នុងករណីជាច្រើន សហគ្រាសជាប់កាតព្វកិច្ចពឹងផ្អែកទៅលើកិច្ចសហការជាមួយអ្នកផ្គត់ផ្គង់ដើម្បីបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវរបស់ខ្លួន។ លក្ខខណ្ឌនេះមានចែងនៅក្នុងច្បាប់ និងចាប់ផ្តើមដោយការអនុវត្តប្រព័ន្ធគ្រប់គ្រងហានិភ័យ។ ជាងនេះទៅទៀត សហគ្រាសជាប់កាតព្វកិច្ចត្រូវការជំនួយពីអ្នកផ្គត់ផ្គង់របស់ខ្លួនពាក់ព័ន្ធនឹងការវិភាគហានិភ័យ វិធានការទប់ស្កាត់ និងដោះស្រាយ និងនីតិវិធីបណ្តឹង។ ទោះបីជាអ្នកផ្គត់ផ្គង់ពុំមានកាតព្វកិច្ចត្រូវសហការពាក់ព័ន្ធនឹងការត្រួតពិនិត្យភាពត្រឹមត្រូវក៏ដោយ ក៏កិច្ចសហការនៅក្នុងការអនុវត្តជាក់ស្តែងមានភាពចាំបាច់ និងសមហេតុផលសម្រាប់ភាគីទាំងពីរ។

**យ៉ាងណាមិញ កិច្ចសហការមិនសំដៅដល់ការពង្រីកវិសាលភាពច្បាប់ឡើយ។** ឧទាហរណ៍ ប្រសិនបើសហគ្រាសជាប់កាតព្វកិច្ចតម្រូវឱ្យអ្នកផ្គត់ផ្គង់របស់ខ្លួនអនុលោមតាមកាតព្វកិច្ចទាំងអស់នៃច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវនៅក្នុងខ្សែចង្វាក់

[1] សូមមើល "កិច្ចសហប្រតិបត្តិការក្នុងខ្សែចង្វាក់ផ្គត់ផ្គង់រវាងសហគ្រាសជាប់កាតព្វកិច្ច និងអ្នកផ្គត់ផ្គង់។ សំណួរ និងចម្លើយសំខាន់ៗបំផុតសម្រាប់សហគ្រាសធុនតូច និងមធ្យម"៖ https://www.bafa.de/SharedDocs/Downloads/DE/Lieferketten/faq_zusammenarbeit_lieferketten.pdf និង "សេចក្តីសង្ខេប ប្រតិបត្តិអមគោលការណ៍ណែនាំនេះ"។ https://www.bafa.de/SharedDocs/Downloads/DE/Lieferketten/executive_summary_zusammenarbeit_lieferketten.html?nn=1469788

ផ្គត់ផ្គង់ និងដោយពឹងផ្អែកទាំងស្រុងទៅលើចំណុចនេះ កត្តានេះអាចនឹងបណ្តាលឱ្យមានការវាយតម្លៃពី BAFA ទៅលើសហគ្រាសនេះពាក់ព័ន្ធនឹងអនុលោមភាពតាមច្បាប់។ **ហាមមិនឱ្យមានការផ្ទេរកាតព្វកិច្ចស្ថិតក្រោមច្បាប់នេះទៅឱ្យអ្នកផ្គត់ផ្គង់ឡើយ។** ការទាមទារឱ្យមានការធានាជាលាយលក្ខណ៍អក្សរពីអ្នកផ្គត់ផ្គង់ថា ពួកគេបានបំពេញតាមបទប្បញ្ញត្តិ និងវិធានការសិទ្ធិមនុស្ស និងបរិស្ថានពាក់ព័ន្ធនានាក៏មានការអនុវត្តទូលំទូលាយពេកផងដែរ។

សហគ្រាសនានាដែលស្ថិតក្រោមវិសាលភាពនៃច្បាប់នេះ ត្រូវទទួលខុសត្រូវក្នុងការអនុលោមតាម កាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវដោយខ្លួនឯងផ្ទាល់។ ទោះបីនៅក្នុងកាលៈទេសៈដែលច្បាប់តម្រូវឱ្យសហគ្រាសជាប់កាតព្វកិច្ចត្រូវសហការជាមួយសហគ្រាសមិនជាប់កាតព្វកិច្ចក៏ដោយ ក៏ច្បាប់នេះកំណត់ត្រឹមតែលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងសកម្មភាពនៃសហគ្រាសជាប់កាតព្វកិច្ចតែប៉ុណ្ណោះ។ **គោលការណ៍នៃភាពសមស្រប និងប្រសិទ្ធភាព** កំណត់លក្ខខណ្ឌឱ្យធ្វើសកម្មភាពតាមវិធីសាស្ត្រផ្អែកលើហានិភ័យ ហើយ **ក្នុងពេលជាមួយគ្នា កម្រិត ការផ្ទេរកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវត្រឹមតែអ្នកផ្គត់ផ្គង់ប៉ុណ្ណោះ។**

## III. លទ្ធិតពាក់ព័ន្ធនឹងការត្រួតពិនិត្យភាពត្រឹមត្រូវ

ក្នុងចំណោមករណីផ្សេងៗទៀត ការត្រួតពិនិត្យភាពត្រឹមត្រូវមានអត្ថន័យដូចខាងក្រោម៖

- សហគ្រាសក្រៅវិសាលភាពច្បាប់ **មិនជាប់កាតព្វកិច្ចក្នុងការអនុលោមតាមកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវឡើយ។** ហេតុដូច្នេះ BAFA នឹងមិនប្រើប្រាស់វិធានការបង្ខំឱ្យអនុវត្ត ឬទណ្ឌកម្មទៅលើសហគ្រាសទាំងនេះឡើយ។ BAFA ក៏នឹងមិនអនុវត្តការគ្រប់គ្រងផ្អែកលើហានិភ័យទៅលើសហគ្រាសដែលមិនជាប់កាតព្វកិច្ចផងដែរ។

- **សហគ្រាសមិនជាប់កាតព្វកិច្ចមិនត្រូវបានតម្រូវឱ្យធ្វើការរាយការណ៍ និងទទួលខុសត្រូវចំពោះ BAFA ឡើយ។** សហគ្រាសមិនជាប់កាតព្វកិច្ចមិនចាំបាច់ផ្សព្វផ្សាយរបាយការណ៍ពាក់ព័ន្ធនឹងការបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹម ត្រូវរបស់ខ្លួន ឬដាក់ជូនរបាយការណ៍ទៅកាន់ BAFA ឡើយ។ លើសពីនេះ សហគ្រាសមិនជាប់កាតព្វកិច្ចពុំមានកាតព្វ កិច្ចក្នុងការចូលរួមដោយផ្ទាល់ក្នុងការបង្កើតរបាយការណ៍ទាំងនេះដូចជាសហគ្រាសជាប់កាតព្វកិច្ចនោះទេ។

- **សហគ្រាសជាប់កាតព្វកិច្ចមិនអាចជំនួសការវិភាគហានិភ័យរបស់ខ្លួនដោយការយោងទៅទៅលើការធានាតាមកិច្ចសន្យា ឬការធានាដែលពាក់ព័ន្ធពីអ្នកផ្គត់ផ្គង់របស់ខ្លួនថា ខ្សែចង្វាក់ផ្គត់ផ្គង់ របស់ខ្លួនគ្មានហានិភ័យឡើយ។** សហគ្រាសជាប់កាតព្វកិច្ចចាំបាច់ត្រូវធ្វើការវិភាគហានិភ័យផ្ទាល់ ខ្លួនដើម្បីធានាថា ខ្លួនបានបំពេញកាតព្វកិច្ចរបស់ខ្លួនស្ថិតក្រោមច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវក្នុងខ្សែចង្វាក់ផ្គត់ផ្គង់។ សហគ្រាសដែលមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួននៅក្នុងការ វិភាគហានិភ័យ ដោយទាមទារឱ្យមានការប្រកាសដោយខ្លួនឯងលក្ខណៈទូទៅ និងទូលំទូលាយដោយមិនគិតពីស្ថានភាពជាក់លាក់ ឬហានិភ័យនៃអ្នកផ្គត់ផ្គង់។ ការអនុវត្តបែបនេះអាចនាំឱ្យមានការចាត់វិធានការសមស្របពី BAFA។

- **សហគ្រាសជាប់កាតព្វកិច្ចត្រូវពិចារណាទៅលើលទ្ធផលនៃការវិភាគហានិភ័យរបស់ខ្លួននៅពេលស្នើសុំព័ត៌មានពីអ្នកផ្គត់ផ្គង់។** នៅក្នុងបរិបទនៃការវិភាគហានិភ័យសមស្របសហគ្រាសជាប់កាតព្វកិច្ច គួរធ្វើការស៊ើបអង្កេតហានិភ័យទៅលើអ្នកផ្គត់ផ្គង់ដែលគ្មាន ឬមានហានិភ័យទាប ដោយប្រើវិធានការមិនសូវធ្ងន់ធ្ងរ ដូចអ្នកផ្គត់ផ្គង់

ដែលមានហានិភ័យខ្ពស់។ ដូចនេះ ទាំងការស្នើសុំព័ត៌មានបែបទូទៅ និងការ អនុវត្តវិធានការទប់ស្កាត់ដែលមិនខុសគ្នាចំពោះអ្នកផ្គត់ផ្គង់គឺមិនសមស្របនោះទេ។

- សហគ្រាសជាប់កាតព្វកិច្ចមិនអាចផ្ទេរការអនុវត្តវិធានការទប់ស្កាត់ទៅឱ្យអ្នកផ្គត់ផ្គង់របស់ខ្លួនបានឡើយ។ ពួកគេមិនបានបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវនេះ ដោយគ្រាន់តែយោងទៅ លើការធានា**ជាលាយលក្ខណ៍អក្សរពីអ្នកផ្គត់ផ្គង់ ឬដោយការផ្តល់សេចក្តីប្រកាសទូទៅពីការជម្រុះកាតព្វកិច្ច។** ផ្ទុយទៅវិញ វិធានការទប់ស្កាត់រួមទាំងការធានាតាមកិច្ចសន្យាត្រូវពិចារណាពីលទ្ធផលនៃការ វិភាគហានិភ័យផ្ទាល់ខ្លួន និងត្រូវមានការរៀបចំតាមវិធីដែលសមស្រប និងមានប្រសិទ្ធភាព។

- **សហគ្រាសជាប់កាតព្វកិច្ច ជាអ្នកទទួលខុសត្រូវក្នុងការធានាឱ្យមានការអនុវត្តការបណ្តុះបណ្តាល និងអប់រំបន្ថែម។** ជំហានដំបូង និងសំខាន់បំផុត សហគ្រាសជាប់កាតព្វកិច្ចគួរជួយអ្នកផ្គត់ផ្គង់ដោយការទទួល ស្គាល់ និងដោះស្រាយបញ្ហាហានិភ័យសិទ្ធិមនុស្ស និងបរិស្ថាននៅដំណាក់កាលដំបូង។ លើសពីនេះ សហគ្រាសជាប់កាតព្វកិច្ចគួរជួយអ្នកផ្គត់ផ្គង់ឱ្យអនុលោមតាមតាម និងអនុវត្តកាតព្វកិច្ចបែបកិច្ចសន្យាប្រកបដោយប្រសិទ្ធភាព។

- ច្បាប់តម្រូវឱ្យសហគ្រាសជាប់កាតព្វកិច្ច**អនុវត្តយន្តការត្រួតពិនិត្យសមស្របតាមកិច្ចសន្យា និងអនុវត្តការត្រួតពិនិត្យទៅលើអ្នកផ្គត់ផ្គង់របស់ខ្លួន។** ការប្រកាសដោយខ្លួនឯងរបស់អ្នកផ្គត់ផ្គង់អាចជាឧបករណ៍ជំនួយដ៏មានប្រយោជន៍មួយសម្រាប់ការតាមដានកំពុងបន្ត។

  យ៉ាងណាមិញ ការប្រកាសដោយខ្លួនឯងជាលាយលក្ខណ៍អក្សរជាទៀតទាត់ថាអ្នកផ្គត់ផ្គង់អនុលោម តាមលក្ខខណ្ឌសិទ្ធិមនុស្ស និងបរិស្ថាន ដែលបានព្រមព្រៀងតែម្យ៉ាងមិនគ្រប់គ្រាន់ជាវិធានការត្រួតពិនិត្យឡើយ។ ប្រសិនបើសហគ្រាសជាប់កាតព្វកិច្ចស្នើសុំការប្រកាសបែបនេះតាមរបៀបទូទៅ និងទូលំទូលាយ ពីអ្នកផ្គត់ផ្គង់ទាំងអស់ វាអាចជាការមិនសមស្រប និងបំពានច្បាប់ផងដែរ។

- **សហគ្រាសជាប់កាតព្វកិច្ចមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការអនុវត្តនីតិវិធីបណ្តឹងដោយយោងទៅនីតិវិធីបណ្តឹងរបស់អ្នកផ្គត់ផ្គង់។** សហគ្រាសជាប់កាតព្វកិច្ចត្រូវរៀបចំនីតិវិធីបណ្តឹងតាមវិធីណា មួយដែលប្រជាជនអាចជូនដំណឹងខ្លួនអំពីហានិភ័យ និងការបំពានលើកាតព្វកិច្ចសិទ្ធិមនុស្ស និងបរិស្ថាន ដែលកើតឡើងដោយសារសកម្មភាពសេដ្ឋកិច្ចរបស់អ្នកផ្គត់ផ្គង់។ ម្យ៉ាងវិញទៀត សហគ្រាសអាចចូលរួមក្នុង នីតិវិធីបណ្តឹងខាងក្រៅដែលសមស្រប។ យ៉ាងណាមិញ ច្បាប់មិនអនុញ្ញាតឱ្យសហគ្រាសយោងទៅលើ តែនីតិវិធីបណ្តឹងដែលបានកំណត់ដោយអ្នកផ្គត់ផ្គង់តែម្យ៉ាងឡើយ។

- សហគ្រាសជាប់កាតព្វកិច្ចគួរពិចារណាពីសមត្ថភាពនៃអ្នកផ្គត់ផ្គង់របស់ខ្លួននៅពេលធ្វើការវាយតម្លៃអំពីប្រសិទ្ធភាពនៃវិធានការ។ សមត្ថភាពអាស្រ័យជាពិសេសទៅលើធនធាន ទំហំ វិស័យ និងស្ថានភាព របស់អ្នកផ្គត់ផ្គង់នៅក្នុងខ្សែផ្គត់ផ្គង់ និងលក្ខខណ្ឌជាក់លាក់ក្នុងតំបន់។ **វិធានការដែលបានអនុវត្ត ដោយសហគ្រាសជាប់កាតព្វកិច្ចដែលជាក់ស្តែងគឺជាលក្ខខណ្ឌខ្ពស់ពេកសម្រាប់អ្នកផ្គត់ផ្គង់ ជាទូទៅពុំមានប្រសិទ្ធភាព និងមិនសមស្របឡើយ។**

## IV. អនុសាសន៍សម្រាប់កិច្ចសហការនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់

ការបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវគឺជាដំណើរការរៀនសូត្រជាប្រចាំសម្រាប់អ្នកចូលរួមទាំងអស់ ហើយត្រូវយល់ថា កិច្ចសហការនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់គឺជាដំណើរការដ៏សកម្មដោយផ្អែកលើការសន្ទនា។ សហគ្រាសជាប់កាតព្វកិច្ចត្រូវតែដឹងអំពីតួនាទី និងសមត្ថភាពរបស់ខ្លួនក្នុងការប្រើប្រាស់ឥទ្ធិពល។ សហគ្រាសជាប់កាតព្វកិច្ចគួរសហការជាមួយអ្នកផ្គត់ផ្គង់ដោយត្រឹមត្រូវ និងស្មើភាពគ្នាក្នុងរយៈពេលយូរទៅមុខទៀត។ ជាទូទៅគំនិតផ្តួចផ្តើមនៅក្នុងវិស័យសមស្របអាចគាំទ្រកិច្ចការនេះបាន។ គួរពិចារណាទៅលើវិធានការ និងវិធីសាស្ត្រខាងក្រោមសម្រាប់កិច្ចសហការដែលសមស្រប ៖

### ការវិភាគហានិភ័យ

តម្លាភាព និងចំណេះដឹងពីហានិភ័យសិទ្ធិមនុស្ស និងបរិស្ថាននៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់របស់ខ្លួនគឺ ជាគន្លឹះក្នុងការបំពេញកាតព្វកិច្ចការត្រួតពិនិត្យភាពត្រឹមត្រូវ។ ដូចនេះ សហគ្រាសជាប់កាតព្វកិច្ចគួរដំណើរការវិធីសាស្ត្រផ្អែកលើហានិភ័យ និងវាយតម្លៃថាតើព័ត៌មានណាខ្លះដែល ពួកគេត្រូវការពីអ្នកផ្គត់ផ្គង់សម្រាប់ធ្វើការវិភាគហានិភ័យដែលសមស្រប។

### សម្រាប់សហគ្រាសជាប់កាតព្វកិច្ចវាមានន័យថា

- នៅពេលស្នើសុំព័ត៌មានពីអ្នកផ្គត់ផ្គង់ សហគ្រាសជាប់កាតព្វកិច្ចគួរបញ្ជាក់មូលហេតុច្បាស់លាស់ សម្រាប់ករណីជាច់ដោយឡែកនីមួយៗថា តើហេតុអ្វីត្រូវការព័ត៌មាននេះ និងដើម្បីគោលបំណងអ្វី?
- សហគ្រាសជាប់កាតព្វកិច្ចត្រូវធានាការការពារទិន្នន័យដែលបានស្នើសុំ ឧទាហរណ៍ ជាមួយនឹងកិច្ចព្រមព្រៀងរក្សាការសម្ងាត់ ។
- សហគ្រាសជាប់កាតព្វកិច្ចគួរផ្តល់ធនធាន ព័ត៌មាន និងឧបករណ៍សម្រាប់ការវិភាគហានិភ័យរបស់ខ្លួន ដល់អ្នកផ្គត់ផ្គង់ដែលមិនជាប់កាតព្វកិច្ច។

### ជាពិសេស អ្នកផ្គត់ផ្គង់គួរ

- ក្នុងករណីការស្នើសុំទិន្នន័យមិនត្រូវបានបញ្ជាក់មូលហេតុច្បាស់លាស់ អ្នកផ្គត់ផ្គង់គួរស្នើសុំការបញ្ជាក់មូលហេតុ ហើយបញ្ជូនព័ត៌មានតែនៅបន្ទាប់ពីទទួលបានការបញ្ជាក់ មូលហេតុប៉ុណ្ណោះ។
- អ្នកផ្គត់ផ្គង់គួរមានការប្រុងប្រយ័ត្នចំពោះការការពារទិន្នន័យដែលបញ្ជូនដោយសហគ្រាសជាប់កាតព្វកិច្ច។

### ជាទូទៅ

- សហគ្រាសជាប់កាតព្វកិច្ច និងអ្នកផ្គត់ផ្គង់របស់ខ្លួនគួរបង្កើតការយល់ដឹងជារួមនៃហានិភ័យ ដែលសហគ្រាសជាប់កាតព្វកិច្ចបានកំណត់ ហើយប្រើប្រាស់វាជាមូលដ្ឋាន សម្រាប់អនុវត្តសកម្មភាពបន្ត។

### វិធានការទប់ស្កាត់

មុនពេលធ្វើការទាមទារទៅអ្នកផ្គត់ផ្គង់ សហគ្រាសជាប់កាតព្វកិច្ចគួរវាយតម្លៃដោយយកចិត្តទុកដាក់ទៅលើការទាមទាររបស់ខ្លួន មូលដ្ឋានច្បាប់សម្រាប់ការទាមទាររបស់ខ្លួន ប្រសិទ្ធភាពនៃការទាមទាររបស់ខ្លួនក្នុងបរិបទនៃវិធីសាស្ត្រផ្អែកលើហានិភ័យ និងថាតើវា អាចអនុវត្តជាក់ស្តែងស្របតាមទៅច្បាប់ពាក់ព័ន្ធនឹងខចែង និងលក្ខខណ្ឌទូទៅដែរឬទេ។ នៅក្នុងបរិបទនេះ គួរកត់សម្គាល់ផងដែរថា ច្បាប់នេះមិនបានកំណត់មូលដ្ឋានឯករាជ្យណាមួយសម្រាប់ការ ទទួលខុសត្រូវរវាងគូភាគីនៃកិច្ចសន្យានៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ឡើយ។ សហគ្រាសជាប់កាតព្វកិច្ច គួរធានាបែបកិច្ចសន្យាដោយមានវិធានការត្រួតពិនិត្យ បណ្តុះបណ្តាល និងការអប់រំបន្ត នៅក្នុងការទទួលខុសត្រូវរបស់ខ្លួន។

### សម្រាប់សហគ្រាសជាប់កាតព្វកិច្ចចំណុចនេះមានន័យថា៖

- នៅពេលទាមទារការធានាពីអ្នកផ្គត់ផ្គង់ សហគ្រាសជាប់កាតព្វកិច្ចគួរយោងទៅលើការវិភាគហានិភ័យរបស់ខ្លួន និងហានិភ័យដែលបានកំណត់ និងកំណត់អាទិភាព រួចដាក់ជូនរបាយការណ៍គោលនយោបាយរបស់ខ្លួន។
- សហគ្រាសជាប់កាតព្វកិច្ចត្រូវបង្ហាញដល់អ្នកផ្គត់ផ្គង់អំពីរបៀបដែលខ្លួនអាចបំពេញការធានា និងថាតើ សហគ្រាសជាប់កាតព្វកិច្ចគាំទ្រខ្លួនដោយប្រើប្រាស់ធនធានផ្ទាល់ខ្លួន និងថាតើគាំទ្រដោយរបៀបណា។
- ជាទូទៅ សហគ្រាសជាប់កាតព្វកិច្ចមិនត្រូវបញ្ចប់ទំនាក់ទំនងអាជីវកម្មដោយសារតែភាពស្ទាក់ស្ទើរក្នុងកិច្ចសហការ ឬគាំទ្រទៅលើការអនុវត្តវិធានការទប់ស្កាត់ឡើយ ប្រសិនបើការអនុវត្តវិធានការទប់ស្កាត់ខកខានដោយសារតែខ្វះកិច្ចសហការពីអ្នកផ្គត់ផ្គង់ នោះសហគ្រាសជាប់កាតព្វកិច្ចគួរតែអាចបង្ហាញអំពីការពិតនេះតាមវិធីដែលសមហេតុផលទៅកាន់ BAFA។

### អ្នកផ្គត់ផ្គង់គួរ៖

- ប្រសិនបើចាំបាច់ អ្នកផ្គត់ផ្គង់គួរតែស្វែងរកការប្រឹក្សាផ្នែកច្បាប់ទៅតាមករណីនីមួយៗ ប្រសិនបើសហគ្រាសជាប់កាតព្វកិច្ចទាមទារឱ្យមានការប្តេជ្ញាចិត្តពីអ្នកផ្គត់ផ្គង់នៅក្នុងផ្នែកបន្ថែមនៃកិច្ចសន្យា ឬការធានាបែបកិច្ចសន្យាដោយសារតែច្បាប់អ្នកផ្គត់ផ្គង់គួរវាយតម្លៃ ថាតើកិច្ចសហការពាក់ព័ន្ធនឹងការអនុវត្តវិធានការទប់ស្កាត់រវាងខ្លួន និងសហគ្រាសជាប់កាតព្វកិច្ចសមហេតុផលដែរឬទេ។

RESPONSIBLE BUSINESS HUB CAMBODIA
RBH NETWORK

### វិធានការតម្រូវ

ថ្លៃចំណាយសម្រាប់វិធានការតម្រូវនៅក្នុងករណីរំលោភលើជំហរផ្លូវច្បាប់ដែលមានការការពារគួរត្រូវ បានចែករំលែកឱ្យបានសមស្របរវាងសហគ្រាសជាប់កាតព្វកិច្ច និងអ្នកផ្គត់ផ្គង់របស់ខ្លួន។ សហគ្រាស ជាប់កាតព្វកិច្ចទទួលខុសត្រូវក្នុងការរៀបចំសំណើស្តីពីរបៀបចំណាយទាំងនេះត្រូវបែងចែកដោយយោងទៅតាមលក្ខខណ្ឌវិនិច្ឆ័យនៃភាពសមស្រប និងប្រសិទ្ធភាព។ ក្នុងករណីមានការត្រួតពិនិត្យពី BAFA ពួកគេគួរតែអាចពន្យល់ពីហេតុផលសម្រាប់ការបែងចែកជាក់លាក់នៃថ្លៃចំណាយ តាមរបៀបដែលអាចជឿទុកចិត្តបាន។

### សម្រាប់សហគ្រាសជាប់កាតព្វកិច្ចចំណុចនេះគឺមានន័យថា៖

- សហគ្រាសជាប់កាតព្វកិច្ចគួរវាយតម្លៃថាតើធនធានមនុស្ស បច្ចេកទេស ហិរញ្ញវត្ថុណាមួយដែលមានសម្រាប់សហគ្រាសទាំងអស់ដែលចូលរួមនៅក្នុងវិធានការតម្រូវរៀងៗខ្លួន សហគ្រាសជាប់កាតព្វកិច្ចគួរពិចារណាទៅលើលទ្ធភាពក្នុងការបញ្ចុះបញ្ចូលភាគីដែលទទួលខុសត្រូវផ្ទាល់ទៅលើការរំលោភបំពានរបស់សហគ្រាសដែលចូលរួមទាំងអស់រៀងៗខ្លួន ពួកគេគួរតែធ្វើការវាយតម្លៃ ប្រៀបធៀបទៅលើកម្រិតនៃការចូលរួមចំណែកទៅក្នុងការរំលោភបំពាននៃសហគ្រាសដែលចូលរួមទាំងអស់។

### អ្នកផ្គត់ផ្គង់គួរ៖

- វាយតម្លៃថា តើធនធានណាដែលខ្លួនអាចប្រើប្រាស់សម្រាប់វិធានការតម្រូវ ដែលចាំបាច់កំណត់ថាតើ ខ្លួនបាន (អាច) ចូលរួមចំណែកកម្រិតណានៅក្នុងការរំលោភបំពាន។

RESPONSIBLE BUSINESS HUB CAMBODIA
RBH NETWORK

**នីតិវិធីបណ្តឹង**

សហគ្រាសជាប់កាតព្វកិច្ចគួរដឹងថាអត្ថប្រយោជន៍របស់ខ្លួននៅក្នុងការចូលទៅប្រើប្រាស់ព័ត៌មានពាក់ព័ន្ធនឹងមុខងារ និងលទ្ធភាពនៃនីតិវិធីបណ្តឹងសារទុក្ខរបស់ខ្លួនអាចប៉ះពាល់ដល់ផល ប្រយោជន៍ផ្នែកច្បាប់នៃអ្នកផ្គត់ផ្គង់ក្នុងការកំណត់ការទំនាក់ទំនងផ្ទាល់រវាងអ្នកផ្គត់ផ្គង់ផ្នែកខាង លើនិងសហគ្រាសជាប់កាតព្វកិច្ច។

## សម្រាប់សហគ្រាសជាប់កាតព្វកិច្ចចំណុចនេះគឺមានន័យថា៖

- សហគ្រាសជាប់កាតព្វកិច្ចទទួលខុសត្រូវក្នុងការអនុវត្តនីតិវិធីបណ្តឹងដែលមានប្រសិទ្ធភាព ឬចូលរួមក្នុងនីតិវិធីបណ្តឹងខាងក្រៅដែលសមស្រប ពួកគេត្រូវទទួលខុសត្រូវក្នុងការផ្តល់នូវដំណោះស្រាយដល់អ្នកផ្គត់ផ្គង់ដែលពាក់ព័ន្ធនៅក្នុងស្ថានភាពនេះ ដូចជាការចូលរួមនៅក្នុងនីតិវិធីបណ្តឹងខាងក្រៅ (ឧ. គំនិតផ្តួចផ្តើមពហុភាគី) ឬការចូល រួបរួមគ្នារបស់អ្នកពាក់ព័ន្ធក្នុងតំបន់ ឬក្នុងឧស្សាហកម្ម (ឧ. សហជីពពាណិជ្ជកម្ម) ពួកគេត្រូវតែរៀបចំនីតិវិធីបណ្តឹងតាមវិធីដែលអនុញ្ញាតឱ្យមានការការពារព័ត៌មានសម្ងាត់នៃអត្តសញ្ញាណរបស់អ្នករាយការណ៍ និងការការពារប្រកបដោយប្រសិទ្ធភាពពីផលវិបាក និងការ ពិន័យដោយសារតែបណ្តឹង។

## អ្នកផ្គត់ផ្គង់គួរ៖

- ពេលមានការស្នើសុំព័ត៌មាន អ្នកផ្គត់ផ្គង់គួរវាយតម្លៃថាតើព័ត៌មានណាដែលដៃគូបែបកិច្ចសន្យារបស់ខ្លួនត្រូវការពិតប្រាកដ និងថាតើអត្ថប្រយោជន៍ស្របច្បាប់មានទំនាស់ទៅនឹង ការបង្ហាញព័ត៌មានដែរឬទេ ( cf. ការណែនាំពាក់ព័ន្ធនឹងការវិភាគហានិភ័យ) ពួកគេគួរប្រតិបត្តិតាមគោលការណ៍នៃកាត់បន្ថយទិន្នន័យដើម្បីធ្វើបែបនេះពួកគេអាច ប្រើប្រាស់កិច្ចព្រមព្រៀងរក្សាការសម្ងាត់។

# គោលការណ៍ណែនាំស្តីពីកិច្ចសហការនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់

## I. ភាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវរបស់ក្រុមហ៊ុន និងច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវក្នុងខ្សែចង្វាក់ផ្គត់ផ្គង់

មូលដ្ឋានគ្រឹះនៃច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ត្រូវបានដាក់ចេញព្រមជាមួយនឹងផែនការសកម្មភាពជាតិស្តីពីពាណិជ្ជកម្ម និងសិទ្ធិមនុស្ស (NAP) របស់រដ្ឋាភិបាលសហព័ន្ធ នៅក្នុងឆ្នាំ 2016។ NAP ដើរតួនាទីជាក្នុងការអនុវត្តគោលនយោបាយអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និង សិទ្ធមនុស្ស (UNGP) ឆ្នាំ2011។ ពួកគេបានប្រកាសពីការទទួលខុសត្រូវរបស់សហគ្រាសក្នុងការគោរព សិទ្ធិមនុស្សនៅក្នុងក្របខណ្ឌភាពចុះសម្រុងជាសកល និងអន្តរជាតិ។ ពួកគេថ្លែងទៅកាន់សហគ្រាស ទាំងអស់នៅទូទាំងពិភពលោកគ្រប់វិស័យ ដោយមិនគិតពីទំហំឡើយ។ រដ្ឋត្រូវបានអំពាវនាវឱ្យលើកកម្ពស់ការគោរពសិទ្ធិមនុស្សរបស់សហគ្រាសដោយការរួមបញ្ចូលគ្នាដ៏ឆ្លាតវៃនៃកាតព្វកិច្ចផ្លូវច្បាប់ និង វិធានការស្ម័គ្រចិត្ត។

នៅក្នុង NAP រដ្ឋាភិបាលសហព័ន្ធបានបង្ហាញអំពីការរំពឹងទុករបស់ខ្លួនទៅកាន់សហគ្រាសទាំងអស់នៅក្នុងប្រទេសអាឡឺម៉ង់ឱ្យដាក់ប្រើប្រាស់ដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវរបស់ក្រុមហ៊ុនតាមវិធីដែលស័ក្តិ សមនឹងទំហំ វិស័យ និងជំហររបស់ពួកគេនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ និងខ្សែចង្វាក់តម្លៃដើម្បីបំពេញ ការទទួលខុសត្រូវរបស់ពួកគេក្នុងការគោរពសិទ្ធិមនុស្សនៅក្នុងខ្សែចង្វាក់តម្លៃ និងផ្គត់ផ្គង់សកល។[2] ការអនុវត្តប្រព័ន្ធគ្រប់គ្រងហានិភ័យដែលរឹងមាំគួរតែផ្អែកទៅលើធាតុសំខាន់ៗចំនួន ប្រាំ៖ សេចក្តីប្រកាស គោលនយោបាយ ការវិភាគហានិភ័យ វិធានការ ការរាយការណ៍ និងយន្តការតវ៉ា។ ចំណុចសំខាន់មួយ ទៀតនៃការតម្រង់ទិសច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវគឺគោលការណ៍ ណែនាំ OECD សម្រាប់សហគ្រាស ចម្រុះជាតិសាសន៍ដែលណែនាំសហគ្រាសគ្រប់ទំហំឱ្យគោរព សិទ្ធិមនុស្សនៅក្នុងប្រតិបត្តិការរបស់ខ្លួន។

ច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវបានអនុវត្តចាប់តាំងពីថ្ងៃទី 1 ខែ មករា ឆ្នាំ 2023 ទៅលើសហគ្រាស ដែលមានរដ្ឋបាលកណ្តាល ទីតាំងអាជីវកម្មគោល ទីស្នាក់ការកណ្តាលអសនៈផ្លូវច្បាប់នៅក្នុងប្រទេសអាឡឺម៉ង់ ឬការិយាល័យសាខាក្នុងស្រុកដែលយោងតាមផ្នែក 13d នៃក្រមពាណិជ្ជកម្ម (Han delsgesetzbuch – HGB) និងមានបុគ្គលិកយ៉ាងតិច 3,000 នាក់ នៅក្នុងប្រទេសអាឡឺម៉ង់។ ចាប់ពីថ្ងៃទី 01 ខែមករា ឆ្នាំ 2024 ច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវនេះក៏នឹងអនុវត្តចំពោះសហគ្រាសដែលមាន បុគ្គលិកយ៉ាងតិច 1,000 នៅក្នុងប្រទេសអាឡឺម៉ង់ផងដែរ។[3]

សហគ្រាសដែលស្ថិតនៅក្នុងវិសាលភាពនៃច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវមានកាតព្វកិច្ចគោរពតាម កាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកបរិស្ថាន និងសិទ្ធិមនុស្សតាមរបៀបដែលសមស្រប និងមាន ប្រសិទ្ធិភាព។[4] ខ្សែចង្វាក់ផ្គត់ផ្គង់នៅក្នុងអត្ថន័យ

---

[2] រដ្ឋាភិបាលសហព័ទ្ធបច្ចុប្បន្នកំពុងតែកែប្រែ និងធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពជាតិ និងដាក់បញ្ចូលច្បាប់ស្តីពីការត្រួតពិនិត្យភាពត្រឹមត្រូវទៅក្នុងយុទ្ធសាស្ត្ររួមស្តីពីពាណិជ្ជកម្ម និងសិទ្ធិមនុស្ស។

[3] ដើម្បីកំណត់ចំនួនបុគ្គលិក សូមមើលផ្នែកទី 1 នៃច្បាប់ស្តីពីការត្រួតពិនិត្យភាពត្រឹមត្រូវ អនុស្សរណៈពន្យល់របស់រដ្ឋាភិបាលទៅលើច្បាប់ស្តីពីការត្រួតពិនិត្យភាពត្រឹមត្រូវ៖ BT-Drs. 19/28649, p. 33 et seq., និង ជំពូក III នៃ FAQ នៅលើគេហទំព័ររបស់ BAFA។ សហគ្រាសត្រូវវាយតម្លៃជាបន្តបន្ទាប់ និងដោយឯករាជ្យ ថាតើវាចូលទៅក្នុងវិសាលភាពនៃច្បាប់ស្តីពីការត្រួតពិនិត្យភាពត្រឹមត្រូវដែរឬទេ ហើយត្រូវទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មានពាក់ ព័ន្ធនឹងករណីនេះទៅ BAFA (ផ្នែកទី 17 4 § 2 លេខ 1 នៃច្បាប់ស្តីពីការត្រួតពិនិត្យភាពត្រឹមត្រូវ)។

[4] កាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវត្រឹមត្រូវបានកំណត់នៅក្នុងផ្នែក 3 § 1 នៃច្បាប់ស្តីពីការត្រួតពិនិត្យភាពត្រឹមត្រូវ។ ផ្នែក 3 § 2 នៃច្បាប់នេះបានកំណត់លក្ខខណ្ឌវិនិច្ឆ័យដាច់ខាតទៅលើភាពសមស្រប ផ្នែក 4 § 2 នៃច្បាប់នេះបានកំណត់លក្ខខណ្ឌវិនិច្ឆ័យដាច់ខាតទៅលើប្រសិទ្ធភាពនៃ វិធានការ។ គោលការណ៍ណែនាំរបស់ BAFA ស្តីពីភាពសមស្រប និងប្រសិទ្ធភាព បានផ្តល់ការពន្យល់ និងការណែនាំបន្ថែមស្តីពីការអនុវត្តជាក់ស្តែង៖ https://www.bafa.de/EN/Supply_Chain_Act/Appropriateness_and_Effectiveness/appropriateness_and_effectivene

ss_node.html

របស់ច្បាប់នេះរួមបញ្ចូលគ្រប់ដំណាក់កាលទាំងអស់នៅក្នុង ប្រទេសអាល្លឺម៉ង់ និងបរទេសដែលចាំបាច់ក្នុងការបង្កើតផលិតផល និងផ្តល់សេវា រាប់ចាប់ពីការ ចម្រាញ់យកវត្ថុធាតុដើម រហូតដល់ការដឹកជញ្ជូនទៅកាន់អ្នកប្រើប្រាស់ចុងក្រោយ និងរួមទាំងសកម្ម ភាពរបស់សហគ្រាសនៅក្នុងតំបន់អាជីវកម្មរបស់ខ្លួន អ្នកផ្គត់ផ្គង់ផ្ទាល់ និងអ្នកផ្គត់ផ្គង់ប្រយោល។[5] នៅក្នុងកាតព្វកិច្ចនៃមធ្យោបាយដែលបានផ្តល់ដោយច្បាប់នេះ សហគ្រាសមិនត្រូវធានាថាខ្សែចង្វាក់ផ្គត់ផ្គង់របស់ពួកគេមិនមានហានិភ័យ និងការរំលោភលើសិទ្ធិមនុស្ស ឬមិនមានផលប៉ះពាល់អវិជ្ជមានទៅ លើបរិស្ថានឡើយ។ ផ្ទុយទៅវិញ ពួកគេត្រូវបង្ហាញថាពួកគេបានអនុវត្តកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវដូចដែលបានរៀបរាប់នៅក្នុងផ្នែកទី 4 ដល់ ទី 10 នៃច្បាប់នេះ។ ដរាបណាសហគ្រាសអនុវត្ត តាមកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវរបស់ពួកគេតាមវិធីដែលមានប្រសិទ្ធភាព និងសមស្រប ការរំលោភលើសិទ្ធិមនុស្ស និងបរិស្ថានដែលមានការការពារ ជាទូទៅមិនមែនជាការរំលោភលើកាតព្វកិច្ច ត្រួតពិនិត្យភាពត្រឹមត្រូវទេ។

ការិយាល័យសហព័ន្ធសម្រាប់កិច្ចការសេដ្ឋកិច្ច និងត្រួតពិនិត្យការនាំចេញ (Bun desamt für Wirtschaft und Ausfuhrkon trolle, BAFA) ទទួលខុសត្រូវទៅលើការត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់។ បន្ថែម ពីលើការវាយតម្លៃនៃរបាយការណ៍ប្រចាំឆ្នាំ និងបណ្តឹងរបស់អ្នកដែលរងផលប៉ះពាល់ពាក់ព័ន្ធនឹងការ រំលោភកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវ BAFA បានធ្វើការត្រួតពិនិត្យផ្អែកលើហានិភ័យទៅលើសហគ្រាសជាប់កាតព្វកិច្ច។ ក្នុងករណីមានអនុលោមភាពទៅតាមលក្ខខណ្ឌតម្រូវ BAFA អាចបង្គាប់ឱ្យសហគ្រាសអនុវត្តវិធានការដែលចាំបាច់ និងសមស្រប រួចដាក់ពិន័យជាសាច់ប្រាក់ និងពិន័យរដ្ឋបាល។ ក្នុងករណីមានការពិន័យសម្រាប់ការរំលោភធ្ងន់ធ្ងរដែលបង្កើតឡើងដោយការសម្រេចចិត្ត ចុងក្រោយ និងដែលជាកាតព្វកិច្ច វាក៏អាចមានការដកចេញពីលទ្ធកម្មសាធារណៈផងដែរ។[6]

## II. ឥទ្ធិពលនៃច្បាប់ស្តីពីសហគ្រាសមិនជាប់កាតព្វកិច្ច

ច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវក៏មានឥទ្ធិពលទៅលើសហគ្រាស ដែលមិនស្ថិតនៅក្នុងវិសាលភាពរបស់ខ្លួន ប៉ុន្តែគឺជាអ្នកផ្គត់ផ្គង់ ឬជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់សហគ្រាសជាប់កាតព្វកិច្ច។ ករណីនេះ គឺដោយសារតែសហគ្រាសជាប់កាតព្វកិច្ចត្រូវអនុលោមតាមកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកសិទ្ធិមនុស្ស និងបរិស្ថាន ក៏ដូចជាពាក់ព័ន្ធទៅនឹងសហគ្រាសមិនជាប់កាតព្វកិច្ចនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ របស់ពួកគេផងដែរប្រសិនបើពួកគេ៖

- ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលជាផ្នែកមួយនៃអាជីវកម្មដ្ឋានរបស់ខ្លួន (ចាត់ទុកជា)[7]
- អ្នកផ្គត់ផ្គង់ផ្ទាល់ ឬ (លក្ខខណ្ឌតម្រូវមិនច្បាស់លាស់) ប្រយោល

នៅក្នុងករណីជាច្រើន សហគ្រាសជាប់កាតព្វកិច្ចត្រូវពឹងផ្អែកលើកិច្ចសហការជាមួយសហគ្រាសមិនជាប់កាតព្វកិច្ច ពោលគឺក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬអ្នកផ្គត់ផ្គង់នៅក្នុងប្រទេសអាល្លឺម៉ង់ ឬបរទេសដើម្បី បំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវរបស់ខ្លួន។ កិច្ចការនេះត្រូវចាប់ផ្តើមដោយការអនុវត្តប្រព័ន្ធគ្រប់គ្រងហានិភ័យ ដែលត្រូវមានការពិចារណាឱ្យបានសមស្របទៅលើផលប្រយោជន៍នៃបុគ្គលិក និងអ្នកដែលអាចរងផលប៉ះពាល់ពីសកម្មភាពសេដ្ឋកិច្ចនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់។[8] ក្រៅពីនេះ សហគ្រាសជាប់កាតព្វកិច្ចនឹងត្រូវការការគាំទ្រ ឬកិច្ចសហការពាក់ព័ន្ធនឹងកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវដូចខាងក្រោម

[5] ផ្នែក 2 ខ 7 និង 8 ក៏ដូចជាផ្នែក 5 ខ 1 នៃច្បាប់នេះ។

[6] ផ្នែកទី 15 ក៏ដូចជាផ្នែកទី 22-24 នៃច្បាប់នេះ

[7] ក្រុមហ៊ុនបុត្រសម្ព័ន្ធនៅក្នុងប្រទេសអាល្លឺម៉ង់ និងបរទេស គឺជាផ្នែកមួយនៃអាជីវកម្មដ្ឋានរបស់ក្រុមហ៊ុនមេប្រសិនបើក្រុមហ៊ុនមេប្រើប្រាស់ឥទ្ធិពលជាប់ខាតទៅលើក្រុមហ៊ុនគ្រុប (ផ្នែកទី 2 ខ 6 ប្រយោគទី 3 នៃច្បាប់នេះ)។

[8] ផ្នែកទី 4 ខ 4 នៃច្បាប់នេះ។

(សូមមើលបទបង្ហាញនៃលក្ខខណ្ឌតម្រូវផ្នែកច្បាប់នៅក្នុងជំពូករងខាងក្រោម)៖

- ការវិភាគហានិភ័យ[9]
- វិធានការទប់ស្កាត់
- វិធានការតម្រូវ
- និតិវិធីសារទុក្ខ[10]

ទោះបីជាសហគ្រាសដែលស្ថិតនៅក្រៅវិសាលភាពនៃច្បាប់នេះមិនមានកាតព្វកិច្ចក្នុងកិច្ចសហការពាក់ព័ន្ធនឹងការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកសិទ្ធិមនុស្ស និងបរិស្ថាន បច្ចុប្បន្នមានសហគ្រាសជាច្រើន រួចមកហើយដែលបានទាក់ទងទៅអ្នកផ្គត់ផ្គង់របស់ខ្លួនដើម្បីទាមទារ និងសុំព័ត៌មាន។ ការបដិសេធ ក្នុងកិច្ចសហការអាចមានផលប៉ះពាល់អវិជ្ជមានទៅលើទំនាក់ទំនងពាណិជ្ជកម្មជាមួយនឹងសហគ្រាស ជាប់កាតព្វកិច្ច ហើយថែមទាំងអាចបណ្តាលឱ្យមានផលវិបាកដល់ទំនាក់ទំនងកិច្ចសន្យាដែលអាចមានទាំងការបញ្ចប់កិច្ចសន្យាផងដែរ។[11]

## 1. ឥទ្ធិពលនៃច្បាប់ស្តីពីសហគ្រាសមិនជាប់កាតព្វកិច្ច

ដើម្បីធ្វើការវិភាគហានិភ័យផ្ទាល់ខ្លួន សហគ្រាសជាប់កាតព្វកិច្ចត្រូវការព័ត៌មានផ្ទៃក្នុង និងខាងក្រៅពីអ្នកផ្គត់ផ្គង់ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ពួកគេនៅក្នុងតំបន់អាជីវកម្មរបស់ខ្លួន។ ការងារនេះត្រូវ អនុវត្តចំពោះអ្នកផ្គត់ផ្គង់ និងក្រុមហ៊ុនបុត្រសម្ព័ន្ធនានាដែលជាផ្នែកមួយនៃអាជីវកម្មរបស់សហគ្រាស ទាំងក្នុង និងក្រៅវិសាលភាពនៃច្បាប់។ ហេតុនេះ សហគ្រាសជាប់កាតព្វកិច្ចត្រូវងាកទៅរកអ្នកផ្គត់ផ្គង់របស់ខ្លួនជាមួយនឹងកម្រងសំណួរវាយតម្លៃខ្លួនឯងបែបទូលំទូលាយ កម្មវិធីចុះឈ្មោះ (demand registration in tools) សម្រាប់គ្រប់គ្រងអ្នកផ្គត់ផ្គង់ ឬការចុះត្រួតពិនិត្យ ឬសវនកម្មនៅទីតាំងដែលតម្រូវ។ នៅក្នុងករណីមួយចំនួនតម្រូវការទាំងនេះ (ឧ. តម្រូវឱ្យអ្នកផ្គត់ផ្គង់បញ្ជូនបន្តនូវព័ត៌មានពាក់ព័ន្ធទាំងអស់នៅពេលមាន ការស្នើសុំ) គឺមានលក្ខណៈទូលំទូលាយពេក។

សហគ្រាសជាប់កាតព្វកិច្ចត្រូវធ្វើការវិភាគហានិភ័យដែលចាំបាច់ក្នុងករណីដែលហៅថា "មានចំណេះ ដឹងជាក់ស្តែង"[12] ឬក្នុងករណីមានការផ្លាស់ប្តូរសំខាន់ៗទៅលើសកម្មភាពអាជីវកម្ម ឬស្ថានភាពហានិភ័យ[13] ទាក់ទងទៅនឹងអ្នកផ្គត់ផ្គង់ប្រយោលដែលជាអ្នកផ្គត់ផ្គង់របស់អ្នកផ្គត់ផ្គង់របស់ខ្លួន។ ហេតុនេះ ជាធម្មតាពួកគេត្រូវការព័ត៌មានពីអ្នកផ្គត់ផ្គង់ផ្ទាល់របស់ខ្លួនមិនត្រឹមតែពាក់ព័ន្ធទៅនឹង ប្រតិបត្តិការរបស់អ្នកផ្គត់ផ្គង់ប៉ុណ្ណោះទេប៉ុន្តែពីអ្នកផ្គត់ផ្គង់របស់អ្នកផ្គត់ផ្គង់ផងដែរ។

[9] គោលការណ៍ណែនាំរបស់ BAFA ស្តីពីការវិភាគហានិភ័យបានផ្តល់ការពន្យល់ និងការណែនាំបន្ថែមស្តីពីការអនុវត្តជាក់ស្តែង៖ https://www.bafa.de/EN/Supply_Chain_Act/Risk_Analysis/risk_analysis_node.html

[10] គោលការណ៍ណែនាំរបស់ BAFA ស្តីពីនីតិវិធីសារទុក្ខបានផ្តល់ការពន្យល់ និងការណែនាំបន្ថែមស្តីពីការអនុវត្តជាក់ស្តែង៖ https://www.bafa.de/EN/Supply_Chain_Act/Complaints_Procedure/complaints_procedure_node.html

[11] ការគំរាមកំហែងក្នុងការបញ្ចប់កិច្ចសហការនៅក្នុងខនៃកិច្ចសន្យាអាចត្រូវទុកជាមោឃៈរួចមកហើយស្ថិតក្រោមខចែង និងលក្ខខណ្ឌទូទៅនៃច្បាប់។

[12] ផ្នែក 9 § 3 នៃច្បាប់នេះ ការពន្យល់បន្ថែមស្តីពីចំណេះដឹងជាក់ស្តែង ត្រូវបានផ្តល់ជូន ក្នុងចំណោមកត្តាផ្សេងទៀត ដោយ BMAS នៅក្នុង FAQ របស់ខ្លួន៖ https://www.csr-in-deutschland.de/EN/Business-Human-Rights/Supply-Chain-Act/FAQ/faq.html

[13] ផ្នែក 5 § 4 នៃច្បាប់នេះ

### ប្រអប់ព័ត៌មានទី1៖ តើ "ចំណេះដឹងជាក់ស្តែង" មានន័យដូចម្តេចនៅក្នុងបរិបទនៃច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវ?

ប្រសិនបើសហគ្រាសមានភស្តុតាងជាក់ស្តែងដែលបង្ហាញអំពីការរំលោភកាតព្វកិច្ចពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ឬពាក់ព័ន្ធនឹងបរិស្ថានដែលអាចកើតឡើងរបស់អ្នកផ្គត់ផ្គង់ប្រយោលសហគ្រាសត្រូវធ្វើការវិភាគ ពិសេសភ្លាមៗ។ ភស្តុតាងជាក់ស្តែងបែបនេះមិនមែនគ្រាន់តែជាមតិយោបល់ ឬពាក្យចចាមអារ៉ាម នោះទេ តែយ៉ាងហោចណាស់វាមានគោលនៃការពិតដែលអាចផ្ទៀងផ្ទាត់បាន។ ដែលរួមមានការ យល់ដឹងផ្ទាល់ខ្លួន របាយការស្តីពីស្ថានភាពសិទ្ធិមនុស្សដែលមិនល្អនៅក្នុងតំបន់ផលិតកម្ម ការពិត ដែលថាអ្នកផ្គត់ផ្គង់ស្ថិតនៅក្នុងវិស័យដែលមានហានិភ័យបរិស្ថាន ឬសិទ្ធិមនុស្សជាក់លាក់ ឬមានភស្តុតាងពីអាជ្ញាធរ។

វាជាការគ្រប់គ្រាន់នៅពេលដែលមានភស្តុតាង។ ឧ. ថាពួកគេបានចូលទៅក្នុងដែននៃការគ្រប់គ្រង របស់សហគ្រាសជាប់កាតព្វកិច្ច ដូចនេះពួកគេអាចកត់សម្គាល់វាបានដោយងាយ។ នេះគឺជា ឧទាហរណ៍អំពីករណីដែលមាន

- ព័ត៌មានតាមរយៈនីតិវិធីបណ្តឹង
- គោលការណ៍ណែនាំរបស់ BAFA និងរបាយការណ៍ពីរដ្ឋាភិបាលសហព័ន្ធ ដែលថាសហគ្រាស ត្រូវបានរំពឹងទុកឱ្យកត់ចំណាំទៅលើ ឧ. តាមរយៈមន្ត្រីសិទ្ធិមនុស្សរបស់ខ្លួន
- របាយការណ៍ប្រព័ន្ធផ្សព្វផ្សាយ របាយការណ៍ពីអង្គការក្រៅរដ្ឋាភិបាល (NGO) និងរបាយការណ៍នៅលើអ៊ីនធឺណិត ប្រសិនបើវាច្បាស់លាស់ ព្រោះពួកវាត្រូវបានគេស្គាល់នៅគ្រប់វិស័យ ឬវាត្រូវបានគេដាក់ជូនទៅកាន់សហគ្រាស។[14]

ក្នុងករណីនៃគោលការណ៍ណែនាំ បញ្ជីករណី និងមូលដ្ឋានទិន្នន័យនៃភាគីពាក់ព័ន្ធចម្រុះ ឬគំនិត ផ្តួចផ្តើមវិស័យ ចំណេះដឹងជាក់លាក់នៅក្នុងអត្ថន័យនៃផ្នែក ៩(3) ទំនងជាត្រូវបានសន្មត់ប្រសិនបើ ព័ត៌មានត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយទៅគ្រប់វិស័យ។

សហគ្រាសមិនជាប់កាតព្វកិច្ចអាច ប្រមើលមើលទុកមុនថាសហគ្រាសជាប់កាតព្វកិច្ចនឹងត្រូវប្រើប្រាស់ កិច្ចខិតខំប្រឹងប្រែងជាក់លាក់មួយចំនួនសម្រាប់ការវិភាគហានិភ័យរបស់ខ្លួន និងរកមើលថាវត្ថុធាតុ ដើមផលិតផល និងសេវាកម្មណាខ្លះដែលប្រឈមនិងហានិភ័យជាពិសេស។ ដូចនេះ បន្ថែមពីលើការ ផលិត ការជ្រើលទូកម្ម និងការកែ ច្នៃវត្ថុធាតុដើម និងផលិតផលពាក់កណ្តាលសម្រេច ការដឹកជញ្ជូនរបស់ខ្លួន និងការបោះចោលវត្ថុ ធាតុដើមក៏ដូចជាផលិតផលពីដំណើរការផលិតក៏ដើរតួនាទីសំខាន់ ក្នុងការវិភាគផងដែរ។ ទាក់ទងនឹងការកំណត់អត្តសញ្ញាណហានិភ័យ និងការរំលោភមួយចំនួនទាមទារ ឱ្យមានការយល់ដឹងពី បច្ចេកទេសនៃដំណើរការផលិតផងដែរ។

## 2. វិធានការទប់ស្កាត់

នៅពេលដែលសហគ្រាសជាប់កាតព្វកិច្ចព្យាយាមអនុវត្តវិធានការទប់ស្កាត់ចំពោះអ្នកផ្គត់ផ្គង់ផ្ទាល់របស់ខ្លួន សហគ្រាសជាប់កាតព្វកិច្ចព្យាយាមធ្វើវាតាមរយៈការចាត់វិធានការដែលស្របគ្នាឬជាក់ចេញនូវបទប្បញ្ញត្តិ ជាពិសេស នៅក្នុងក្របខណ្ឌនៃទំនាក់ទំនងពាណិជ្ជកម្មបែបកិច្ចសន្យាដែលមានស្រាប់ ជាមួយនឹងឧកិច្ចសន្យា ឬ ក្រមប្រតិបត្តិបន្ថែម។ ច្បាប់នេះបានផ្តល់នូវវិធានការទប់ស្កាត់ដូចខាងក្រោមជាឧទាហរណ៍៖

[14] ព័ត៌មានបន្ថែមស្តីពីកម្រិតលទ្ធភាពនៃចំណេះដឹងជាក់ស្តែងអាចរកមើលបាននៅក្នុងជំពូក VI នៃ FAQ ក្នុងគេហទំព័ររបស់ BAFA (ជាភាសាអាឡឺម៉ង់)

- ពិចារណាពីការរំពឹងទុកពាក់ព័ន្ធនឹងបរិស្ថាននិងសិទ្ធិមនុស្សនៅពេលធ្វើការជ្រើសរើសអ្នកផ្គត់ផ្គង់។
- ការធានាបែបកិច្ចសន្យាពីអ្នកផ្គត់ផ្គង់ថាពួកគេនឹងអនុលោមតាមការរំពឹងទុកពាក់ព័ន្ធនឹងបរិស្ថាន និងសិទ្ធិមនុស្ស ដែលតម្រូវដោយអ្នកគ្រប់គ្រងជាន់ខ្ពស់របស់សហគ្រាស និងដោះស្រាយវាឱ្យបានសមស្របតាមបណ្តោយខ្សែចង្វាក់ផ្គត់ផ្គង់។
- ការអនុវត្តវិធានការបណ្តុះបណ្តាលបឋម និងបន្តដើម្បីអនុវត្តការធានាបែបកិច្ចសន្យាដែលធ្វើឡើងដោយអ្នកផ្គត់ផ្គង់។
- ការព្រមព្រៀងទៅលើយន្តការត្រួតពិនិត្យបែបកិច្ចសន្យាដែលសមស្រប និងការអនុវត្តដោយ ផ្អែកលើហានិភ័យ ដើម្បីផ្ទៀងផ្ទាត់អនុលោមភាពរបស់អ្នកផ្គត់ផ្គង់ទៅតាមយុទ្ធសាស្ត្រសិទ្ធិមនុស្ស។[15]

ក្រៅពីនេះ សហគ្រាសជាប់កាតព្វកិច្ចត្រូវបង្កើត និងអនុវត្តយុទ្ធសាស្ត្រលទ្ធកម្ម និងរបៀបអនុវត្តការទិញ ដើម្បីទប់ស្កាត់ ឬកាត់បន្ថយហានិភ័យដែលបានកំណត់ពាក់ព័ន្ធនឹងអ្នកផ្គត់ផ្គង់។ ឧទាហរណ៍រួមមានដូចជារយៈពេលដំណើរការ តម្លៃទិញ ឬរយៈពេលនៃទំនាក់ទំនងកិច្ចសន្យា។[16]

ពាក់ព័ន្ធនឹងអ្នកផ្គត់ផ្គង់ប្រយោល ក្នុងករណីមានចំណេះដឹងជាក់ស្តែងពីការរំលោភសិទ្ធិមនុស្ស ឬបរិស្ថាន ជាទូទៅ ច្បាប់នេះបានកំណត់វិធានការទប់ស្កាត់ដូចខាងក្រោមចំពោះភាគីដែលទទួលខុសត្រូវ៖

- ការអនុវត្តយន្តការត្រួតពិនិត្យ
- គាំទ្រការទប់ស្កាត់ ឬបញ្ចៀសហានិភ័យ
- ការអនុវត្តការផ្តួចផ្តើមទៅលើវិស័យជាក់លាក់ឬឆ្លងវិស័យដែលមានសហគ្រាសនោះចូលរួមចំណែក។[17]

សហគ្រាសជាប់កាតព្វកិច្ចជាច្រើនស្នើសុំឱ្យអ្នកផ្គត់ផ្គង់ចុះហត្ថលេខាទៅលើក្រមប្រតិបត្តិ (ឬក្រមប្រតិបត្តិ អ្នកផ្គត់ផ្គង់)។ CoC (ឬផ្នែកបន្ថែមទៅលើការព្រមព្រៀងបែបកិច្ចសន្យា) ជាទូទៅគ្រប់គ្រងទៅលើទាំងការ អនុលោមតាមការរំពឹងទុកផ្នែកសិទ្ធិមនុស្ស និងបរិស្ថាន និងកិច្ចសហការ ដើម្បីបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវរបស់សហគ្រាសជាប់កាតព្វកិច្ច (ផ្តល់ព័ត៌មានសម្រាប់ការវិភាគហានិភ័យល់ ព្រមឱ្យធ្វើសវនកម្ម និងការចុះពិនិត្យដល់កន្លែង កិច្ចសហការទៅលើវិធានការទប់ស្កាត់ និងកែប្រែ គាំទ្រក្នុងវិធានការដើម្បីឱ្យអាចចូលទៅប្រើប្រាស់នីតិវិធីបណ្តឹងបាន)។ បន្ថែមពីនេះជាទូទៅ សហគ្រាសជាប់កាតព្វកិច្ចមាននូវយន្តការត្រួតពិនិត្យ និងផលវិបាកដោយសារការមិនអនុលោមតាមលក្ខខណ្ឌ។[18]

## 3. វិធានការតម្រូវ

ទាក់ទងនឹងវិធានការតម្រូវ វាក៏អាចត្រូវបានរំពឹងទុកផងដែរថា សហគ្រាសជាប់កាតព្វកិច្ចនឹងស្វែងរកការ សហការពីអ្នកផ្គត់ផ្គង់របស់ខ្លួន។ សហគ្រាសជាប់កាតព្វកិច្ចមានកាតព្វកិច្ចទូលំទូលាយក្នុងដោះស្រាយកែតម្រូវនៅក្នុងទីតាំងអាជីវកម្មរបស់ខ្លួន៖ នៅក្នុងប្រទេសអាល្លឺម៉ង់ ពួកគេត្រូវបញ្ចប់ការរំលោភបំពានតាមរយៈវិធានការតម្រូវដែលស័ក្តិសម។ នៅបរទេសក៏ដូច

[15] ផ្នែកទី 6 ទ 4 នៃច្បាប់នេះ។

[16] សូមមើលផ្នែកទី 6 ទ 3 Nr.2 នៃច្បាប់នេះ ក៏ដូចជា អនុស្សរណៈពន្យល់របស់រដ្ឋាភិបាលនៅក្នុង BT-Drs. 19/9/28649, p. 47.

[17] សូមមើលផ្នែក ទី 9 ទ 3 លេខ២ នៃច្បាប់នេះ។

[18] សូមមើលជំពូក III នៃគោលការណ៍ណែនាំសម្រាប់ការបញ្ជាក់លម្អិតបន្ថែមអំពីភាពសមស្របនៃវិធីសាស្ត្រនេះ។

គ្នា នៅក្រុមហ៊ុនបុត្រសម្ព័ន្ធដែលជា (ចាត់ទុកថាជា) ផ្នែកមួយនៃអាជីវកម្មរបស់ខ្លួន[19] ការរំលោភបំពានត្រូវតែបញ្ចប់ជាទូទៅ។

ប្រសិនបើសហគ្រាសជាប់កាតព្វកិច្ចរកឃើញការរំលោភលើកាតព្វកិច្ចសិទ្ធិមនុស្ស ឬបរិស្ថានដែលបាន កើតឡើងរួចមក ហើយឬជិតនឹងកើតឡើងទៅអ្នកផ្គត់ផ្គង់របស់ខ្លួនពួកគេត្រូវអនុវត្តវិធានការតម្រូវសមស្របភ្លាមៗដើម្បីទប់ស្កាត់ បញ្ចប់ ឬ កាត់បន្ថយកម្រិតនៃការរំលោភបំពាន។[20] មានការរំលោភបំពាន ជាច្រើនដែលមិនអាចត្រូវបានបញ្ចប់ដោយវិធានការតែមួយ ដោយឯកឯងបានទេ ប៉ុន្តែវាតម្រូវឱ្យមានវិធាន ការសម្របសម្រួលច្រើនទៀត។ ប្រសិនបើការរំលោភបំពានរបស់អ្នកផ្គត់ផ្គង់ មិនអាចបញ្ចប់បាននៅពេលដ៏ខ្លីខាងមុខ ច្បាប់នេះតម្រូវឱ្យមានគោលគំនិតសម្រាប់បញ្ចប់ ឬកាត់បន្ថយ ពោលគឺ សហគ្រាស ជាប់កាតព្វកិច្ច និងអ្នកផ្គត់ផ្គង់ត្រូវរៀបចំ និងអនុវត្តផែនការសកម្មភាពកែប្រែរួមគ្នា។[21]

សហគ្រាសជាប់កាតព្វកិច្ចក៏ត្រូវរៀបចំ និងអនុវត្តផែនការសកម្មភាពកែប្រែដើម្បីទប់ស្កាត់ និងបញ្ចប់ ឬកាត់បន្ថយតាមការចំបាច់ប្រសិនបើខ្លួនបានដឹងច្បាស់ពីការរំលោភបំពានលើកាតព្វកិច្ចសិទ្ធិ មនុស្ស ឬបរិស្ថានរបស់អ្នកផ្គត់ផ្គង់ប្រយោលរបស់ខ្លួន។[22]

សហគ្រាសជាប់កាតព្វកិច្ចពឹងផ្អែកទៅលើជំនួយរបស់អ្នកផ្គត់ផ្គង់ផ្ទាល់ និងប្រយោលរបស់ខ្លួនដើម្បីអនុវត្តវិធានការតម្រូវ ពីព្រោះពួកគេមិនអាចធ្វើកិច្ចការនេះបានដោយគ្មានការយល់ព្រមពីអ្នកផ្គត់ផ្គង់ឡើយ។ ដើម្បីអាចអនុវត្តវិធានការចំពោះអ្នកផ្គត់ផ្គង់ប្រយោលបាន ជាទូទៅ សហគ្រាសជាប់កាតព្វកិច្ចត្រូវការឱ្យមានការទំនាក់ទំនងផ្ទាល់រវាងអ្នកផ្គត់ផ្គង់ផ្ទាល់និងទៅអ្នកផ្គត់ផ្គង់ប្រយោល។ ស្រដៀងគ្នានេះ សហគ្រាសមិនជាប់កាតព្វកិច្ចអាចពឹងផ្អែកលើការគាំទ្ររបស់សហគ្រាសជាប់កាតព្វកិច្ច។

## 4. នីតិវិធីបណ្តឹង

សហគ្រាសជាប់កាតព្វកិច្ចទាំងអស់ត្រូវអនុវត្តនីតិវិធីបណ្តឹងដែលអាចឱ្យបុគ្គលខាងក្នុង និងខាងក្រៅ ជូនដំណឹងដល់ក្រុមហ៊ុនអំពីហានិភ័យសិទ្ធិមនុស្ស និងបរិស្ថាន ឬការរំលោភបំពាននៅទីតាំងអាជីវកម្ម ឬខ្សែចង្វាក់ផ្គត់ផ្គត់របស់ខ្លួន។ នីតិវិធីបណ្តឹងដើរតួនាទីជាប្រព័ន្ធផ្តល់ព័ត៌មានជាមុនដែលកំណត់ និង ល្អប្រសើរក្នុងការដោះស្រាយហានិភ័យ និងការរំលោភបំពានមុនពេលដែលមនុស្ស និងបរិស្ថានទទួលរងគ្រោះថ្នាក់។

ដើម្បីអនុវត្តនីតិវិធីបណ្តឹងដែលសមស្រប និងមានប្រសិទ្ធភាព សហគ្រាសជាប់កាតព្វកិច្ចត្រូវពឹងផ្អែក លើការផ្លាស់ប្តូរ និងកិច្ចសហការនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់។ សហគ្រាសជាប់កាតព្វកិច្ចត្រូវអនុវត្ត មិនថាតែនីតិវិធីបណ្តឹង សមស្របរបស់ខ្លួន ឬបង្កើត ឬចូលរួមជាមួយនីតិវិធីខាងក្រៅឡើយ។ នីតិវិធីត្រូវតែអាចប្រើប្រាស់បានសម្រាប់ ភាគីសក្តានុពលដែលពាក់ព័ន្ធ ដែលរួមទាំងបុគ្គលិកនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ផងដែរ។[23] ក្នុងគោល បំណងនេះ សហគ្រាសជាប់កាតព្វកិច្ចត្រូវផ្តល់នូវព័ត៌មានដែលច្បាស់ និងងាយយល់ទាក់ទងនឹងការចូល ទៅប្រើប្រាស់ និងការទទួលខុសត្រូវ ក៏ដូចជាដំណាក់កាលនីមួយៗនៃនីតិ

[19] សូមមើលលេខយោងទី 17

[20] ផ្នែកទី 7 ទ 1 នៃច្បាប់នេះ។

[21] ផ្នែកទី 7 ទ 2 នៃច្បាប់នេះ។

[22] ផ្នែកទី 9 ទ 3 លេខ3 នៃច្បាប់នេះ។

[23] ពាក្យនេះរួមបញ្ចូលបានទាំងអ្នកដែល (អាច) រងផលប៉ះពាល់ផ្ទាល់ដោយការរំលោភបំពានលើកាតព្វកិច្ច និងអ្នកផ្សេងទៀតដែលមិនរងផលប៉ះពាល់ដោយផ្ទាល់ (ឧ. សាច់ញាតិ អ្នកជិតខាង)។

វិធី។ នីតិវិធីបណ្តឹងក៏ត្រូវតែ ការពារព័ត៌មានសម្ងាត់នៃអត្តសញ្ញាណនៃភាគីសក្តានុពល និងផ្តល់នូវការការពារប្រកបដោយប្រសិទ្ធ ភាពពីផលវិបាក ឬការពិន័យដោយសារតែការសារទុក្ខ។[24]

សហគ្រាសជាប់កាតព្វកិច្ចជាទូទៅខ្វះខាតព័ត៌មានអំពីភាគីសក្តានុពលក្នុងស្រុកដើម្បីរៀបចំគោលគំនិត តម្រង់ទិសនៃនីតិវិធីបណ្តឹងដល់ក្រុមគោលដៅ។ ព័ត៌មាននេះប្រហែលជាត្រូវការរួចមកហើយនៅពេល ដែលសហគ្រាសជាប់កាតព្វកិច្ចរៀបចំបង្កើតនីតិវិធីបណ្តឹង ព្រោះពួកគេអាចរៀបចំបានតែនីតិវិធីបណ្តឹងដែលអាចចូលទៅប្រើប្រាស់បានដោយក្រុមគោលដៅដែលមានចំណេះដឹងនៃក្រុមនេះ និងស្ថានភាពជាក់លាក់នៃរបស់ពួកគេតែប៉ុណ្ណោះ។[25] សហគ្រាសជាប់កាតព្វកិច្ចអាចនឹងស្នើសុំបន្ថែមឱ្យអ្នកផ្គត់ផ្គង់ជួយក្នុងការធ្វើឱ្យនីតិវិធីបណ្តឹងរបស់ខ្លួនអាចទទួលបានដោយការទទួល និងបញ្ជូនបន្តបណ្តឹងទៅកាន់ពួកគេ។

## III. ព្រំដែននៅលើការប្រើប្រាស់អ្នកផ្គត់ផ្គង់របស់សហគ្រាសជាប់កាតព្វកិច្ច

កាតព្វកិច្ចផ្លូវច្បាប់នៃច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវនេះ អនុវត្តទៅលើតែសហគ្រាសដែលស្ថិតក្នុងវិសាលភាពច្បាប់តែប៉ុណ្ណោះ។ ទោះបីជានៅពេលដែលច្បាប់នេះតម្រូវឱ្យសហគ្រាសជាប់កាតព្វកិច្ច និងមិនជាប់ កាតព្វកិច្ច សហការដើម្បីបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវក្តី ច្បាប់នេះបានកំណត់តែលក្ខខណ្ឌ តម្រូវទាក់ទងនឹងកាតព្វកិច្ចរបស់សហគ្រាសជាប់កាតព្វកិច្ចតែប៉ុណ្ណោះ។ ជាពិសេស លក្ខណៈនៃកាតព្វកិច្ច ត្រួតពិនិត្យភាពត្រឹមត្រូវមិនអនុញ្ញាតឱ្យមានការផ្ទេរកាតព្វកិច្ចទាំងនេះជាទូទៅទេ។ BAFA នឹងពិចារណា គោលការណ៍នេះនៅក្នុងបរិបទនៃកិច្ចការគ្រប់គ្រង និងដាក់ឱ្យអនុវត្តរបស់ខ្លួន។

### 1. គោលការណ៍នៃភាពសមស្រប និងប្រសិទ្ធភាព

កាតព្វកិច្ចនៃច្បាប់នេះសំដៅទៅលើ **គោលការណ៍នៃភាពសមស្រប និងប្រសិទ្ធភាព** ដែលមានទំនាក់ ទំនងគ្នាយ៉ាងជិតស្និទ។ សហគ្រាសជាប់កាតព្វកិច្ច ត្រូវគោរពកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់របស់ខ្លួន តាមរបៀបសមស្រប (សម្រាប់ពួកគេ) ដើម្បីទប់ស្កាត់ ឬកាត់បន្ថយហានិភ័យសិទ្ធិមនុស្ស និងបរិស្ថាន និងបង្ការ បញ្ចប់[26] ឬកាត់បន្ថយកម្រិតនៃការរំលោភបំពានលើសិទ្ធិមនុស្ស និងបរិស្ថាន។[27] ការជ្រើសរើសវិធានការដែលសមស្របគឺត្រូវបានអនុញ្ញាតចំពោះតែវិធានការ ដែលមានប្រសិទ្ធភាពតែប៉ុណ្ណោះ។ គោលការណ៍នៃភាពសមស្រប និងប្រសិទ្ធភាពជួយឱ្យសហគ្រាសជាប់កាតព្វកិច្ចអនុវត្ត**វិធីសាស្ត្រផ្អែកលើហានិភ័យ** និងក្នុងពេលជាមួយគ្នាដាក់កម្រិតទៅលើការផ្ទេរកាតព្វកិច្ច ច្បាប់ទៅឱ្យអ្នកផ្គត់ផ្គង់។

[24] ផ្នែកទី 8 ទ 4 នៃច្បាប់នេះ។

[25] សូមមើល BAFA-គោលការណ៍ណែនាំស្តីពីនីតិវិធីសារទុក្ខ p.11.

[26] ផ្នែកទី 3 ទ 1 និង 4 ទ 2 នៃច្បាប់នេះ។

[27] ផ្នែកទី 7 ទ 1 ប្រយោគទី 1 និង ផ្នែកទី 9 ទ 3 លេខ 3 នៃច្បាប់នេះ។

## ប្រអប់ព័ត៌មានទី2៖ លក្ខខណ្ឌវិនិច្ឆ័យភាពសមស្របនៃច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវ

ភាពសមស្របត្រូវបានកំណត់ដោយលក្ខខណ្ឌខាងក្រោម៖

- លក្ខណៈ និងទំហំនៃសកម្មភាពរបស់សហគ្រាសជាប់កាតព្វកិច្ច
- លទ្ធភាពរបស់សហគ្រាសជាប់កាតព្វកិច្ចក្នុងការបញ្ចុះបញ្ចូលភាគីដែលទទួលខុសត្រូវផ្ទាល់ទៅលើហានិភ័យសិទ្ធិមនុស្ស ឬបរិស្ថាន ឬការរំលោភបំពានទៅលើកាតព្វកិច្ចសិទ្ធិមនុស្ស ឬបរិស្ថាន
- ភាពធ្ងន់ធ្ងរនៃការរំលោភបំពានដែលបានរំពឹងទុកជាទូទៅ ផលបញ្ច្រាសរបស់វា និងលទ្ធភាពនៃការរំលោភលើកាតព្វកិច្ចពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងបរិស្ថាន និង
- លក្ខណៈនៃការចូលរួមចំណែករបស់សហគ្រាសជាប់កាតព្វកិច្ចទៅក្នុងហានិភ័យសិទ្ធិមនុស្ស ឬបរិស្ថាន ឬការរំលោភលើកាតព្វកិច្ចពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ឬបរិស្ថាន។[28]

លក្ខខណ្ឌវិនិច្ឆ័យភាពសមស្របមិនមានទីតាំងតាមឋានានុក្រមជាក់លាក់ពីមួយទៅមួយទេប៉ុន្តែត្រូវតែពិចារណាឱ្យបានស្មើភាពគ្នា។ ដូចនេះ វានឹងត្រូវបានកាត់បន្ថយ ឧទាហរណ៍ ធ្វើការវាយតម្លៃហានិភ័យ ទៅលើ តែមូលដ្ឋាននៃលទ្ធភាពរបស់ខ្លួនក្នុងការបញ្ចុះបញ្ចូល និងដើម្បីសរុបថាហានិភ័យនោះ មិនចាំបាច់ត្រូវតាម រកតាំងពីដំបូងទេប្រសិនបើមានឥទ្ធិពលតិចតួច ឬគ្មាន។ ភាពសមស្របក៏មានន័យផងដែរថាលក្ខខណ្ឌ តម្រូវទៅលើទំហំ និងកម្រិតនៃការវិភាគ និងសកម្មភាពគឺខុសគ្នាទៅតាមករណីនីមួយៗ។ ជាទូទៅ វាក៏អាច មានន័យថាភាពសមស្របក្នុងការធ្វើសកម្មភាពតាមវិធីដែលអនុលោមទៅលើលក្ខខណ្ឌតម្រូវនៃការត្រួត ពិនិត្យភាពត្រឹមត្រូវនឹងត្រូវបានវាយតម្លៃផ្សេងៗគ្នា នៅក្នុងសហគ្រាសផ្សេងៗគ្នានៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់។ ការធានារបស់អ្នកផ្គត់ផ្គង់ថាបានបំពេញតាមស្តង់ដារនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ទាំងមូល ជាទូទៅ មិនមែនជាការចូលរួមចំណែកដែលសមស្រប និងមានប្រសិទ្ធភាពទៅលើការគ្រប់គ្រងហានិភ័យរបស់សហ គ្រាសជាប់កាតព្វកិច្ចនោះទេ។

**វិធានការមានប្រសិទ្ធភាព**[29] ដែលអាចជួយឱ្យសហគ្រាសជាប់កាតព្វកិច្ចកំណត់ និងកាត់បន្ថយហានិភ័យ សិទ្ធិមនុស្ស និងបរិស្ថាន និងបង្ការ បញ្ចប់ ឬកាត់បន្ថយកម្រិតនៃការរំលោភបំពានសិទ្ធិមនុស្ស និងបរិស្ថាន ប្រសិនបើសហគ្រាសជាប់កាតព្វកិច្ចបានធ្វើឱ្យមាន ឬចូលរួមចំណែកក្នុងហានិភ័យ ឬការរំលោភបំពាន នៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់។[30] នេះមានន័យថា សហគ្រាសត្រូវវិភាគស្ថានភាពជាក់លាក់ឱ្យបានលម្អិត និងអនុវត្តវិធីសាស្រ្តផ្អែកលើហានិភ័យ។[31]

សហគ្រាសជាប់កាតព្វកិច្ច ត្រូវពិចារណាពី**សមត្ថភាព**របស់អ្នកផ្គត់ផ្គង់របស់ខ្លួន ដើម្បីធ្វើការវាយតម្លៃប្រសិទ្ធភាពនៃវិធានការ។ វិធានការរបស់សហគ្រាសជាប់កាតព្វកិច្ចដែលមើលឃើញថាមានការទាមទារ ច្រើនពេក (ឧ. ព្រោះពួកគេខ្វះធនធានហិរញ្ញវត្ថុដែលចាំបាច់) សម្រាប់អ្នកផ្គត់ផ្គង់ ជាធម្មតាមិនមាន ប្រសិទ្ធភាព និងសមស្របទេ។ សមត្ថភាពរបស់អ្នកផ្គត់ផ្គង់អាស្រ័យជាពិសេសលើធនធាន ទំហំ វិស័យ និងជំហររបស់អ្នកផ្គត់ផ្គង់នៅក្នុង ខ្សែចង្វាក់ផ្គត់ផ្គង់ ក៏ដូចជាលក្ខខណ្ឌ

[28] ផ្នែកទី 3 § 2 នៃច្បាប់នេះ។

[29] ផ្នែកទី 4 § 2 នៃច្បាប់នេះ។

[30] ការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាពតម្រូវឱ្យមានការពិចារណាយ៉ាងត្រឹមត្រូវទៅលើអត្ថប្រយោជន៍បុគ្គលិកដែលរួមបញ្ចូល ទាំងសហជីព និងបុគ្គលនានាដូចជាអ្នកជិតខាងដែលអាចរងផលប៉ះពាល់ដោយសកម្មភាពអាជីវកម្មរបស់សហគ្រាស។ សូមមើលផ្នែក 4 § 4 នៃច្បាប់នេះ ក៏ដូចជាអនុស្សារណៈពន្យល់របស់រដ្ឋាភិបាលនៅក្នុង៖ BT-Drs. 19/28649, p.44

[31] សម្រាប់ព័ត៌មានបន្ថែមសូមមើល គោលការណ៍ណែនាំរបស់ BAFA ការវិភាគហានិភ័យ

ក្នុងតំបន់ជាក់លាក់។[32]

## 2. ព្រំដែនសម្រាប់ការផ្ទេរភាពតព្វកិច្ចពីច្បាប់ទៅអ្នកផ្គត់ផ្គង់

នៅក្នុងការអនុវត្ត សហគ្រាសជាប់កាតព្វកិច្ចមួយចំនួនព្យាយាមស្វែងរកការធានាជាលាយលក្ខណ៍អក្សរពី អ្នកផ្គត់ផ្គង់ថា ខ្លួនបានអនុលោមតាមស្តង់ដារសិទ្ធិមនុស្ស និងបរិស្ថាន និងនីតិវិធីត្រួតពិនិត្យភាពត្រឹមត្រូវដែលពាក់ព័ន្ធនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់របស់ខ្លួន។ នៅក្នុងករណីមួយចំនួន ពួកគេថែមទាំងចង់បានការធានាបែបគ្របដណ្តប់ ( Blanket Assurance ) ដែលថាអ្នកផ្គត់ផ្គង់បានអនុលោមទៅតាមច្បាប់នេះផងដែរ។

[32] សូមមើលផងដែរនូវឧទាហរណ៍អវិជ្ជមានទី 2 សម្រាប់ការពន្យល់

ឧទាហរណ៍អវិជ្ជមានទី 1

**ដកស្រង់ចេញពីក្រមប្រតិបត្តិរបស់អ្នកផ្គត់ផ្គត់ (មិនសមស្រប) រវាងសហគ្រាសជាប់កាតព្វកិច្ច A និង សហគ្រាសមិនជាប់កាតព្វកិច្ច B។**

*គូភាគីទាំងពីរបានបញ្ចប់កិច្ចសន្យាខាងក្រោមធៀបទៅនឹងសារតារនៃកាតព្វកិច្ចរបស់សហគ្រាស A ស្ថិតក្រោមច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវរបស់អាឡឺម៉ង់។ អ្នកផ្គត់ផ្គង់ មានកាតព្វកិច្ចផ្ទាល់តែក្នុងការអនុលោមទៅនឹងច្បាប់នេះប៉ុណ្ណោះប្រសិនបើច្បាប់នេះប្រើប្រាស់យោងទៅតាមបទប្បញ្ញត្តិរបស់ខ្លួន។*

*ទ 1 កាតព្វកិច្ច*

*អ្នកផ្គត់ផ្គង់ប្តេជ្ញាចិត្តក្នុងការគោរពសិទ្ធិមនុស្ស និងការការពារបរិស្ថានប្រកបដោយនិរន្តរភាព។ អ្នកផ្គត់ផ្គត់ត្រូវរ៉ាប់រងក្នុងការអនុលោមតាមការហាមឃាត់ដូចខាងក្រោម៖*

- *ការហាមឃាត់ការជួលបុគ្គលិកជាកម្លាំងពលកម្មដោយបង្ខំ*
- *ការហាមឃាត់គ្រប់ទម្រង់នៃទាសភាព ឬការអនុវត្តស្រដៀងទៅនឹង ទាសភាព*
- *ការហាមឃាត់ចំពោះការមិនយកចិត្តទុកដាក់លើកាតព្វកិច្ចសុខភាព និងសុវត្ថិភាពការងារជាធរមានស្ថិតក្រោមច្បាប់នៃកន្លែងធ្វើការ*
- *ការហាមឃាត់ការបង្កឱ្យមានការផ្លាស់ប្តូរដីដែលមានគ្រោះថ្នាក់ ការបំពុលទឹក ការបំពុលខ្យល់ ការបញ្ចេញសម្លេងរំខានដែល គ្រោះថ្នាក់ ឬការប្រើប្រាស់ទឹកច្រើនហួសហេតុ*
- *(…)*

*ទ 2 វិធានការ*

*(1) អ្នកផ្គត់ផ្គង់ទទួលខុសត្រូវក្នុងការអនុវត្តវិធានការដើម្បីទប់ស្កាត់ និងកាត់បន្ថយហានិភ័យក្នុងការបំពេញកាតព្វកិច្ចស្របតាម ទ 1 នៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់។*

*(2) អ្នកផ្គត់ផ្គង់ត្រូវធ្វើការវាយតម្លៃស្ថិតក្នុងក្របខណ្ឌនៃការវិភាគហានិភ័យថាតើហានិភ័យជាក់លាក់សម្រាប់ ទ 1 កើតមានដែរ ឬទេ។*

*(3) នៅពេលហានិភ័យត្រូវបានកំណត់ អ្នកផ្គត់ផ្គង់មានកាតព្វកិច្ចក្នុងការអនុវត្ត វិធានការទប់ស្កាត់ជាក់ លាក់ដើម្បីទប់ស្កាត់ ឬកាត់បន្ថយហានិភ័យទាំងនេះ។*

*(4) អ្នកផ្គត់ផ្គងមានកាតព្វកិច្ចក្នុងការអនុវត្តវិធានការតម្រូវភ្លាមៗនៅពេលធ្វើការកំណត់ការរំលោភបំពានលើកាតព្វកិច្ចសិទ្ធិមនុស្ស ឬបរិស្ថាន។*

*(5) អ្នកផ្គត់ផ្គង់មានកាតព្វកិច្ចក្នុងការអនុវត្តវិធានការបណ្តឹងដែលជួយឱ្យភាគីទីបីអាចរាយការណ៍អំពីករណីរំលោភបំពានលើបទប្បញ្ញត្តិដែលបានរៀបរាប់ខាងលើ*

*(6) សហគ្រាស A រក្សាសិទ្ធិក្នុងការស្នើ ឬកំណត់វិធានការជាក់លាក់ប្រសិនបើ វិធានការទាំងនោះពាក់ព័ន្ធនឹងកាតព្វកិច្ចស្ថិតក្រោម ទ 1។*

*(…)*

***កិច្ចសន្យាបែបគ្របដណ្តប់នេះមិនអនុលោមទៅនឹងលក្ខខណ្ឌតម្រូវនៃច្បាប់នេះទេ ហើយអាចនឹងតម្រូវឱ្យមានការត្រួតពិនិត្យទៅលើសហគ្រាជាប់កាតព្វកិច្ចពីសំណាក់ BAFA។***

សហគ្រាសជាប់កាតព្វកិច្ចត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនក្នុងការបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវនៅក្នុងអាជីវកម្មដ្ឋានរបស់ខ្លួន និងពាក់ព័ន្ធនឹងអ្នកផ្គត់ផ្គង់ផ្ទាល់ និងប្រយោល[33]។ កាតព្វកិច្ចនៃច្បាប់នេះមិនអាចផ្ទេរទៅឱ្យអ្នកផ្គត់ផ្គង់បានឡើយ។

ចំណុចនេះមានអត្ថន័យលម្អិតដូចខាងក្រោម៖

- ផ្ទុយទៅនឹងសហគ្រាសជាប់កាតព្វកិច្ចសហគ្រាសក្រៅវិសាលភាព**មិនជាប់កាតព្វកិច្ចក្នុងការអនុវត្តដំណើរការដើម្បីបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវដូចរៀបរាប់ខាងលើទេ។** ដោយហេតុនេះ BAFA នឹងមិនអនុវត្តវិធានការជំរុញការអនុវត្ត ឬទណ្ឌកម្មទៅលើសហគ្រាសក្រៅវិសាលភាពឡើយ។

- **BAFA នឹងមិនអនុវត្តការត្រួតពិនិត្យផ្អែកលើហានិភ័យនៃសហគ្រាសមិនជាប់កាតព្វកិច្ចទេ។** យោង លើច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវ ការវាយតម្លៃនៃបណ្តឹងជាក់ស្តែងរបស់អ្នករងផលប៉ះពាល់អាចអនុវត្តបានសម្រាប់តែសហគ្រាសជាប់កាតព្វកិច្ចប៉ុណ្ណោះ។

- សហគ្រាសមិនជាប់កាតព្វកិច្ច**មិនតម្រូវឱ្យធ្វើការរាយការណ៍ និងទទួលខុសត្រូវចំពោះ BAFA ទេ។** សហគ្រាសមិនជាប់កាតព្វកិច្ចមិនចាំបាច់ផ្សព្វផ្សាយរបាយការណ៍ទាក់ទងនឹងការបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវរបស់ខ្លួន ឬដាក់របាយការណ៍ជូន BAFA ឡើយ។ លើសពីនេះ ពួកគេមិនតម្រូវឱ្យចូលរួមដោយ ផ្ទាល់នៅក្នុងការបង្កើតរបាយការណ៍ទាំងនេះរបស់សហគ្រាសជាប់កាតព្វកិច្ចទេ។ កាតព្វកិច្ចក្នុងការផ្តល់ព័ត៌មាន និងប្រគល់ឯកសារជាទូទៅមិនអនុវត្តចំពោះសហគ្រាសមិនជាប់កាតព្វកិច្ចឡើយ។[34]

- **សហគ្រាសជាប់កាតព្វកិច្ចមិនអាចជំនួសការវិភាគហានិភ័យសមស្របដោយដោយការបង្ហាញការធានាបែបកិច្ចសន្យា ឬការធានាដែលពាក់ព័ន្ធពីអ្នកផ្គត់ផ្គង់របស់ខ្លួន ដែលបញ្ជាក់ថាខ្សែចង្វាក់ផ្គត់ផ្គង់របស់ខ្លួនគ្មានហានិភ័យឡើយ។** សហគ្រាសជាប់កាតព្វកិច្ចត្រូវធ្វើការវិភាគហានិភ័យផ្ទាល់ខ្លួន ដើម្បីធានាថា ខ្លួនបានបំពេញការទទួលខុសត្រូវរបស់ខ្លួនស្ថិតក្រោមច្បាប់។ ក្នុងចំណោមកិច្ចការ ផ្សេងៗទៀត លទ្ធផលនៃការប្រមូល និងវិភាគដោយឯករាជ្យទៅលើហានិភ័យខ្សែចង្វាក់ផ្គត់ផ្គង់ក៏ជាប់ពាក់ព័ន្ធផងដែរ។ សហគ្រាសអាចប្រើប្រាស់វិធីសាស្រ្តខុសៗគ្នាដើម្បីវិភាគហានិភ័យ។ យ៉ាងណាមិញ ការស្នើសុំឱ្យមានការបង្ហាញព័ត៌មានផ្ទាល់ខ្លួនបែបគ្របដណ្តប់ និងទូលំលាយដោយមិនមានការយោងទៅលើស្ថានភាពជាក់ស្តែង ឬហានិភ័យជាក់ស្តែងរបស់អ្នកផ្គត់ផ្គង់មិនអនុលោមទៅនឹងវិធីសាស្រ្តផ្អែកលើហានិភ័យ និងបណ្តាលឱ្យមានការខិតខំយ៉ាងខ្លាំងសម្រាប់អ្នកផ្គត់ផ្គង់ឡើយ។ ការអនុវត្តបែបនេះអាចបណ្តាលឱ្យ BAFA ចាត់វិធានការស្របគ្នាសម្រាប់សហគ្រាសជាប់កាតព្វកិច្ច។

- ក្រៅពីនេះ គួរកត់សម្គាល់ផងដែរថា ការប្រើប្រាស់ឧបករណ៍ និងការវាយតម្លៃទិន្នន័យ គ្រាន់តែជា ផ្នែកមួយនៃនីតិវិធីវិភាគហានិភ័យតែប៉ុណ្ណោះ។ សហគ្រាសជាប់កាតព្វកិច្ចក៏អាចប្រើវិធីសាស្រ្តដូច ជាសវនកម្ម ឬស្ទង់ជារឧស្សាហកម្ម និងគោលការណ៍ណែនាំដើម្បីទទួលបានការយល់ដឹងទូលំទូលាយពីហានិភ័យនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់របស់ពួកគេ។ លើសពីនេះ នៅពេលបង្កើតការគ្រប់គ្រងហានិភ័យត្រូវមានការពិចារណាឱ្យបានសមស្របទៅលើអត្ថប្រយោជន៍កម្មករ និងអ្នកដែលអាច ទទួលផលប៉ះពាល់ដោយសកម្មភាពសេដ្ឋកិច្ចនៅក្នុងខ្សែចង្វាក់ ផ្គត់

[33] យោងតាមផ្នែក 9 § 3 នៃច្បាប់នេះ នៅក្នុងករណីនៃចំណេះដឹងច្បាស់លាស់ សូមមើលប្រអប់ព័ត៌មានទី 1

[34] យោងតាមផ្នែកទី 17 នៃច្បាប់ សហគ្រាសជាប់កាតព្វកិច្ចមានតួនាទីក្នុងការលាតត្រដាង និងប្រគល់ឱ្យវិញ នៅក្នុងវិសាលភាពដែលពួកគេ ត្រូវផ្តល់ព័ត៌មាន និងប្រគល់ឯកសារជូនទៅតាមការស្នើសុំរបស់ BAFA ដែល BAFA ត្រូវបំពេញកាតព្វកិច្ចតាមច្បាប់របស់ខ្លួន។ កាតព្វកិច្ចក៏រួម បញ្ចូលដល់ព័ត៌មានអំពីក្រុមហ៊ុនបុត្រសម្ព័ន្ធ អ្នកផ្គត់ផ្គង់ផ្ទាល់ និងប្រយោល និងការប្រគល់ជូនឯកសាររបស់សហគ្រាសទាំងនេះ។ ដរាបណាសហគ្រាស ឬបុគ្គលជាប់កាតព្វកិច្ចក្នុងការផ្តល់ឬប្រគល់ព័ត៌មាន ព័ត៌មានដែលខ្លួនអាចប្រើការបាន ឬនៅក្នុងតួនាទីក្នុងការប្រមូល ព័ត៌មានដែលបានស្នើសុំដោយសារតែទំនាក់ទំនងកិច្ចសន្យាដែលមានស្រាប់។ យ៉ាងណាមិញ ពាក់ព័ន្ធនឹងព័ត៌មាន និងភស្តុតាងដើម្បីកំណត់ថាតើ សហគ្រាសស្ថិតនៅក្នុងវិសាលភាពនៃច្បាប់ សហគ្រាសទាំងអស់មានកាតព្វកិច្ចក្នុងការផ្តល់ព័ត៌មានទៅកាន់ BAFA (ផ្នែក 17 § 2 No.1)

ផ្គង់។[35] ប្រសិនបើសហគ្រាស ជាប់កាតព្វកិច្ចត្រូវបានអ្នកផ្គត់ផ្គង់របស់ខ្លួនបដិសេធ មានហេតុផល ឬមិនមានហេតុផល ក្នុងការ បង្ហាញព័ត៌មានដែលតម្រូវនៅក្នុងបរិបទនៃការវិភាគហានិភ័យ ឬប្រសិនបើការបង្ហាញព័ត៌មាន នេះត្រូវបានធ្វើឱ្យលំបាក វាជាកាតព្វកិច្ចរបស់សហគ្រាសជាប់កាតព្វកិច្ចក្នុងការចង្អុលបង្ហាញកាលៈ ទេសៈទាំងនេះនៅក្នុងវិសាលភាពនៃការរាយការណ៍។ សហគ្រាសជាប់កាតព្វ កិច្ចគួរតែអាចចងក្រងឯកសារជាក់លាក់ថាតើមូលដ្ឋានណាមួយដែលពួកគេព្យាយាមប្រមូលព័ត៌មានពាក់ព័ន្ធមូលហេតុ ដែលធ្វើឱ្យការទទួលព័ត៌មានបរាជ័យ និងថាវិធានការជំនួសណាមួយដែលពួកគេបានប្រើប្រាស់ ដើម្បីទទួលបានព័ត៌មានពីផ្នែកពាក់ព័ន្ធ។ នៅក្នុងបរិបទនៃការត្រួតពិនិត្យរបាយការណ៍ BAFA និងពិចារណាទៅលើការពន្យល់ដែលអាចជឿទុកចិត្តបានយ៉ាងសមស្រប និងពិនិត្យមើលថាតើសហគ្រាសបានបំពេញកាតព្វកិច្ចរបស់ខ្លួនដែរឬទេ និងតើបំពេញបានកម្រិតណា។

## ប្រអប់ព័ត៌មានទី3៖ ការប្រើប្រាស់ឧបករណ៍សម្រាប់ការវិភាគហានិភ័យ

វាជាការស្របក្នុងការធ្វើការវិភាគហានិភ័យជាច្រើនជំហាន។ សហគ្រាសគួរប្រើប្រភពខាងក្នុង និងខាងក្រៅដើម្បីទទួលបានទិដ្ឋភាពទូទៅដែលសមស្រប។[36]

ជាដំបូង វាមានប្រយោជន៍ក្នុងការប្រមូលព័ត៌មានជាក់លាក់អំពីវិស័យ ប្រទេស និងផលិតផលដើម្បី ធ្វើវិភាគហានិភ័យអរូបី។ ជំហាននេះរួមមានជាឧទាហរណ៍ ការស្រាវជ្រាវឯកសារ (ឧ.ដោយការប្រើ ប្រាស់សន្ទស្សន៍ របាយការណ៍ NGO របាយការណ៍ UN របាយការណ៍ពីភ្នាក់ងារនានា -ល-)។ **មានឧបករណ៍ និងដំណោះស្រាយសូហ្វវែរផ្សេងទៀតដែលសហគ្រាសអាចប្រើប្រាស់បានដើម្បី វិភាគហានិភ័យ និងបង្កើតតម្លាភាពបន្ថែមទៀតនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់របស់ពួកគេ។ ទោះជាយ៉ាងណា វាជាការសំខាន់ដែលត្រូវកត់សម្គាល់ថាការប្រើប្រាស់ឧបករណ៍ទាំងនេះតែ ម្យ៉ាងមិនបានបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវផ្ទាល់ខ្លួនរបស់សហគ្រាសទេ។**

ជំហានបន្ទាប់ សហគ្រាសគួរវាយតម្លៃថាតើអ្នកផ្គត់ផ្គង់មានហានិភ័យអរូបីកម្រិតណា (ការវិភាគ ហានិភ័យជាក់ស្តែង)។ សម្រាប់ជំហាននេះ សហគ្រាសអាចរួមបញ្ចូលចំណេះដឹងខាងក្នុង និងខាងក្រៅពីផ្នែកផ្សេងៗ ហើយផ្ទៀងផ្ទាត់ការសន្ទត់ជាមួយនឹងតម្លៃធ្វើពិសោធន៍សវនកម្ម/ការបញ្ជាក់ ការយល់ឃើញពីអ្នកពាក់ព័ន្ធចម្រុះ និងគំនិតផ្តួចផ្តើមវិស័យ ឬការសន្ទនាជាមួយអ្នករងផលប៉ះពាល់ (សក្តានុពល) និងអ្នកតំណាងស្របច្បាប់របស់ពួកគេ។ នៅក្នុងបរិបទនេះ សហគ្រាសអាចងាកទៅ រកការវាយតម្លៃផ្ទាល់ខ្លួន កម្រងសំណួររបស់អ្នកផ្គត់ផ្គង់ ឬការចុះពិនិត្យនៅទីតាំងផ្ទាល់។

- **សហគ្រាសជាប់កាតព្វកិច្ចជាទូទៅមិនអាចបញ្ជូនបន្តការអនុវត្តវិធានការទប់ស្កាត់ទៅកាន់អ្នកផ្គត់ផ្គង់របស់ខ្លួនឡើយ។** វិធានការទប់ស្កាត់ត្រូវបំពេញតាមកម្រិតនៃភាពសមស្រប និងប្រសិទ្ធភាព និង ទាក់ទងនឹងអ្នកផ្គត់ផ្គង់ផងដែរ។ សហគ្រាសជាប់កាតព្វកិច្ចមិនអាចបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវនេះ ដោយគ្រាន់តែយោងទៅលើ**ការធានាជាលាយលក្ខណ៍អក្សរ**ពីអ្នកផ្គត់ផ្គង់ទេ។ សេចក្តីប្រកាសទូទៅ ពីការជម្រះកាតព្វកិច្ចក៏មិនមែនជាការបំពេញកាតព្វកិច្ចដែរ។ ការធ្វើបែបនេះអាចនាំឱ្យមានការចាត់ វិធានការសមស្របពី BAFA ទៅលើសហគ្រាសជាប់កាតព្វកិច្ច។ ផ្ទុយទៅវិញ វិធានការទប់ស្កាត់ដែលរួមមានការធានាបែបកិច្ចសន្យាត្រូវពិចារណាទៅលើលទ្ធផលនៃកាវិភាគហានិភ័យផ្ទាល់ខ្លួន និងត្រូវរៀបចំតាមវិធីដែលសមស្រប និងមានប្រសិទ្ធភាព។ សហគ្រាសជាប់

[35] ផ្នែកទី 4 § 4 នៃច្បាប់នេះ។

[36] សូមមើលឧបសម្ព័ន្ធនៃជំពូក V នៃគោលការណ៍ណែនាំនេះ ក៏ដូចជាគោលការណ៍ណែនាំរបស់ BAFA ស្តីពីការវិភាគហានិភ័យ

កាតព្វកិច្ចគួរ ពន្យល់ជាពិសេសទៅលើហានិភ័យដែលបានរកឃើញ និងអាទិភាពរបស់ខ្លួនចំពោះអ្នកផ្គត់ផ្គង់តាមវិធីដែលច្បាស់លាស់មួយ។[37] វិសាលភាពនៃការ ខិតខំប្រឹងប្រែងដែលសហគ្រាសត្រូវអនុវត្ត ស្ថិតក្នុងវិសាលភាពនៃកាតព្វកិច្ចរបស់ពួកគេនៅ ពេលអនុវត្តវិធានការចំពោះអ្នកផ្គត់ផ្គង់ផ្ទាល់ក៏ត្រូវបានកំណត់ដោយហានិភ័យដែលបានរកឃើញផងដែរ។

- ប្រសិនបើការអនុវត្តវិធានការទប់ស្កាត់បរាជ័យដោយសារតែអ្នកផ្គត់ផ្គង់មិនបានផ្តល់ការធានា ការខិតខំប្រឹងប្រែងរបស់សហគ្រាសជាប់កាតព្វកិច្ចក្នុងការបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវរបស់ខ្លួនមិនអាចធ្វើទៅបានទេ ប្រសិនបើការធានាមិនអាចត្រូវបានរំពឹងថាចាប់ផ្តើមជាមួយ (ឧ. ដោយ សារតែការលើកលែងយ៉ាងទូលំទូលាយពីការទទួលខុសត្រូវចំពោះផលវិបាករបស់អ្នកផ្គត់ផ្គង់ ឬថ្លៃចំណាយខ្ពស់ដែលមិនសមាមាត្រដែលមិនត្រូវបានគ្របដណ្តប់ដោយថ្លៃទិញ)។ ទាក់ទងនឹងលក្ខខណ្ឌនៃមាត្រានៃកិច្ចសន្យាដែលរួមបញ្ចូលអ្នកផ្គត់ផ្គង់ប្រយោលទៅក្នុងវិធានការទប់ស្កាត់ គួរកត់សម្គាល់ ថាកិច្ចសន្យាដែលថ្លៃចំណាយជាបន្ទុករបស់ភាគីទីបីជាទូទៅ មិនមានសុពលភាពឡើយ។

- **ជាទូទៅវាជាការទទួលខុសត្រូវរបស់សហគ្រាសជាប់កាតព្វកិច្ចក្នុងការធានាឱ្យមានការអនុវត្តការ បណ្តុះបណ្តាល និងអប់រំជាបន្ត។** ជំហានដំបូង និងសំខាន់បំផុត ពួកគេគួរជួយដល់អ្នកផ្គត់ផ្គង់ដោយ ការទទួលស្គាល់ និងដោះស្រាយបញ្ហាហានិភ័យសិទ្ធិមនុស្ស និងបរិស្ថាននៅដំណាក់កាលដំបូង។ លើសពីនេះ ពួកគេគួរជួយអ្នកផ្គត់ផ្គង់ឱ្យអនុលោមតាម និងអនុវត្តកាតព្វកិច្ចបែបកិច្ចសន្យាប្រកប ដោយប្រសិទ្ធភាព។ គួរមានចែងនៅក្នុងកិច្ចសន្យាថានរណាជាអ្នកធ្វើការបណ្តុះបណ្តាល និងអប់រំជាបន្ត និងនរណាជាអ្នករ៉ាប់រងថ្លៃចំណាយ។[38] សហគ្រាសជាប់កាតព្វ កិច្ចអាចគ្រប់គ្រង ឧ. នៅក្នុងគំរូ ថាតើការបណ្តុះបណ្តាល និងអប់រំបន្តដែលបានព្រមព្រៀងពិតជាបានកើតឡើងឬទេ និងថាតើវា បានទៅដល់ក្រុមគោលដៅដែលពាក់ព័ន្ធដែរ ឬទេ។ ការបណ្តុះបណ្តាល និងអប់រំបន្ត គួរតែគ្រប ដណ្តប់ខ្លឹមសារនៃច្បាប់នេះ និងក្របខណ្ឌអន្តរជាតិដែលវាផ្អែកលើ។ សហគ្រាសអាចជួលអ្នកផ្តល់ សេវាខាងក្រៅសម្រាប់ការបណ្តុះបណ្តាល និងអប់រំបន្តទាំងនោះ។ នៅក្នុងបរិបទនេះ គួរកត់ចំណាំ ផងដែរថា ការបណ្តុះបណ្តាល និងអប់រំបន្តគ្របដណ្តប់ទៅលើខ្លឹមសារអំពីជំហរផ្នែកច្បាប់ដែលត្រូវបានការពារនៃច្បាប់នេះនៅក្នុងបរិបទជាក់ស្តែងនៃអ្នកផ្គត់ផ្គង់ និងទំនាក់ទំនងអាជីវកម្មរបស់ខ្លួនទៅនឹងសហគ្រាសជាប់កាតព្វកិច្ច។[39]

- ច្បាប់តម្រូវឱ្យ**សហគ្រាសជាប់កាតព្វកិច្ចព្រមព្រៀងបែបកិច្ចសន្យាទៅលើយន្តការត្រួតពិនិត្យសមស្រប និងអនុវត្តការត្រួតពិនិត្យ**ចំពោះអ្នកផ្គត់ផ្គង់របស់ពួកគេ (ឧ.សវនកម្ម)។ ការប្រកាសដោយខ្លួនឯងរបស់អ្នកផ្គត់ផ្គង់អាចជាឧបករណ៍ជំនួយដ៏មានប្រយោជន៍សម្រាប់ការត្រួតពិនិត្យបន្ត។ **យ៉ាងណាមិញ ការប្រកាសដោយខ្លួនឯងជាលាយលក្ខណ៍អក្សរជាទៀងទាត់ថាអ្នកផ្គត់ផ្គង់អនុលោមតាមលក្ខខណ្ឌតម្រូវនៃសិទ្ធិមនុស្ស និងបរិស្ថានដែលបានព្រមព្រៀងតែម្យ៉ាង មិនគ្រប់គ្រាន់ជាយន្តការត្រួតពិនិត្យទេ។** ប្រសិនបើសហគ្រាសជាប់កាតព្វកិច្ចស្នើសុំការប្រកាសបែបនេះតាមបែបទូទៅ និងទូលំទូលាយពីអ្នកផ្គត់ផ្គង់ទាំងអស់ វាអាចជាការមិនសមស្រប ជាហេតុធ្វើឱ្យគេមិនបានបំពេញ តាមកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវដោយស្របច្បាប់ទេ។

- សវនកម្មអាចត្រូវបានប្រើប្រាស់ដើម្បីកំណត់ហានិភ័យ និងការបំពានជាក់ស្តែងនៅកន្លែងអ្នក

---

[37] សម្រាប់ការពន្យល់បន្ថែម សូមមើលជំពូក IV.2 នៃ គោលការណ៍ណែនាំនេះ

[38] សូមមើលផងដែរនៅផ្នែក IV.3.a) នៅក្នុងគោលការណែនាំស្តីពីការបែងចែកថ្លៃចំណាយសមស្របសម្រាប់វិធានការកែប្រែ

[39] បញ្ជីខាងក្រោមផ្តល់នូវទិដ្ឋភាពទូទៅអំពីព័ត៌មាន និងការបណ្តុះបណ្តាលពាក់ព័ន្ធ (ជាភាសាអាល្លឺម៉ង់)៖ https://www.csr-indeutschland.de/DE/Wirtschaft-Menschenrechte/Umsetzungshilfen/Information-Beratung-Schulung-Vernetzung/Netzwerkbildung-und-Schulungen/netzwerkbildung-und-schulungen.html

ផ្គត់ផ្គង់។ ក្រៅពីនេះ វាអាចត្រូវបានប្រើជាវិធានការត្រួតពិនិត្យដើម្បីវាយតម្លៃថាតើ វិធានការទប់ស្កាត់ ឬ កែប្រែនាំឱ្យមានលទ្ធផលដែលចង់បានដែរ ឬទេ។

យ៉ាងណាមិញ វាគ្រាន់តែជាសូចនាករមួយសម្រាប់បំពេញតាមការរំពឹងទុក និងសម្រាប់តែករណី ដែលសវនកម្មដែលបានលើកឡើងត្រូវតាមលក្ខខណ្ឌជាក់លាក់ រួមទាំងឯករាជ្យភាព និងតម្លាភាព តែប៉ុណ្ណោះ។[40]

## ប្រអប់ព័ត៌មានទី4៖ តួនាទីនៃស្តង់ដារនៅក្នុងការបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវស្របច្បាប់

សហគ្រាសជាប់កាតព្វកិច្ចពឹងផ្អែកកាន់តែខ្លាំងទៅលើស្តង់ដារដើម្បីបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវរបស់ខ្លួន។ សហគ្រាសជាប់កាតព្វកិច្ចអាចជួយទៅលើ សារពើភ័ណ្ឌជាប្រព័ន្ធ ការវាយតម្លៃហានិភ័យ កិច្ចព្រមព្រៀងស្តីពីវិធានការ និងការត្រួតពិនិត្យកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវទាក់ទងទៅនឹងអ្នកផ្គត់ផ្គង់ផ្ទាល់ និងប្រយោល។ អ្នកប្រើប្រាស់ក៏ធ្វើការសម្រេចចិត្តទិញ ដោយផ្អែកកាន់តែច្រើនទៅលើស្តង់ដារដែលសន្យាថាផលិតផល និងសេវាត្រូវបានផលិតដោយអនុលោមតាមសិទ្ធិមនុស្ស។[41]

ច្បាប់នេះមិនបានផ្តល់សិទ្ធិពិសេសដល់ស្តង់ដារជាក់លាក់ទេ។ លើសពីនេះ ច្បាប់នេះមិនបាន បញ្ជាក់ថាភស្តុតាងមួយណាដែលត្រូវផ្តល់ ឬព្រមព្រៀងដោយអ្នកផ្គត់ផ្គង់នៅក្នុងករណីជាក់លាក់ទេ។ ស្តង់ដារអាចជាឧបករណ៍ជំនួយដ៏មានប្រយោជន៍ ដើម្បីជួយសហគ្រាសជាប់កាតព្វកិច្ចក្នុងការ អនុលោមទៅនឹងកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវនៅតាមខ្សែចង្វាក់ផ្គត់ផ្គង់របស់ពួកគេ។ **យ៉ាងណាមិញ ពួកគេ ជាទូទៅមិនលើកលែងសហគ្រាសនានាពីកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវរបស់ពួកគេទេ។**

នៅក្នុងវិសាលភាពដែលស្តង់ដារពិចារណាទៅលើលក្ខខណ្ឌតម្រូវនៃការត្រួតពិនិត្យភាពត្រឹមត្រូវស្របច្បាប់ វាអាចត្រូវបានប្រើប្រាស់ជាសូចនាករសម្រាប់ការបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវនៅក្នុងបរិបទនៃដំណើរការត្រួតពិនិត្យបទប្បញ្ញត្តិ។ យ៉ាងណាមិញ សហគ្រាសគួរដឹងអំពី ដែនកំណត់នៃស្តង់ដារ ហើយដំបូងត្រូវពិចារណាថាតើ ស្តង់ដារដែលបានជ្រើសរើសមានប្រសិទ្ធ ភាព និងសក្តិសមសម្រាប់គោលបំណងរបស់ពួកគេដែរឬទេ និងដល់កម្រិតណា។

[40] សវនកម្ម និងការបញ្ជាក់ ជានិច្ចកាល ផ្តល់តែរូបភាពរួមនៃស្ថានភាពបច្ចុប្បន្នតែប៉ុណ្ណោះ។ ក្រៅពីនេះ ហានិភ័យជាក់លាក់ (នៃចេតនាសម្ព័ន្ធ) អាចនឹងមិនត្រូវបានរកឃើញតាមរយៈសវនកម្ម។ ពេលវេលាមានកំណត់ ការគួរសមចំពោះអតិថិជន (ជាញឹកញាប់សហគ្រាសដែលត្រូវបាន ធ្វើសវនកម្ម) បុគ្គលិកដែលមានសមត្ថភាពមិនគ្រប់គ្រាន់ ឬសូម្បីតែអំពើពុករលួយអាចមានឥទ្ធិពលទៅលើលទ្ធផល និងអាចនាំឱ្យមានស្ថានភាព ដែលលក្ខខណ្ឌជាក់ស្តែងនៅទីតាំងមិនត្រូវបានឆ្លុះបញ្ចាំងតាមវិធីដែលត្រឹមត្រូវ។ ព័ត៌មានបន្ថែម រួមទាំងតួនាទីនៃសវនកម្មនៅក្នុងនីតិវិធីត្រួតពិនិត្យភាពត្រឹមត្រូវអាចរកបាននៅក្នុងកញ្ចប់ព័ត៌មាន 8។ Runder Tisch: Wirtschaft & Menschenrechte - Austausch zwischen NGOs und Unternehmen' នៃអាជីវកម្ម & សិទ្ធិមនុស្ស (ជាភាសាអាឡឺម៉ង់)៖

https://wirtschaftentwicklung.

de/fileadmin/user_upload/5_Wirtschaft_und_Menschenrechte/Aktuelle_Downloads/8._Runder_Tisc

h_Rolle_von_Audits.pdf

[41] ការិយាល័យជំនួយអំពីធុរកិច្ច & សិទ្ធិមនុស្ស ផ្តល់ព័ត៌មានបន្ថែមស្តីពីតួនាទីនៃស្តង់ដារស្របតាមគោលការណែនាំរបស់អង្គការសហប្រជាជាតិ នៅក្នុង "ត្រីវិស័យស្តង់ដារ" របស់ពួកគេ៖ https://kompass.wirtschaft-entwicklung.de/en/standardscompass/

what-can-standards-achieve

RESPONSIBLE BUSINESS HUB CAMBODIA
RBH NETWORK

> ក្រៅពីនេះ ស្តង់ដារអនុវត្តតាមវិធីសាស្ត្រផ្សេងគ្នា និងជានិច្ចកាលមិនតម្រូវឱ្យមានប្រព័ន្ធគ្រប់គ្រងដ៏រឹងមាំទេ។ គុណភាព និងភាពជឿជាក់របស់ស្តង់ដារពឹងផ្អែកយ៉ាងខ្លាំងទៅលើ ថាតើភាគីពាក់ព័ន្ធ ណា (ឧ.តួអង្គសង្គមស៊ីវិល) ដែលត្រូវបានរួមបញ្ចូលទៅក្នុងការអភិវឌ្ឍរបស់ខ្លួន និងថា តើលក្ខណៈ វិនិច្ឆ័យត្រូវបានផ្ទៀងផ្ទាត់ដោយរបៀបណានៅក្នុងការអនុវត្តជាក់ស្តែង។ ឧទាហរណ៍ នៅក្នុង ប្រទេសដែលមានអភិបាលកិច្ចខ្សោយ ការកើនឡើងនៃភាពងាយរងគ្រោះចំពោះអំពើពុករលួយ អាចបណ្តាលឱ្យមានការប៉ុនប៉ងសូកប៉ាន់ដើម្បីមានឥទ្ធិពលលើលទ្ធផលនៃការត្រួតពិនិត្យការអនុលោមតាមស្តង់ដារ។

- **សហគ្រាសជាប់កាតព្វកិច្ចមិនបានបំពេញកាតព្វកិច្ចរបស់ពួកគេដើម្បីអនុវត្តនីតិវិធីបណ្តឹងដោយយោងទៅនីតិវិធីបណ្តឹងរបស់អ្នកផ្គត់ផ្គង់ទេ។** សហគ្រាសមិនជាប់កាតព្វកិច្ច មិនចាំបាច់អនុវត្តនីតិវិធីបណ្តឹង របស់ខ្លួនយោងតាមច្បាប់នេះទេ។ ពេលខ្លះ សហគ្រាសជាប់កាតព្វកិច្ចព្យាយាមបំពេញកាតព្វកិច្ចរបស់ ខ្លួនក្នុងការធ្វើឱ្យនីតិវិធីបណ្តឹងរបស់ខ្លួនអាចចូលទៅប្រើប្រាស់បានទាំងស្រុង ដោយតម្រូវឱ្យអ្នកផ្គត់ផ្គង់របស់ខ្លួនអនុវត្តនីតិវិធីបណ្តឹងរបស់ពួកគេផ្ទាល់ និងធ្វើឱ្យអ្នករាយការណ៍ សក្តានុពលអាចចូលទៅប្រើប្រាស់វាបាននៅក្នុងបរិបទនៃអ្នកផ្គត់ផ្គង់បន្តរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី វាមិនមែនជាការបំពេញ កាតព្វកិច្ចរបស់សហគ្រាសជាប់កាតព្វកិច្ចក្នុងការអនុវត្តនីតិវិធីបណ្តឹងសមស្រប និងធ្វើឱ្យវាអាចចូល ទៅប្រើប្រាស់បាននោះទេ។ ផ្ទុយទៅវិញ ពួកគេត្រូវរចនានីតិវិធីបណ្តឹងផ្ទាល់ខ្លួនតាមរបៀបដែលអាចជួយឱ្យនរណាម្នាក់ផ្តល់ដំណឹងដល់ពួកគេអំពីហានិភ័យ និងការបំពានកាតព្វកិច្ចសិទ្ធមនុស្ស និងបរិស្ថានដែលបណ្តាលមកពីសកម្មភាពអាជីវកម្មរបស់អ្នកផ្គត់ផ្គង់។ សហគ្រាសជាប់កាតព្វកិច្ច ជាពិសេស ត្រូវផ្តល់ព័ត៌មានដែលច្បាស់ និងអាចយល់បានទាក់ទងនឹងនីតិវិធី និងបណ្តាញសារទុក្ខដែលមាន។ លើសពីនេះ នីតិវិធីបណ្តឹងត្រូវការពារការសម្ងាត់ និងអត្តសញ្ញាណនៃភាគីសក្តានុពល និងផ្តល់ការការពារដែលមានប្រសិទ្ធភាពពីផលវិបាក ឬការពិន័យដោយសារតែការសារទុក្ខ។
- សហគ្រាសជាប់កាតព្វកិច្ចអាចប្រើនីតិវិធីខាងក្នុង ចូលរួមនៅក្នុងនីតិវិធីខាងក្រៅដែលស្មើគ្នា ឬការរួមបញ្ចូលគ្នានីតិវិធីបណ្តឹងខាងក្នុង និងខាងក្រៅ។ ដោយសារតែការកំណត់ក្រុមគោលដៅនៃនីតិវិធី និងវិធានការសារទុក្ខដើម្បីធ្វើឱ្យអាចចូលទៅប្រើប្រាស់នីតិវិធីបណ្តឹងបាននៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ ដែលជ្រៅជាងនេះ បង្កឱ្យមានបញ្ហាប្រឈមជាក់លាក់សម្រាប់សហគ្រាសជាប់កាតព្វកិច្ច សហគ្រាសជាប់កាតព្វកិច្ចអាចវាយតម្លៃថាតើនីតិវិធីបណ្តឹងខាងក្រៅអាចជាដំណោះស្រាយដែលប្រសើរជាង។ នីតិវិធីបណ្តឹង ខាងក្រៅក៏មានអត្ថប្រយោជន៍ខ្លាំងផងដែរ ប្រសិនបើសហគ្រាសជាប់កាតព្វកិច្ចធ្វើលទ្ធកម្មផលិតផល ឬសេវាកម្មពីអ្នកផ្គត់ផ្គង់ដូចគ្នា។

នៅក្នុងការបង្កើតខចែង ឬមាត្រានៃកិច្ចសន្យាសម្រាប់ក្រមប្រតិបត្តិអ្នកផ្គត់ផ្គង់ សហគ្រាសជាប់កាតព្វកិច្ចត្រូវពិចារណាពីលទ្ធផលនៃការវិភាគហានិភ័យ។ នៅពេលធ្វើបែបនេះ សហគ្រាសជាប់កាតព្វកិច្ចត្រូវពិនិត្យដោយប្រុងប្រយ័ត្នថាតើកាតព្វកិច្ចសិទ្ធិមនុស្ស និងបរិស្ថានណាមួយនៅក្នុងច្បាប់ដែលពាក់ព័ន្ធសម្រាប់អ្នកផ្គត់ផ្គង់នីមួយៗ និងប្រសិនបើចាំបាច់ដោះស្រាយចំពោះតែហានិភ័យ និងការបំពាននីមួយៗទាំងនេះតែប៉ុណ្ណោះ ហើយជូនដំណឹងកិច្ចការនេះទៅកាន់អ្នកផ្គត់ផ្គង់ទៅតាមករណីសមស្រប។

## IV. ការណែនាំសម្រាប់កិច្ចសហការនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់

កិច្ចសហការនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ត្រូវតែយល់ថាជាដំណើរការដ៏សកម្មដោយផ្អែកលើការពិភាក្សា។ ជាការល្អដែល សហគ្រាសជាប់កាតព្វកិច្ចគួរសហការជាមួយអ្នកផ្គត់ផ្គង់របស់ខ្លួនដោយយុត្តិធម៌ និងស្មើភាពនៅក្នុងរយៈពេលយូរ។ សហ

គ្រាសជាប់កាតព្វកិច្ចត្រូវដឹងពីតួនាទី និងឥទ្ធិពលរបស់ខ្លួន និង ជាឧទាហរណ៍ផ្តោតទៅលើខចែង និងលក្ខខណ្ឌនៃកិច្ចសន្យាសមស្របនៅក្នុងដំណើរការទិញ ឧ. ក្នុងការកំណត់តម្លៃ និងរយៈពេលដំណើរការ។[42]

សហគ្រាសជាប់កាតព្វកិច្ច អាចត្រូវបានរំពឹងទុកថានឹងអនុវត្តការរួមបញ្ចូលគ្នានៃវិធានការលើកទឹកចិត្ត និងគ្រប់គ្រង។ វិធីសាស្រ្តដែលអាចអនុវត្តបានសម្រាប់វិធានការ គឺការអនុវត្តការបណ្តុះបណ្តាលសុខភាព និងសុវត្ថិភាពការងារ ការផ្លាស់ប្តូរចេនាសម្ព័ន្ធ ឬបច្ចេកទេសដែលចាំបាច់ស្ថិតក្រោមច្បាប់សុខភាព និងសុវត្ថិភាពការងារ ការណែនាំអំពីការគ្រប់គ្រងទឹកកខ្វក់ប្រកបដោយនិរន្តរភាព សវនកម្ម/ការពិនិត្យឡើងវិញ តម្លៃទិញដែលខ្ពស់ គាំទ្រក្នុងការបណ្តុះបណ្តាលអ្នកផ្គត់ផ្គង់ ឬការបញ្ជាក់នៃទីតាំងផលិតកម្ម។ អ្នកផ្គត់ផ្គង់អាចត្រៀមខ្លួនសម្រាប់តម្រូវការដែលមានការកើនឡើងរបស់អតិថិជនដោយអនុវត្តដំណើរការដែលកាត់បន្ថយហានិភ័យសិទ្ធិមនុស្សនិងបរិស្ថាន។

ម្យ៉ាងវិញទៀត សហគ្រាសមិនជាប់កាតព្វកិច្ចអាចសួរខ្លួនឯងថាតើវិធានការមួយណាដែលធ្វើឱ្យខ្លួន ទទួលបានការយល់ដឹងកាន់តែច្បាស់ពីហានិភ័យ និងរបៀបដែលខ្លួនអាចចាប់ផ្តើមដោះស្រាយបញ្ហាទាំងនោះ។

ឈរលើមូលដ្ឋាននេះសហគ្រាសជាប់កាតព្វកិច្ច និងសហគ្រាសមិនជាប់កាតព្វកិច្ចក៏អាចពិនិត្យទៅលើ ថាតើខ្លួនអាចរួមគ្នាដោះស្រាយលក្ខខណ្ឌតម្រូវបានដោយរបៀបណា។ សហគ្រាសជាប់កាតព្វកិច្ចទទួលបានប្រយោជន៍ពីការដោះស្រាយហានិភ័យ និងការបំពាននៅក្នុងករណីនោះ ហើយសហគ្រាសមិនជាប់កាតព្វកិច្ច មិនថានៅក្នុងប្រទេសអាឡឺម៉ង់ ឬបរទេសទទួលបានជំនួយក្នុងការអនុវត្តវិធានការទប់ស្កាត់ និងកែប្រែដោយផ្អែកលើហានិភ័យ ដែលជាញឹកញាប់ច្រើនតែស្មុគស្មាញនិងចំណាយច្រើន។ សហគ្រាសជាប់កាតព្វកិច្ចក៏ត្រូវពិចារណាផងដែរពីផលប្រយោជន៍បុគ្គលិក និងអ្នកដែលអាចរងផលប៉ះពាល់ដោយសកម្មភាពអាជីវកម្មនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ (ឧ. អ្នករស់នៅសហគមន៍ជុំវិញ)។

កាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវគឺជាដំណើរការរៀនសូត្រសម្រាប់អ្នកចូលរួមទាំងអស់។ ដើម្បីបង្កើតការ រួមសហការណ៍គ្នា និងចែករំលែកបទពិសោធន៍រៀនសូត្រ សហគ្រាសជាប់កាតព្វកិច្ច ជាពិសេសគួរផ្លាស់ប្តូរព័ត៌មានទៅវិញទៅមកអំពីហានិភ័យដែលបានកំណត់នៅក្នុងក្របខណ្ឌនៃគំនិតផ្តួចផ្តើមពហុភាគី។ គោលបំណងគួរតែជាការស្វែងរកដំណោះស្រាយរួមគ្នាសម្រាប់ពង្រឹងការទទួលខុសត្រូវផ្នែក សិទ្ធិមនុស្សនិងបរិស្ថាននៅតាមខ្សែចង្វាក់ផ្គត់ផ្គង់ និងខ្សែចង្វាក់តម្លៃ ឧទាហរណ៍សម្រាប់វិស័យ ក្រុមផលិតផល ផលិតផល ឬតំបន់។

## 1. វិធីសាស្រ្តសម្រាប់ការវិភាគ

សហគ្រាសជាប់កាតព្វកិច្ចគួរវាយតម្លៃថាតើព័ត៌មានណាដែលខ្លួនត្រូវការពីអ្នកផ្គត់ផ្គង់របស់ខ្លួនដើម្បីធ្វើការវិភាគហានិភ័យដែលសមស្រប។ ការវាយតម្លៃនេះក៏មានប្រយោជន៍ផងដែរសម្រាប់ផ្នែកអ្នកផ្គត់ផ្គង់។ នៅក្នុងករណីជាច្រើនសហគ្រាសជាប់កាតព្វកិច្ចសាកសួរព័ត៌មានយ៉ាងទូលំទូលាយពីអ្នកផ្គត់ផ្គង់របស់ខ្លួន។ មិនមែនព័ត៌មានទាំងអស់នេះសុទ្ធតែចាំបាច់សម្រាប់ការវិភាគហានិភ័យដែលសមស្រប នោះទេ។ ធៀបទៅនឹងព័ត៌មាននៃលក្ខណៈវិនិច្ឆ័យភាពសមស្រប ឧទាហរណ៍ដោយសួរអ្នកផ្គត់ផ្គង់ អាឡឺម៉ង់អំពីពលកម្មកុមារ ទម្រង់ដ៏អាក្រក់បំផុតនៃពលកម្មកុមារ ឬពលកម្មដោយបង្ខំ ដោយផ្អែកលើវិស័យ ប្រហែលជាគ្មានមូលដ្ឋាន។[43] បើមើលតែមួយភ្លែត វាហាក់ដូចជាងាយស្រួលសម្រាប់សហគ្រាស ជាប់កាតព្វកិច្ចក្នុងការស្នើសុំព័ត៌មានយ៉ាងទូលំទូលាយពីអ្នកផ្គត់ផ្គង់ទាំងអស់ ដោយមិនយោងទៅករណីនីមួយៗរៀងខ្លួនតាមរយៈកម្រងសំណួរវាយតម្លៃខ្លួនឯង។ យ៉ាងណាមិញ នៅពេលសហគ្រាសជាប់កាតព្វកិច្ចទាមទារព័ត៌មានពីអ្នកផ្គត់ផ្គង់ផ្ទាល់ទាំងអស់

[42] សម្រាប់ព័ត៌មានទាក់ទងនឹងផលវិបាកនៃច្បាប់ប្រកួតប្រជែងសូមមើលជំពូកទី IV.3.b នៃគោលការណ៍ណែនាំនេះ

[43] នៅក្នុងវិស័យខ្លះ ករណីដាច់ពីគេនៃពលកម្មដោយបង្ខំនៅក្នុងប្រទេសអាឡឺម៉ង់ត្រូវបានរាយការណ៍កាលពីអតីតកាល។ សេចក្តីប្រកាសជាទូទៅ ថាអ្នកផ្គត់ផ្គង់មានមូលដ្ឋានក្នុងប្រទេសអាឡឺម៉ង់ (ឬ EU) ហេតុដូចនេះមិនពាក់ព័ន្ធនឹងហានិភ័យសិទ្ធិមនុស្ស ឬបរិស្ថានដែលមើលមិនឃើញទេ។ [44] សូមមើលប្រអប់ព័ត៌មានទី 4 ទាក់ទងនឹងតួនាទីនៃស្តង់ដារ និងការបញ្ជាក់។

របស់ខ្លួន ពួកគេអាចប្រឈមនឹងហានិភ័យនៃការទទួលបានព័ត៌មានច្រើនពេក ដែលមិនបានជួយក្នុងការបង្កើតការយល់ដឹងបានកាន់តែច្បាស់នៃហានិភ័យដែលកំពុងប្រឈមនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់របស់ខ្លួនទេ។ លទ្ធផលជាញឹកញាប់មិនអាចប្រើប្រាស់បានសម្រាប់ការវិភាគហានិភ័យ និងបង្កើតកិច្ចខិតខំប្រឹងប្រែង និងថ្លៃចំណាយយ៉ាងច្រើនសម្រាប់សហគ្រាសមិនជាប់កាតព្វកិច្ចទេ។ ដោយសារតែការវិភាគហានិភ័យត្រូវបានប្រើប្រាស់ដើម្បីបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវរបស់សហគ្រាសជាប់កាតព្វកិច្ច ពួកគេគួរថ្លឹងថ្លែងឱ្យមានតុល្យភាពរវាងកិច្ចខិតខំប្រឹងប្រែង និងថ្លៃចំណាយ ហើយបន្ថែមពីលើការប្រឈមនឹងហានិភ័យត្រូវតែពិចារណាពីសមត្ថភាព និងតម្រូវការរបស់អ្នកផ្គត់ផ្គង់ជានិច្ច។

**ឧទាហរណ៍អវិជ្ជមានទី 2**

សគ្រាសជាប់កាតព្វកិច្ចទាក់ទងអ្នកផ្គត់ផ្គង់ដែលពាក់ព័ន្ធទាំងអស់ដោយប្រើកម្រងសំណួរដូចគ្នា និងសុំឱ្យអ្នកផ្គត់ផ្គង់ទាំងអស់ចុះហត្ថលេខាលើការ ធានាដែលមានស្តង់ដារដូចគ្នា។ ក្នុងករណីមិនមានការឆ្លើយតប សហគ្រាស ធ្វើការគំរាមដោយផលវិបាកអវិជ្ជមានសម្រាប់ទំនាក់ទំនងអាជីវកម្ម។ ក្នុងចំណោមអ្នកផ្គត់ផ្គង់ដែលបានទាក់ទងគឺមិនមានភាពខុសគ្នាទេ។ ក្រុមហ៊ុនផ្តល់សេវា IT នៅក្នុងប្រទេស អាឡឺម៉ង់ ក្រុមហ៊ុនច្បាប់អាឡឺម៉ង់ដែលផ្តល់ ប្រឹក្សាដល់ក្រុមហ៊ុនបុត្រសម្ព័ន្ធនៅក្នុងតំបន់អាជីវកម្ម និង សិប្បកម្មផ្ទាល់ខ្លួន របស់សហគ្រាសជាប់កាតព្វកិច្ច។

វិធីសាស្ត្រនេះមិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃច្បាប់ទេ ហើយអាចប៉ះពាល់ដល់សកម្មភាពត្រួតពិនិត្យរបស់ BAFA។

ដើម្បីជៀសវាងការទាមទារច្រើនហួសហេតុ ទៅលើអ្នកផ្គត់ផ្គង់មិនជាប់កាព្វកិច្ចនៅក្នុងបរិបទនៃការវិភាគហានិភ័យសហគ្រាសជាប់កាតព្វកិច្ច ជាដំបូងត្រូវកំណត់ពីទម្រង់ហានិភ័យនៃអ្នកផ្គត់ផ្គង់ផ្ទាល់ និង (ប្រសិនបើចំបាច់) ប្រយោលនៅក្នុងការវិភាគហានិភ័យអរូបី។ លទ្ធផលរកឃើញទាំងនេះគួរប្រើជា មូលដ្ឋានសម្រាប់វិធានការបន្ថែមទៀត។ ឧទាហរណ៍ វាប្រហែលជាមិនសមស្របរួចទៅហើយក្នុងការបញ្ជូលអ្នកផ្គត់ផ្គង់ដែលមានហានិភ័យទាបទៅក្នុងព័ត៌មានលម្អិតដូចគ្នាទៅនឹងអ្នកផ្គត់ផ្គង់ដែលមានហានិភ័យខ្ពស់។ ការធ្វើបែបនេះក៏អនុវត្តផងដែរចំពោះការបញ្ជូលអ្នកផ្គត់ផ្គង់ផ្ទាល់នៃក្រុមហ៊ុនបុត្រសម្ព័ន្ធដែលជាផ្នែកមួយនៃតំបន់អាជីវកម្មផ្ទាល់ខ្លួនរបស់សហគ្រាសជាប់កាតព្វកិច្ច។

អ្នកផ្គត់ផ្គង់ជាច្រើនទទួលបានកម្រងសំណួរខុសៗគ្នាជាច្រើន ដែលជាខ្លឹមសារគឺស្នើសុំព័ត៌មានដូចគ្នា ប៉ុន្តែខុសគ្នាត្រង់សេចក្តីលម្អិត និងការរៀបចំ។ ការបំពេញកម្រងសំណួរទាំងនេះគឺតម្រូវឱ្យមានការព្យាយាមយ៉ាងច្រើន។ នៅទីនេះ វាអាចនឹងសមហេតុផលក្នុងការបង្កើតទម្រង់កម្រងសំណួរទូទៅ ឧទាហរណ៍ នៅក្នុងក្របខណ្ឌ នៃគំនិតផ្តួចផ្តើមតាមវិស័យ។ សហគ្រាសជាប់កាតព្វកិច្ចក៏អាចពិនិត្យមើលផងដែរថាតើកម្រងសំណួរ ទម្រង់ការវាយតម្លៃ និងតារាងពិន្ទុ -ល- ដែលបានបំពេញរួចរាល់ពីសូហ្វវែរ ឬអ្នកផ្តល់សេវាដំណោះស្រាយ ប្រព័ន្ធ ឬប្រភពផ្សេង៉ បានបំពេញតម្រូវការផ្នែកព័ត៌មានរបស់ខ្លួនដែរឬទេ។ លទ្ធភាពនៃការធ្វើប្រតិបត្តិ ការរួមគ្នានៃកម្មវិធីអាចសន្សំសំចៃធនធានទៅលើផ្នែករបស់អ្នកផ្គត់ផ្គង់ដោយមិនចាំបាច់បំពេញកម្រង សំណួរផ្សេងគ្នា និងផ្តល់ឯកសារផ្ទៀងផ្ទាត់។ សហគ្រាសជាប់កាតព្វកិច្ចគួរធានាថាកម្មវិធី និងដំណោះស្រាយដែលខ្លួនប្រើប្រាស់គឺអាចប្រតិបត្តិការរួមគ្នាតាមដែលអាចធ្វើទៅបានជាមួយអ្នកផ្តល់សេវា ឧ. ដោយឱ្យសូហ្វវែរបញ្ជូលទិន្នន័យពីកម្មវិធីផ្សេងមួយទៀតតាមរយៈអ៊ិនធឺហ្វេស។

ការរួមគ្នានៃវិស័យជាក់លាក់ និងអន្តរវិស័យ អាចរួមចំណែកយ៉ាងសំខាន់នៅក្នុងការវិភាគហានិភ័យ ឧ. ការបង្កើតសេវា

សម្រាប់ការវិភាគហានិភ័យកម្រិតខ្ពស់ទាក់ទងនឹងផលិតផលជាក់លាក់ សេវាកម្ម ឬតំបន់ដែលពាក់ព័ន្ធជាពិសេសទៅនឹងសមាជិករបស់ខ្លួន។ សមាជិកអាចប្រើប្រាស់សេវានេះដើម្បីជំនួយ ដល់ការវិភាគហានិភ័យរបស់ខ្លួន។

ឧទាហរណ៍ទី 1

**ជំនួយក្នុងការវិភាគហានិភ័យពីសមាគមពាណិជ្ជកម្ម**

សមាគមពាណិជ្ជកម្ម A តំណាងឱ្យផលប្រយោជន៍សេដ្ឋកិច្ច ច្បាប់ និងនយោបាយនៃសហគ្រាសអាឡឺម៉ង់ចំនួន 800។ សមាជិករបស់ខ្លួនភាគច្រើនជាសហគ្រាសធុនតូច និង មធ្យម ប៉ុន្តែក៏រួមមានសហគ្រាសមួយចំនួនដែលមានបុគ្គលិកច្រើនជាង 1000 នាក់ ផងដែរ ដែលស្ថិតនៅក្នុងវិសាលភាពនៃច្បាប់ក្នុងឆ្នាំ 2024 ដោយហេតុនេះ ត្រូវបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវ។ សមាគម A ចង់ជួយសមាជិករបស់ខ្លួនក្នុងការបំពេញតាមច្បាប់ ដោយការឆ្លើយសំណួរទាក់ទងទៅនឹងច្បាប់ ផ្តល់ការណែនាំសម្រាប់វិស័យរបស់ខ្លួន និង ជំនួយសម្រាប់ការវិភាគហានិភ័យ និងកាតព្វកិច្ចត្រួតពិនិត្យភាពត្រូវផ្សេងទៀត។

មកដល់ចំណុចនេះ សមាគម A បានធ្វើការស្ទង់មតិ (ដោយស្ម័គ្រចិត្ត) ទៅលើផលិតផល សម្ភារៈ សមាសធាតុ និងប្រទេសដើម ក្នុងចំណោមសមាជិករបស់ខ្លួន។ ជាមួយនឹងព័ត៌មាន នេះ ប្រភពផ្សេងៗ និងអ្នកជំនាញក្នុងវិស័យ A បានធ្វើការសិក្សាប្រចាំឆ្នាំទៅលើហានិភ័យ នៃវិស័យ និងប្រទេសជាក់លាក់។ ការសិក្សារួមមាន ការស្ទង់មតិក្នុងចំណោមអ្នកដែលអាចរងផលប៉ះពាល់នៅក្នុងប្រទេសប្រភពផ្គត់ផ្គង់ដែលសំខាន់បំផុតនៃសមាជិករបស់ A។ បន្ទាប់មក ក្រុមការងារបានពិភាក្សា និងចងក្រងលទ្ធផល និងការយល់ដឹងនៅក្នុងការវាយ តម្លៃហានិភ័យនៃវិស័យជាក់លាក់។

សមាជិកទាំងអស់អាចចូលទៅប្រើប្រាស់ការវាយតម្លៃហានិភ័យបានតាមរយៈទម្រង់ដែលអាចចូលទៅប្រើប្រាស់បានដោយងាយស្រួលដែលផ្តល់ដោយសមាគម (ឧបករណ៍)។ សមាជិកអាចប្រើប្រាស់ការវាយតម្លៃហានិភ័យជាមូលដ្ឋានសម្រាប់ការវិភាគហានិភ័យជាក់ស្តែងរបស់ខ្លួន។ លើសពីនេះ ពួកគេអាចបញ្ចូលទិន្នន័យពីអ្នកផ្គត់ផ្គង់ដើម្បីទទួលបានការវាយតម្លៃបឋមទៅលើប្រទេស និងវិស័យជាក់លាក់សម្រាប់ការវាយតម្លៃហានិភ័យ អរូបិយរបស់ខ្លួន និងការណែនាំពីវិធីដោះស្រាយជាមួយអ្នកផ្គត់ផ្គង់។

សមាគមនេះចង្អុលបង្ហាញទៅកាន់សហគ្រាសជាសមាជិករបស់ខ្លួនថា នេះគ្រាន់តែជា ឧបករណ៍ជំនួយ និងមិនមែនសម្រាប់ជំនួសកាតព្វកិច្ចក្នុងការវិភាគហានិភ័យទេ។ ទាំងសមាជិកធុនតូច និងមធ្យម និងសមាជិកជាប់កាតព្វកិច្ចប្រើប្រាស់ឧបករណ៍របស់សមាគម ឧស្សាហកម្មនេះ សម្រាប់ការវាយតម្លៃហានិភ័យបឋម។ ក្រុមការងារត្រួតពិនិត្យប្រសិទ្ធភាព នៃឧបករណ៍ជាទៀងទាត់ និងធ្វើការផ្លាស់ប្តូរប្រសិនបើចាំបាច់។

សហគ្រាសជាប់កាតព្វកិច្ច ក៏អាចលើកសំណួរពាក់ព័ន្ធនឹងអ្នកផ្គត់ផ្គង់បន្តផងដែរ។ ជាទូទៅ តម្លាភាព និងចំណេះដឹងនៃខ្សែចង្វាក់ផ្គត់ផ្គង់ គឺជាគន្លឹះក្នុងការបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវ។ យ៉ាងណាមិញ អ្នកផ្គត់ផ្គង់ជារឿយៗភ័យខ្លាចថាព័ត៌មាននេះអាចនឹងត្រូវបានប្រើប្រាស់ដើម្បីមើលរំលងពួកគេ ពីខ្សែចង្វាក់ផ្គត់ផ្គង់។ នៅពេលផលិត សហគ្រាសជារឿយៗមានជំនាញនៅក្នុងដំណាក់កាលជាក់លាក់នៃខ្សែចង្វាក់តម្លៃ និងមិនសូវស្ទាក់ស្ទើរក្នុងការបង្ហាញអំពីប្រភពដើមនៃវត្ថុធាតុដើម ឬផលិតផល ពាក់កណ្តាលសម្រេចរបស់ខ្លួនឡើយ។ លក្ខខណ្ឌតម្រូវសម្រាប់តម្លាភាពនៃខ្សែចង្វាក់ផ្គត់ផ្គង់បង្កឱ្យមានហានិភ័យអាជីវកម្មគួរឱ្យកត់សម្គាល់ដល់ពាណិជ្ជករ និងអ្នកនាំចូល។ អ្នកផ្គត់ផ្គង់គួរចូលរួមនៅ ក្នុងកិច្ចសន្ទនាជាមួយនឹងសហគ្រាសជាប់កាតព្វកិច្ចដើម្បីបង្កើតការយល់ដឹងថាព័ត៌មានអ្វីខ្លះដែលត្រូវការពិតប្រាកដ។

**ព័ត៌មានស្តីពីទំនាក់ទំនងអាជីវកម្ម និងខ្សែចង្វាក់ផ្គត់ផ្គង់ ជាទូទៅត្រូវបានការពារជាព័ត៌មានសម្ងាត់ ពាណិជ្ជកម្ម។** វាក៏អាចកើតឡើងផងដែរដែលថា សហគ្រាសជាប់កាតព្វកិច្ចស្នើសុំព័ត៌មានដែលអ្នកផ្គត់ផ្គង់មិនត្រូវបានអនុញ្ញាតឱ្យបញ្ជូនបន្តព្រោះតែពួកគេបានប្តេជ្ញាចិត្តខ្លួនឯងចំពោះការរក្សាការសម្ងាត់ពីអ្នកផ្គត់ផ្គង់របស់ខ្លួន ឬដោយសារតែវាលប់លើច្បាប់ដែលមានជាធរមាន។

## ប្រអប់ព័ត៌មានទី5៖ ព័ត៌មានចំបាច់ (ក្នុងចំណោមព័ត៌មានផ្សេងទៀត) សម្រាប់ការវិភាគហានិភ័យ

- ព័ត៌មានស្តីពីហានិភ័យ និងការបំពានដែលបានកំណត់
- ក្នុងករណីហានិភ័យ និងការបំពាន៖
    - ព័ត៌មានអំពីប្រទេស ឬតំបន់ កម្រិតនៃខ្សែចង្វាក់តម្លៃ
    - សកម្មភាពសេដ្ឋកិច្ចទាក់ទងនឹងហានិភ័យ ឬការបំពាន
    - ចំនួនអ្នករងផលប៉ះពាល់ ទំហំនៃតំបន់បរិស្ថានដែលរងផលប៉ះពាល់
    - វិធានការទប់ស្កាត់ និងកែប្រែណាខ្លះដែលបានអនុវត្តហើយ ប្រសិនបើអាចអនុវត្តបាន
- ព័ត៌មានអំពីថាតើអ្នកផ្គត់ផ្គង់បានធ្វើការវិភាគហានិភ័យដោយខ្លួនឯងដែរទេ និងវិធីសាស្រ្ត
- ព័ត៌មានអំពីវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និងសេវាកម្មដែលបានប្រើប្រាស់ដើម្បី បង្កើតផលិតផល ឬសេវាកម្ម៖ តើពួកវាមកពីប្រទេសណា? តើពួកគេទទួលបានវត្ថុធាតុដើម ផលិតផលពាក់កណ្តាលសម្រេច និងផលិតផលដែលផលិតរួចរាល់ ដោយរបៀបណា? (សម្រាប់គ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផ្គត់ផ្គង់)
- សវនកម្ម និងឯកសារបញ្ជាក់ទាក់ទងនឹងបរិវេណរបស់អ្នកផ្គត់ផ្គង់ ប្រសិនបើមាន (កិច្ចព្រមព្រៀងរក្សាការសម្ងាត់អាចនឹងចាំបាច់ផងដែរ)។[44]

[44] សូមមើលប្រអប់ព័ត៌មានទី 4 ទាក់ទងនឹងតួនាទីនៃស្តង់ដារ និងការបញ្ជាក់។

នៅក្នុងបរិបទនៃការវិភាគហានិភ័យសហគ្រាសជាប់កាតព្វកិច្ច អាចសុំការអនុញ្ញាតិពីអ្នកផ្គត់ផ្គង់របស់ខ្លួន ដើម្បីចុះទៅកាន់ទីតាំងរបស់ពួកគេដើម្បីធ្វើសវនកម្ម។ ពេលខ្លះ សហគ្រាសជាប់កាតព្វកិច្ច នៅក្នុងបរិបទនេះព្យាយាមទាញយកសិទ្ធិគ្រប់គ្រងទូលំទូលាយទៅលើអ្នកផ្គត់ផ្គង់តាមរយៈការព្រមព្រៀងបែបកិច្ចសន្យា ឧទាហរណ៍ នៅក្នុងលក្ខខណ្ឌនៃក្រមប្រតិបត្តិ។ ការធ្វើបែបនេះបណ្តាលឱ្យមានផលវិបាកក្នុងការអនុវត្ត។ អ្នកផ្គត់ផ្គង់ជាញឹកញាប់ មិនមានឆន្ទៈ ឬអាចផ្តល់សិទ្ធិគ្រប់គ្រងបែបនេះទៅឱ្យសហគ្រាស ជាប់កាតព្វកិច្ចទេ។ សិទ្ធិធ្វើសវនកម្ម និងគ្រប់គ្រងហួសហេតុ អាចគ្មានសុពលភាពស្របតាមច្បាប់កិច្ចសន្យា។[45] ដូចនេះ អ្នកផ្គត់ផ្គង់គួរពិនិត្យកិច្ចព្រមព្រៀងបែបនេះយ៉ាងប្រុងប្រយ័ត្នតាមទស្សនៈផ្លូវច្បាប់ ជាពិសេសទាក់ទងនឹង គុណវិបត្តិមិនសមហេតុផល ឬការទាមទារហួសហេតុ។

ទោះបីជាអ្នកផ្គត់ផ្គង់មិនចាំបាច់សហការជាមួយដៃគូអាជីវកម្មរបស់ខ្លួនយោងតាមច្បាប់ក៏ដោយ វាអាចជា សម្ពាធដល់ទំនាក់ទំនងអាជីវកម្មនៅពេលដែលពួកគេបដិសេធទាំងស្រុងក្នុងកិច្ចសហការទៅនឹងការស្នើសុំព័ត៌មាន ដោយសារតែសហគ្រាសជាប់កាតព្វកិច្ចជាទូទៅពឹងផ្អែកលើព័ត៌មានពីអ្នកផ្គត់ផ្គង់របស់ខ្លួនដើម្បី បំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវខ្លួន។ សហគ្រាសមិនជាប់កាតព្វកិច្ចមានសេរីភាពក្នុងការបំពេញ ឬមិនបំពេញតាមតម្រូវការទាំងនេះ ហើយគួរអនុវត្តដោយប្រុងប្រយ័ត្ន និងតាមវិធីដែលកាត់បន្ថយទិន្នន័យ នៅពេលដោះស្រាយជាមួយការស្នើសុំបែបនេះ។

អ្នកផ្គត់ផ្គង់គួរសួរថាតើអតិថិជនរបស់ខ្លួនស្នើសុំព័ត៌មានក្នុងគោលបំណងអ្វី ដើម្បីធ្វើការសម្រេចចិត្តបានគ្រប់ ជ្រុងជ្រោយថាតើពួកគេអាចផ្តល់ការយល់ដឹងអ្វីខ្លះទៅលើខ្សែចង្វាក់ផ្គត់ផ្គង់ និងខ្សែចង្វាក់តម្លៃរបស់ខ្លួន និងថាតើអាចផ្តល់ឱ្យបានត្រឹមកម្រិតណា។ ពួកគេក៏គួរបិទបាំងព័ត៌មានរសើប និងធានាបែបកិច្ចសន្យា ចំពោះការប្រើប្រាស់ព័ត៌មានថាសម្រាប់តែគោលបំណងជាក់លាក់ ក៏ដូចជាការរក្សាការសម្ងាត់តាមរយៈ កិច្ចព្រមសន្យារក្សាការសម្ងាត់ (NDA)។ វាក៏អាចកើតឡើងផងដែរដែលថាទំនាក់ទំនងកិច្ចសន្យារយៈ ពេលវែងអាចរំងាប់ក្តីកង្វល់របស់អ្នកផ្គត់ផ្គង់អំពីការត្រូវបានមើលរំលងនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ ដោយមាន ជំនួយពីព័ត៌មានដែលបានទទួលពីការវិភាគហានិភ័យ។

គោលដៅ គឺការសន្ទនាដោយឈរលើមូលដ្ឋាននៃភាពស្មើគ្នាដើម្បីដោះស្រាយភាពតានតឹងនេះ។ ក្នុងការធ្វើ កិច្ចការនេះ សហគ្រាសជាប់កាតួកិច្ចគួរពិចារណាផលប្រយោជន៍ពាក់ព័ន្ធដែលមានទៅតាមបរិបទ រៀងៗខ្លួន។ វិធីសាស្ត្រដែលអាចមានអាចថាអ្នកផ្គត់ផ្គង់មិនជាប់កាតព្វកិច្ចបង្ហាញតែទិន្នន័យជាក់លាក់ (ឧ. បញ្ជូនបន្តលទ្ធផលសវនកម្មដោយមិនដាក់ឈ្មោះអ្នកផ្គត់ផ្គង់បន្ត ឬប្រើប្រាស់វេទិកាអន្តរការី) ឬថាសហគ្រាស ជាប់កាតព្វកិច្ចផ្តល់ឱ្យពួកគេនូវឧបករណ៍ និងធនធាន (ហិរញ្ញវត្ថុ) ដែលពួកគេអាចវិភាគ និងដោះស្រាយហានិភ័យនៅក្នុងខ្សែចង្វាក់ខាងលើបានកាន់តែប្រសើរដោយខ្លួនឯង។

[45] សូមមើលផ្នែក 307 ទ 1 ប្រយោគទី 1 ទ 2 នៃក្រមរដ្ឋប្បវេណីអាឡឺម៉ង់

RESPONSIBLE BUSINESS HUB CAMBODIA
RBH NETWORK

### ប្រអប់ព័ត៌មានទី6៖ របៀបបន្តដំណើរការព័ត៌មានសើប

- វាយតម្លៃថាតើព័ត៌មានណាដែលត្រូវការ
- ការបិទបាំងព័ត៌មានជាក់លាក់មួយចំនួន
  - ដែលមិនត្រូវការសម្រាប់គោលបំណងនៃការស្នើសុំ
  - នៅពេលដែលមានផលប្រយោជន៍ផ្លូវច្បាប់ក្នុងការការពារព័ត៌មាននោះ (អាថ៌កំបាំងពាណិជ្ជកម្ម)
  - នៅពេលដែល NDA រួមជាមួយនឹងអ្នកផ្គត់ផ្គង់ប្រយោលហាមមិនឱ្យបង្ហាញព័ត៌មាន
  - នៅពេលដែលច្បាប់ពាក់ព័ន្ធជាអាទិភាពហាមឃាត់ការបង្ហាញព័ត៌មាន
- ការការពារព័ត៌មានសើបតាមរយៈកិច្ចព្រមព្រៀងរក្សាការសម្ងាត់៖
  - មិនត្រូវធ្វើការចែករំលែកព័ត៌មាន
  - ព័ត៌មានអាចត្រូវបានប្រើប្រាស់សម្រាប់តែគោលបំណងជាក់លាក់មួយចំនួន
  - ទំនាក់ទំនងចំពោះតែតួអង្គជាក់ជាក់មួយចំនួន

3

## 2. វិធីសាស្ត្រសម្រាប់វិធានការទប់ស្កាត់

នៅពេលសហគ្រាសជាប់កាតព្វកិច្ចសុំឱ្យអ្នកផ្គត់ផ្គង់របស់ខ្លួនឱ្យចុះហត្ថលេខាលើកិច្ចសន្យាព្រមព្រៀង ពួកគេគួរតែវាយតម្លៃទៅលើចំណុចដែលចាំបាច់ដោយប្រុងប្រយ័ត្ន ថាតើអ្នកផ្គត់ផ្គង់អាចបំពេញវាបានឬទេ និងថាតើកិច្ចសន្យាមានតុល្យភាពឬទេ។ ជាទូទៅអ្នកផ្គត់ផ្គង់គួតែប្រុងប្រយ័ត្ននៅពេលធានាតាមកិច្ចសន្យាទៅលើស្ថានភាពដែលពួកគេមិនបានដឹង ឬមិនអាចគ្រប់គ្រងបាន។ទោះបីអ្នកផ្គត់ផ្គង់ទំនងជាស៊ាំទៅនឹងស្ថានភាពនៅក្នុងប្រភេទអាជីវកម្មរបស់ពួកគេក៏ដោយ ក៏អ្នកផ្គត់ផ្គង់ប្រហែលជាមានចំណេះដឹងតិចតួចពាក់ព័ន្ធនឹងអ្នកផ្គត់ផ្គង់បន្ត ឬខ្សែចង្វាក់ផ្គត់ផ្គង់ដែលមានភាពស៊ីជម្រៅជាងនេះ។

**ការធានាថាបានបំពេញតាមតម្រូវការបទដ្ឋានជាក់លាក់អាចបណ្តាលឱ្យមានការទាមទារតាមកិច្ចសន្យា។** សហគ្រាសគួរមានការប្រុងប្រយ័ត្នជាពិសេសប្រសិនបើពួកគេត្រូវទទួលខុសត្រូវចំពោះកាលៈទេសៈជាក់លាក់មួយចំនួន។ ច្បាប់មិនបានបង្កើតស្តង់ដារទទួលខុសត្រូវឯករាជ្យរវាងគូភាគីនៃកិច្ចសន្យាតាមខ្សែចង្វាក់ ផ្គត់ផ្គង់ទេ។ ទោះជាយ៉ាងណា វាអាចទៅរួចដែលអ្នកផ្គត់ផ្គង់ត្រូវទទួលខុសត្រូវចំពោះកំហុស ឬការធានាដែលមិនបានបំពេញ។ ដូចនេះ គូភាគីគួរវាយតម្លៃយ៉ាងប្រុងប្រយ័ត្នថាតើវិធានការមួយណា ជាពិសេស សមិទ្ធផលដែលពួកគេត្រូវប្តេជ្ញាចិត្តធ្វើនៅក្នុងបរិបទនៃការកែតម្រូវកិច្ចសន្យាដែលត្រឹមត្រូវតាមច្បាប់។ អ្នកផ្គត់ផ្គត់គួរស្វែងរកការណែនាំផ្លូវច្បាប់ផ្ទាល់ខ្លួនប្រសិនបើចាំបាច់។ លើសពីនេះ សហគ្រាសអាចត្រូវទទួលខុសត្រូវចំពោះការផ្សព្វផ្សាយបំភាន់ដែលចុងក្រោយមិនបានបំពេញតាមស្តង់ដារ ដោយមិនគិតពីទំនាក់ទំនងរបស់អ្នកផ្គត់ផ្គង់ឡើយ។ ពួកគេក៏អាចនឹងត្រូវទទួលខុសត្រូវផងដែរពាក់ព័ន្ធ នឹងអ្នកប្រើប្រាស់ចុងក្រោយ (ដរាបណាមានទំនាក់ទំនងតាមកិច្ចសន្យា) ផងដែរ។ ដូចនេះការត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នតែងតែត្រូវបានណែនាំនៅពេលមានការលើកឡើងពីស្តង់ដារជាក់លាក់ និងលក្ខខណ្ឌ តម្រូវរបស់ខ្លួន។

សហគ្រាសជាប់កាតព្វកិច្ចគួរភ្ជាប់យន្តការត្រួតពិនិត្យ ការបណ្តុះបណ្តាល និងការអប់រំបន្ត ទៅនឹងការ ធានាតាមកិច្ចសន្យាស្របពេលធ្វើការតាមដានថ្លៃចំណាយសម្រាប់វិធានការត្រួតពិនិត្យដូចជាការធ្វើសវនកម្មដើម្បីជៀសវាងការប៉ះទង្គិចគ្នារវាងគោលបំណងនានា។ អ្នកផ្គត់ផ្គង់ប្រហែលជាមិនអាចរ៉ាប់រងថ្លៃ ចំណាយដែលបានបង្កើតឡើងដោយការបំពេញតាមស្តង់ដារ និងអនុវត្តដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវនៅពេលដែលតម្លៃមិនមានការប្រែប្រួល។ សហគ្រាសជាប់កាតព្វកិច្ចគួរផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើផលប៉ះពាល់នៃថ្លៃដើមសម្រាប់អ្នកផ្គត់ផ្គង់នៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ឱ្យកាន់តែស៊ីជម្រៅដែលពួកគេអាចមានជំហរក្នុងការចរចារដែលខ្សោយជាង។ អ្នកផ្គត់ផ្គង់អាចជួបការលំបាកក្នុងការរ៉ាប់រងថ្លៃចំណាយលើសុខភាព និងសុវត្ថិភាពការងារ ការការពារបរិស្ថាន និងប្រាក់ឈ្នួលសមរម្យ។ ហេតុនេះ សហគ្រាសជាប់កាតព្វកិច្ចជានិច្ចកាលគួរពិចារណាទៅលើយុទ្ធសាស្ត្រ លទ្ធកម្ម និងទម្លាប់នៃការទិញរបស់ខ្លួន។

ឧទាហរណ៍ទី 2

## ការបណ្តុះបណ្តាលអ្នកផ្គត់ផ្គង់ស្តីពីក្រមប្រតិបត្តិ

សហគ្រាសជាប់កាតព្វកិច្ចមួយកំពុងធ្វើការជួញដូរផ្លែឈើតំបន់ត្រូពិច ហើយមានអ្នក ផ្គត់ផ្គង់ជាច្រើននៅក្នុងបណ្តាប្រទេសនៃសកលលោកខាងត្បូង ដែលប្រទេសខ្លះជា ប្រទេសដែលមានហានិភ័យខ្ពស់។ បុគ្គលិកគ្មានជំនាញ ឬមានជំនាញទាបជាញឹកញាប់ ត្រូវបានប្រើប្រាស់នៅក្នុងការប្រមូលផលផ្លែឈើ អាជីវកម្មជាច្រើនប្រើប្រាស់កម្មករតាមរដូវកាល និងកម្មករចំណាកស្រុក។ អំឡុងពេលនៃការវិភាគហានិភ័យសហគ្រាសបានសង្កេតឃើញថាមានហានិភ័យខ្ពស់ក្នុងការការពារជំហរផ្លូវច្បាប់ជាពិសេសពាក់ព័ន្ធនឹងពលកម្មដោយបង្ខំ ពលកម្មកុមារ សុវត្ថិភាព និងសុខភាពប្រតិបត្តិការ ប្រាក់ឈ្នួលរស់ នៅសមរម្យ សេរីភាពក្នុងការបង្កើតសមាគម និងសិទ្ធិក្នុងការ ចរចាជាសមូហភាព និងការរំលោភបំពានតាមរយៈការប្រើប្រាស់កម្លាំងសន្តិសុខ។

ជាជំហានដំបូង សហគ្រាសចង់ផ្ញើក្រមប្រតិបត្តិរបស់ខ្លួនទៅឱ្យដៃគូអាជីវកម្មដែល មានហានិភ័យខ្ពស់។ គោលបំណងគឺទាំងការគ្រប់គ្រងជារួមនៃកិច្ចសហការក្នុងការ បំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវ និងដើម្បីកំណត់លក្ខខណ្ឌតម្រូវអប្បបរិ មាក្នុងការអនុលោមទៅនឹងសិទ្ធិនៅកន្លែងធ្វើការ និងដើម្បីកំណត់គោលដៅដើម្បីធ្វើ ការឆ្ពោះទៅមុខ។ សហគ្រាសដឹងថាការជានាថាគ្មានហានិភ័យ ឬការរំលោភបំពាន មិនមានភាពពិតប្រាកដពាក់ព័ន្ធនឹងហានិភ័យដែលបានកំណត់រួចមកហើយនោះទេ។ ហើយសហគ្រាសក៏បានសន្និដ្ឋានផងដែរថាមិនមែនអ្នកផ្គត់ផ្គង់ទាំងអស់អាចយល់ពីក្រម ប្រតិបត្តិ និងសារតៈរបស់វានោះទេ។ លើសពីនេះ សហគ្រាសក៏ភ័យខ្លាចថាអ្នកផ្គត់ផ្គង់ អាចនឹងព្យាយាមលាក់បាំងបញ្ហាដោយសារតែខ្លាចបាត់បង់ផលប្រយោជន៍ ដែលជា លទ្ធផលធ្វើឱ្យរាំងដល់ការបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវ។ ពួកគេ បារម្ភថាអ្នកផ្គត់ផ្គត់មួយចំនួនអាចបដិសេធក្នុងការចុះហត្ថលេខាលើក្រមប្រតិបត្តិ និងបដិសេធកិច្ចសហការ ព្រោះពួកគេមិនមានកាតព្វកិច្ចផ្លូវច្បាប់នោះទេ។

ដើម្បីទប់ស្កាត់បញ្ហាទាំងនេះ សហគ្រាសមិនត្រឹមតែត្រូវធ្វើឱ្យប្រាកដថាក្រមប្រតិបត្តិបាន រៀបរាប់ពីនីតិវិធីត្រួតពិនិត្យភាពត្រឹមត្រូវថាជាកិច្ចការរួមនៅក្នុងន័យការទទួលខុសត្រូវរួម និងដើម្បីឱ្យសិទ្ធិក្នុងការបញ្ចប់កិច្ចសន្យាជាជម្រើសចុងក្រោយនៅក្នុងករណី ដែលមានការរំលោភបំពានធ្ងន់ធ្ងរប៉ុណ្ណោះ ហើយលុះត្រាតែអ្នកផ្គត់ផ្គង់បដិសេធក្នុងការ សហការ ឬការកែលម្អមិនបានកើតឡើងទោះព្យាយាមម្តងហើយម្តងទៀតក្តី។ សហគ្រាសក៏ចង់ជួយឱ្យអ្នកផ្គត់ផ្គង់របស់ខ្លួនអាចបំពេញកាតព្វកិច្ចដែលកើតចេញពីក្រមប្រតិបត្តិដែលដំបូងបំផុតតម្រូវឱ្យមានការយល់ដឹងរួមគ្នាពីនីតិវិធីត្រួតពិនិត្យភាពត្រឹមត្រូវ និងកិច្ចសហការតាមអត្ថន័យនៃក្រមប្រតិបត្តិ។

មកដល់ចំណុចនេះ សហគ្រាសមិនត្រឹមតែផ្ញើក្រមប្រតិបត្តិរបស់ខ្លួនទៅកាន់អ្នកផ្គត់ផ្គង់តែប៉ុណ្ណោះទេ ប៉ុន្តែក៏បានផ្តល់នូវការបណ្តុះបណ្តាលដោយធ្វើថ្លៃចំណាយផ្ទាល់ខ្លួនផងដែរ។ ការបណ្តុះបណ្តាលគ្រប់ដណ្តប់ទៅលើច្បាប់ស្តីពីការត្រួតពិនិត្យភាពត្រឹម ត្រូវក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ និងតម្រូវការដែលជាលទ្ធផលពី សហគ្រាសក្នុងកិច្ចសហការជាមួយអ្នកផ្គត់ផ្គង់របស់ខ្លួន។ បន្ថែមពីនេះ ការបណ្តុះបណ្តាលពន្យល់ពីខ្លឹមសារនៃក្រមប្រតិបត្តិ ការរំពឹងទុករបស់សហគ្រាស និងរបៀបដែលពួកគេអាចសហការគ្នាដើម្បីបំពេញកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវក្នុងរូបភាពជាការទទួលខុសត្រូវរួម។

## ប្រអប់ព័ត៌មានទី7៖ សំណួរដើម្បីវាយតម្លៃការអនុវត្តលទ្ធកម្ម និងការទិញ

- មានការពិចារណាទៅលើថ្លៃចំណាយសម្រាប់ការគោរពសិទ្ធិមនុស្ស និងបរិស្ថានដែរឬទេ (ឧ. ដោយផ្នែក និងជាកញ្ចប់នៅក្នុងការចរចាតម្លៃ)?
- តើថ្លៃចំណាយដែលអាចកើនឡើង ឧទាហរណ៍ ដោយសារតែការកើនឡើងនៃប្រាក់ឈ្នួល អប្បបរិមា ការកើនឡើងនៃថ្លៃចំណាយរស់នៅ ឬអតិផរណា (ឧ. ជាមួយនឹងលក្ខខណ្ឌក្នុង ការតម្លើងថ្លៃ) ត្រូវបានយកមកពិចារណាដែរ ឬទេ?
- តើថ្លៃចំណាយសម្រាប់ប្រាក់ឈ្នួលសម្រាប់ការរស់នៅសមរម្យត្រូវបានរាប់បញ្ចូលដោយរបៀបណា?
- តើមានការប៉ាន់ប្រមាណទៅលើថ្លៃចំណាយសម្រាប់វិធានការជួចជាសវនកម្ម ឬការបណ្តុះបណ្តាល ដែលត្រូវបានធ្វើឡើងជាប្រយោជន៍ដល់ក្រុមហ៊ុនជាប់កាតព្វកិច្ចត្រូវបានប៉ាន់ប្រមាណដែរឬទេ?
- តើការផ្តល់ការលើកទឹកចិត្តជាហិរញ្ញវត្ថុដល់អ្នកផ្គត់ផ្គង់ត្រូវបានភ្ជាប់ទៅនឹងការកែលម្អជាបន្តពាក់ព័ន្ធនឹងកាតព្វកិច្ចសិទ្ធិមនុស្ស និងបរិស្ថាន (ឧ. តាមរយៈការធានាសម្រាប់ការបញ្ជាទិញបន្ថែម រយៈពេលកិច្ចសន្យាដែលយូរជាងមុន ឬបរិមាណការទិញដែលច្រើនជាងមុន) ដែរឬទេ?
- តើលក្ខខណ្ឌនៃកិច្ចសន្យាត្រូវបានរៀបចំឡើងតាមវិធីដែលមិនបង្កើតជាបន្ទុកដែលមិនសមាមាត្រចំពោះអ្នកផ្គត់ផ្គង់ (ឧ. តាមរយៈលក្ខខណ្ឌបង់ប្រាក់ដែលមិនយុត្តិធម៌ ការបង់ប្រាក់ដែលមិន ពាក់ព័ន្ធជាក់លាក់ទៅនឹងការលក់ផលិតផលរបស់អ្នកផ្គត់ផ្គង់ ឬលក្ខខណ្ឌក្នុងការផ្លាស់ប្តូរ ឬលុបចោលការបញ្ជាទិញ) ដែរឬទេ?
- តើរយៈពេលនៃការរង់ចាំ និងលក្ខណៈបច្ចេកទេសផលិតផល បានរៀបចំឡើងតាមវិធីដែល អ្នកផ្គត់ផ្គង់អាចបំពេញបានដោយមិនមានការរំលោភសិទ្ធិ (ជាពិសេស ម៉ោងធ្វើការ) ដែរឬទេ? (ដើម្បីជៀសវាងការរំលោភសិទ្ធិ ជាឧទាហរណ៍ កិច្ចសន្យាអាចអនុញ្ញាតឱ្យអ្នកផ្គត់ផ្គង់បដិសេធ ការបំពេញការងារ ឬចុះកិច្ចសន្យាបន្តពាក់ព័ន្ធនឹងសិទ្ធិក្នុងការបដិសេធដោយហេតុផលសិទ្ធិ មនុស្ស។)
- តើការលើកទឹកចិត្តអ្វីខ្លះដែមានផ្តល់នៅក្នុងលក្ខខណ្ឌនៃកិច្ចសន្យា (លក្ខខណ្ឌកិច្ចសន្យាដែលមានរយៈពេលខ្លីមិនអនុញ្ញាតឱ្យអ្នកផ្គត់ផ្គង់វិនិយោគទៅលើប្រតិបត្តិការសុវត្ថិភាព និងសុខភាព ឬការការពារបរិស្ថានឡើយ)?
- តើមានការលើកទឹកចិត្តអ្វីខ្លះដែលផ្តល់ជូនដោយសិទ្ធិបញ្ចប់កិច្ចសន្យា? តើផលប៉ះពាល់អវិជ្ជមាន ទៅលើសិទ្ធិមនុស្ស និងបរិស្ថានត្រូវបានកំណត់ និងដោះស្រាយថាអាចបណ្តាលឱ្យមានការបញ្ចប់ កិច្ចសន្យាដែរឬទេ?

សហគ្រាសជាប់កាតព្វកិច្ចអាចសហការជាមួយអ្នកផ្គត់ផ្គង់របស់ខ្លួន និងតួអង្គផ្សេងទៀតដើម្បីអនុវត្តវិធាន ការបង្ការទៅលើអ្នកផ្គត់ផ្គង់ប្រយោល។ ប្រសិនបើអ្នកផ្គត់ផ្គង់មិនចង់ចែករំលែកព័ត៌មានដែលអាចឱ្យមានការ recourse ទៅលើអត្តសញ្ញាណរបស់អ្នកផ្គត់ផ្គង់បន្ត សហគ្រាសជាប់កាតព្វកិច្ចអាចជួយអ្នកផ្គត់ផ្គង់របស់ពួក គេដោយការអនុវត្តវិធានការទប់ស្កាត់ជំនួសវិញ។ សហគ្រាសជាប់កាតព្វកិច្ចអាចនឹងចង់អនុវត្តវិធានការទប់ស្កាត់ ទៅលើអ្នកអ្នកផ្គត់ផ្គង់ប្រយោលដោយខ្លួនឯងផ្ទាល់ ឧទាហរណ៍ ដោយឱ្យអ្នកផ្គត់ផ្គង់បន្តព្រមព្រៀង អនុវត្តតាមក្រមប្រតិបត្តិ។ នៅក្នុងករណីភាគច្រើនការអនុវត្តវិធានការទប់ស្កាត់ទៅលើអ្នកផ្គត់ផ្គង់បន្តអាចធ្វើ ទៅបាននៅពេលដែលសហគ្រាសជាប់កាតព្វកិច្ចស្គាល់អ្នកផ្គត់ផ្គង់ប្រយោលនេះហើយពួកគេអាចទាក់ទងគ្នាបាន។ អ្នកផ្គត់ផ្គង់នៅក្នុងករណីនេះគួររំពឹងឱ្យអតិថិជនរបស់ខ្លួនស្នើសុំព័ត៌មានទាំងនេះ។

លើសពីនេះ សហគ្រាសជាប់កាតព្វកិច្ចត្រូវធានាថាពួកគេបានប្រកាសពីវិធានការទប់ស្កាត់ទៅកាន់អ្នកផ្គត់ផ្គង់ របស់ខ្លួនដោយផ្តល់រយៈពេលគ្រប់គ្រាន់ដែលអាចឱ្យពួកគេសម្របខ្លួនទៅនឹងស្ថានភាពថ្មី។ ជាទូទៅ ការយោងទៅលក្ខខណ្ឌតម្រូវផ្នែកច្បាប់នៃច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវតែម្យ៉ាងមិនគ្រប់គ្រាន់នោះទេ។

## ប្រអប់ព័ត៌មានទី ៨៖ សំណួរសម្រាប់កិច្ចសហការទៅលើវិធានការទប់ស្កាត់

- តើអ្នកផ្គត់ផ្គង់ត្រូវបានស្នើសុំឱ្យធានាពីស្ថានភាពដែលពួកគេមិន ឬអាចនឹងមិនដឹងដែរ ឬទេ?
- តើការធានាបែបកិច្ចសន្យាត្រូវបានថ្លឹងថ្លែងឱ្យស្មើគ្នាក្នុងន័យការទទួលខុសត្រូវរួមដែរ ឬទេ?
- តើថ្លៃចំណាយទៅលើវិធានការត្រួតពិនិត្យ (ឧ.សវនកម្ម) ត្រូវបានចែករំលែកដោយសមស្របដែរ ឬទេ?
- តើសហគ្រាសមានកាតព្វកិច្ច និងអ្នកផ្គត់ផ្គង់សហការគ្នាទៅលើវិធានការទប់ស្កាត់ទៅលើអ្នកផ្គត់ផ្គង់ ប្រយោលតាមវិធីដែលសមហេតុផលដែរ ឬទេ?
    - តើអ្នកផ្គត់ផ្គង់ត្រូវតែទទួលខុសត្រូវតែម្នាក់ឯងឬបន្ទុកនៃថ្លៃចំណាយត្រូវបានថ្លឹងថ្លែងឱ្យស្មើគ្នា?
    - លក្ខខណ្ឌតម្រូវសម្រាប់ការបង្ហាញព័ត៌មានដែលកំណត់អត្តសញ្ញាណអ្នកផ្គត់ផ្គង់ខាងលើ៖
        - កិច្ចព្រមព្រៀងរក្សាការសម្ងាត់ រួមមានដូចជា ការប្រើប្រាស់ការពិន័យដោយចេតនា ឬបែបកិច្ចសន្យា ប្រសិនបើចាំបាច់។
        - ការធានារលើកិច្ចសហការបន្តប្រសិនបើមានការរាយការណ៍អំពីការរំលោភបំពាន ហើយវិធីសាស្ត្រក្នុងការកែលម្អបានបង្ហាញដើម្បីជៀសវៀសការសម្ងាត់ពាក់ព័ន្ធនឹងការរំលោភបំពានដែលមានស្រាប់។

ប្រសិនបើអ្នកផ្គត់ផ្គង់បានអនុវត្តវិធានការទប់ស្កាត់ទៅលើអ្នកផ្គត់ផ្គង់របស់ខ្លួនរួចហើយ សហគ្រាសជាប់ កាតព្វកិច្ចគួរវាយតម្លៃថាតើវិធានការទាំងនេះកាត់បន្ថយហានិភ័យបានពេញលេញឬទេ។ ប្រសិនបើមិនដូច្នោះទេ ពួកគេគួរវិភាគបន្ថែមថាតើលក្ខណៈវិនិច្ឆ័យសម្រាប់ភាពសមស្របតម្រូវឱ្យពួកគេអនុវត្តវិធានការ ផ្ទាល់ខ្លួនបន្ថែមដែរឬទេ។

## ប្រអប់ព័ត៌មានទី ១៖ ការផ្តល់លទ្ធភាពមុនដកកិច្ចសន្យា

ច្បាប់នេះតម្រូវឱ្យសហគ្រាសបញ្ចប់ទំនាក់ទំនងពាណិជ្ជកម្មស្ថិតក្រោមលក្ខខណ្ឌចាំបាច់មួយចំនួន និងជាជម្រើសចុងក្រោយតែប៉ុណ្ណោះ។ ច្បាប់នេះមិនមានបំណងឱ្យសហគ្រាសដកខ្លួនចេញពី ស្ថានភាពដែលពិបាកនោះទេ។ ការបញ្ចប់ទំនាក់ទំនងពាណិជ្ជកម្ម គឺមិនមានភាពចាំបាច់សម្រាប់ ការកាត់បន្ថយហានិភ័យ ឬបញ្ចប់ការរំលោភបំពាននោះទេ។ ផ្ទុយទៅវិញការធ្វើបែបនេះអាចបង្កើត ទៅជាហានិភ័យបន្ថែម និងបណ្តាលឱ្យស្ថានភាពរស់នៅ និងការងារកាន់តែមានភាពយ៉ាប់យឺន ទៅវិញទេ។ ការបញ្ចប់ទំនាក់ទំនងពាណិជ្ជកម្មត្រូវធ្វើឡើងតែក្នុងករណី៖

1. សហគ្រាសជាប់កាតព្វកិច្ចវាយតម្លៃការរំលោភបំពាននៃជំហរផ្លូវច្បាប់ដែលបានការពារថា មានកម្រិតធ្ងន់ធ្ងរ
2. ការអនុវត្តវិធានការដែលបានបង្កើតឡើង ជាមួយអ្នកផ្គត់ផ្គង់ នៅក្នុងទស្សនៈមិនបានផ្តល់សំណងបន្ទាប់ពីពេលវេលាដែលបានបញ្ជាក់នៅក្នុងទស្សនៈ
3. សហគ្រាសមិនមានវិធីផ្សេងដែលស្រាលជាងនេះ
4. បង្កើតសមត្ថភាពក្នុងការបញ្ចេញឥទ្ធិពលមិនមានឱកាសជោគជ័យ។ [46]

គួរកត់សម្គាល់ថា ការពិតដែលរដ្ឋមិនបានផ្តល់សច្ចាប័នទៅលើអនុសញ្ញាណាមួយដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ ឬមិនបានអនុវត្តអនុសញ្ញាទាំងនោះនៅក្នុងច្បាប់ជាតិ មិនបណ្តាលឱ្យមានកាតព្វកិច្ចក្នុងការបញ្ចប់ទំនាក់ទំនងពាណិជ្ជកម្មដោយស្វ័យប្រវត្តិទេ។

## 3. វិធីសាស្ត្រសម្រាប់វិធានការតម្រូវ

ប្រសិនបើសហគ្រាសជាប់កាតព្វកិច្ចចង់រៀបចំផែនការ ឬអនុវត្តវិធានការតម្រូវទៅលើអ្នកផ្គត់ផ្គង់ យ៉ាងហោចណាស់ត្រូវមានការយល់ព្រមពីពួកគេ។ ការអនុវត្តវិធានការទាំងនោះអាចនឹងតម្រូវឱ្យមានការ ចូលទៅកាន់ទីតាំងរបស់អ្នកផ្គត់ផ្គង់ដើម្បីបង្កើតការផ្លាស់ប្តូរ ដោយអាចធ្វើទៅបានដោយមានការយល់ព្រម ពីអ្នកផ្គត់ផ្គង់។ នៅក្នុងករណីភាគច្រើន អ្នកផ្គត់ផ្គង់នឹងមិនអាចសម្រេចការកែប្រែបានដោយគ្រាន់តែណែនាំ ឱ្យអ្នកផ្គត់ផ្គង់របស់ខ្លួនឱ្យបញ្ចប់សកម្មភាពមួយចំនួននោះទេ។ ផ្ទុយទៅវិញ ជាញឹកញាប់ការកែប្រែអាច សម្រេចទៅបានដោយការរួមបញ្ចូលគ្នានូវវិធានការស្មុគស្មាញជាច្រើន។ នៅក្នុងករណីជាច្រើន សហគ្រាសជាប់កាតព្វកិច្ចក៏ត្រូវការព័ត៌មានដើម្បីបង្កើតវិធានការ មិនថាជាវិធានការតែមួយ ឬផែនការវិធានការនោះទេ។ ព័ត៌មានណាដែលត្រូវការជាពិសេស វាខុសគ្នាអាស្រ័យការបំពាន ដែលបានកំណត់ និងវិធានការតម្រូវដែលចាំបាច់។ ការដោះស្រាយបញ្ហាសុវត្ថិភាពប្រតិបត្តិការ និងការការពារសិទ្ធិមនុស្ស ឬបរិស្ថាន អាចត្រូវការព័ត៌មានបច្ចេកទេសលម្អិត។

វាអាចកើតឡើងបានដែលការកែប្រែរួមមាន ជាឧទាហរណ៍ ការផ្តល់សំណងដល់អ្នកដែលរងផលប៉ះពាល់ ព្រោះសុខភាពរបស់ខ្លួនចុះខ្សោយ ហើយពួកគេត្រូវចំណាយលើការព្យាបាល ឬបាត់បង់ចំណូល។ នៅក្នុងករណីទាំងនេះ ដំណោះស្រាយអាចធ្វើទៅបានតែក្នុងករណីដែលសហគ្រាសជាប់កាតព្វកិច្ចទាក់ទងអ្នក រងផលប៉ះពាល់ ឬអ្នកតំណាងស្របច្បាប់របស់ខ្លួន

[46] ផ្នែក 7 ន 3 នៃច្បាប់នេះ

ប៉ុណ្ណោះ។ ត្រឡប់មកវិញ ដំណើរការនេះត្រូវការព័ត៌មានដែលសហគ្រាស ជាប់កាតព្វកិច្ចជាទូទៅបានទទួលតែពីអ្នកផ្គត់ផ្គង់របស់ខ្លួនតែប៉ុណ្ណោះ។

សម្រាប់ការធ្វើផែនការ និងអនុវត្តវិធានការតម្រូវទៅលើអ្នកផ្គត់ផ្គង់ប្រយោលរបស់ខ្លួន សហគ្រាសជាប់កាតព្វកិច្ចជាទូទៅងាកទៅរកអ្នកផ្គត់ផ្គង់ផ្ទាល់ដែលមានទំនាក់ទំនងជាមួយពួកគេ។ ស្របពេលនៅក្នុងបរិបទនៃការវិភាគហានិភ័យសហគ្រាសជាប់កាតព្វកិច្ចគួរវាយតម្លៃដោយប្រុងប្រយ័ត្នថាព័ត៌មានមួយណាដែលពួកគេពិតជាត្រូវការ សម្រាប់ការវិភាគហានិភ័យ និងគួរប្រុងប្រយ័ត្នជាមួយនឹងព័ត៌មានទាក់ទងនឹងអត្តសញ្ញាណនៃអ្នកផ្គត់ផ្គង់បន្ត នៅចុងបញ្ចប់វាអាចនឹងមានភាពចាំបាច់សម្រាប់វិធានការទប់ស្កាត់ក្នុងដឹងពីអត្តសញ្ញាណនៃអ្នកផ្គត់ផ្គង់ប្រយោល។

វាជាការពិតពីព្រោះការអនុវត្តវិធានការតម្រូវចំពោះអ្នកផ្គត់ផ្គង់ប្រយោលតម្រូវឱ្យមានការយល់ដឹងពីអត្តសញ្ញាណ និងលទ្ធភាពក្នុងការទំនាក់ទំនងរបស់ខ្លួន។ អ្នកផ្គត់ផ្គង់អាចរំពឹងថាអ្នកទិញរបស់ខ្លួននឹងងាកមករកពួកគេជាមួយនឹងសំណួរប្រភេទនេះ។ នៅក្នុងបរិបទនេះ វាអាចកើតឡើងបានដែលថា សហគ្រាសជាប់កាតព្វកិច្ចគាំទ្រអ្នកផ្គត់ផ្គង់ផ្ទាល់របស់ខ្លួនក្នុងការអនុវត្តវិធានការតម្រូវប្រសិនបើពួកគេមិនចង់បង្ហាញព័ត៌មានទាក់ទងនឹងអ្នកផ្គត់ផ្គង់បន្ត។ ការគាំទ្រនេះអាចមានរហូតដល់ការគ្របដណ្តប់ពេញលេញលើថ្លៃចំណាយ អាស្រ័យលើភាពសមស្របនៃការបែងចែកថ្លៃចំណាយ ដោយយោងទៅតាមលក្ខខណ្ឌវិនិច្ឆ័យភាពសមស្រប។ សហគ្រាសជាប់កាតព្វកិច្ចមិនគួរប្រើប្រាស់ការខ្វះការសហការ ឬ គាំទ្រពីអ្នកផ្គត់ផ្គង់ក្នុងការអនុវត្តវិធានការតម្រូវជាមូលហេតុគ្របដណ្តប់ដើម្បីបញ្ចប់ទំនាក់ទំនងអាជីវកម្មទេ។ [47]

ពាក់ព័ន្ធនឹងការអនុវត្តជាក់ស្តែងនៃវិធានការ តួអង្គជាច្រើនអាចត្រូវបានពិចារណា

- វាអាចទៅរួចដែលថាសហគ្រាសជាប់កាតព្វកិច្ចអនុវត្តវិធានការដោយខ្លួនឯងផ្ទាល់ទៅលើអ្នកផ្គត់ផ្គង់ផ្ទាល់ និងប្រយោល ក្នុងករណីដែលត្រូវចាត់វិធានការកែតម្រូវ។
- យ៉ាងណាមិញ សហគ្រាសជាប់កាតព្វកិច្ចក៏អាចអនុវត្តវិធានការរួមគ្នាជាមួយតួអង្គ ឬអ្នកផ្គត់ផ្គង់អន្តរការីបន្ថែមផ្សេងទៀត។ ជាពិសេសនោះ ការធ្វើបែបនេះអាចនឹងត្រូវបានពិចារណាប្រសិនបើ ពួកគេស្ថិតនៅក្នុងវិសាលភាពនៃច្បាប់។ ការអនុវត្តវិធានការរួមគ្នាជាមួយអ្នកទិញ ឬអ្នកផ្គត់ផ្គង់អន្តរការី ក៏អាចកើតឡើងបានផងដែរប្រសិនបើពួកគេមិនមានកាតព្វកិច្ចស្ថិតក្រោមច្បាប់។ នៅក្នុងស្ថានភាពនេះ វាជាការសំខាន់ដែលត្រូវកត់សម្គាល់ថា ពួកគេអាចមិនស្ថិតក្រោមកាតព្វកិច្ច ផ្លូវច្បាប់ក្នុងការផ្តល់ដំណោះស្រាយ ហើយ សហគ្រាសជាប់កាតព្វកិច្ចត្រូវចរចារអំពីការចូលរួមរបស់ខ្លួននៅក្នុងវិធានការតម្រូវ។ អ្នកទិញ និងអ្នកផ្គត់ផ្គង់អន្តរការីទាំងនេះអាចនឹងចាប់អារម្មណ៍ក្នុងការចូលរួមក្នុងវិធានការតម្រូវ ដោយហេតុផលផ្សេង ឧទាហរណ៍ ព្រោះពួកគេត្រូវមានកាតព្វកិច្ចដោយច្បាប់ផ្សេងក្នុងការកែប្រែ ឬត្រួតពិនិត្យភាពត្រឹមត្រូវ ឬដោយសារហេតុផលកេរ្តិ៍ឈ្មោះ។
- ជម្រើសមួយផ្សេងទៀតគឺថា អ្នកផ្គត់ផ្គង់ ក្នុងករណីត្រូវធ្វើការកែប្រែ (remedy) អនុវត្តវិធានការ ដោយខ្លួនឯង និងទទួលបានការគាំទ្រពីសហគ្រាសជាប់កាតព្វកិច្ច។

ករណីទាំងអស់នេះរួមគ្នា សហគ្រាសត្រូវតែធានាថាថ្លៃចំណាយសម្រាប់វិធានការតម្រូវត្រូវបាន**បែងចែកយ៉ាងសមស្រប។**

[47] ប្រអប់ព័ត៌មានទី 6 ផ្តល់នូវព័ត៌មានបន្ថែមស្តីពីគោលការណ៍ ការជួយមុនពេលដកកិច្ចសន្យា

ឧទាហរណ៍ទី 3

**ការអនុវត្តវិធានការកែតម្រូវចំពោះអ្នកផ្គត់ផ្គង់ប្រយោល**

ក្រុមហ៊ុនលក់សម្លៀកបំពាក់មួយបានឱ្យរោងចក្រមួយក្នុងចំណោមរោងចក្រនៅឥណ្ឌាផលិតម៉ូតសម្លៀកបំពាក់របស់ខ្លួន។

បន្ថែមពីលើការផលិតសម្លៀកបំពាក់ ការផលិតសរសៃសូត្រពីសែលុយឡូស ការរវៃសរសៃអំបោះ និងការជ្រលក់ពណ៌ធ្វើឡើងនៅក្នុងអគារផលិតកម្មរបស់ខ្លួន។ ជាផ្នែកមួយនៃការវិភាគហានិភ័យ ក្រុមហ៊ុនលក់សម្លៀកបំពាក់នេះ បានប្រើវិធីសាស្ត្រផ្អែកលើហានិភ័យ និងបានធ្វើសវនកម្មទៅលើអ្នកផ្គត់ផ្គង់នេះ។ សវនកម្មបានបង្ហាញថាមានសារធាតុគីមីជាច្រើនត្រូវបានប្រើប្រាស់នៅក្នុងការផលិតសរសៃសូត្ររុក្ខជាតិ រួមមានទាំងសារធាតុកាបោនឌីសុលហ្វាតដែលមានជាតិពុលខ្ពស់ មិនបានធ្វើប្រព្រឹត្តិកម្មយ៉ាងត្រឹមត្រូវពីទឹកដែលបង្ហូរចូលទៅទន្លេក្បែរនោះទេ។ ដោយសារការបង្ហាញយ៉ាងរឹងមាំពីលក្ខណៈវិនិច្ឆ័យភាព សមស្រប (ជាពិសេស វាមានហានិភ័យសុខភាពធ្ងន់ធ្ងរសម្រាប់អ្នករស់នៅក្នុងសហគមន៍មួយចំនួនដែលរស់នៅតាមដងទន្លេនេះ) ក្រុមហ៊ុនលក់សម្លៀកបំពាក់សម្រេចចិត្តអនុវត្តវិធានការដោះស្រាយរបស់ខ្លួនជាមួយនឹងថ្លៃចំណាយធនធានខ្ពស់។

បន្ថែមពីលើការកែតម្រូវ ការខូចខាតបរិស្ថានដែលបានកើតឡើងរួចមកហើយ និងការផ្តល់សំណងដល់ប្រជាជនដែលបានធ្លាក់ខ្លួនឈឺ វិធានការកែតម្រូវក៏រួមបញ្ចូលនូវការកែសម្រួលរោងចក្រផលិតសរសៃសូត្ររុក្ខជាតិដើម្បីឱ្យអ្នកផ្គត់ផ្គង់លែងបោះចោលសារធាតុគីមីតាមរយៈទឹកសំណល់ទៀត។ ដើម្បីអាចធ្វើកិច្ចការនេះបាន សារធាតុគីមីមួយចំនួនដែលបានប្រើប្រាស់នឹងត្រូវរក្សាទុកនិងកែច្នៃឡើងវិញ។

ក្រុមហ៊ុនលក់សម្លៀកបំពាក់អាចធ្វើផែនការ និងអនុវត្តវិធានការនេះរួមគ្នាជាមួយនឹងអ្នកផ្គត់ផ្គង់របស់ខ្លួនតែប៉ុណ្ណោះ។ សម្រាប់ការរៀបចំវិធានការ ក្រុមហ៊ុនលក់សម្លៀកបំពាក់ត្រូវការព័ត៌មានច្បាស់លាស់អំពីរោងចក្រផលិតសរសៃសូត្ររុក្ខជាតិ។ ក្រុមហ៊ុនមិនអាចធ្វើការផ្លាស់ប្តូរទៅលើរោងចក្របានទេ ប្រសិនបើមិនមានការយល់ព្រមពីអ្នកផ្គត់ផ្គង់។ លើសពីនេះ ក្រុមហ៊ុនលក់សម្លៀកបំពាក់ត្រូវប្រឈមមុខនឹងសំណួរថាតើនឹងធ្វើការបែងចែកថ្លៃចំណាយក្នុងការកែសម្រួលរោងចក្រ លុបបំបាត់ការខូចខាតបរិស្ថាននិងផ្តល់សំណងដល់ប្រជាជនដែលបានធ្លាក់ខ្លួនឈឺ ដោយរបៀបណារវាងខ្លួនឯងនិងអ្នកផ្គត់ផ្គង់។

ចំណុចក្រោយគេមិនថាក្នុងករណីណាមួយ គឺត្រូវមានកាតព្វកិច្ចស្ថិតក្រោមច្បាប់នៃប្រទេសឥណ្ឌាក្នុងការធ្វើប្រព្រឹត្តិកម្មទឹកសំណល់ ហើយវាត្រូវបានហាមឃាត់ក្នុងការបញ្ចេញសារធាតុគីមីគ្រោះថ្នាក់ទៅក្នុងប្រភពទឹក។

នៅពេលអនុវត្តវិធានការកែតម្រូវចំពោះអ្នកផ្គត់ផ្គង់ផ្ទាល់ និងប្រយោល ក្រុមហ៊ុនជាប់កាតព្វកិច្ចពេលខ្លះព្យាយាមភ្ជាប់កាតព្វកិច្ចតាមកិច្ចសន្យាទៅលើអ្នកផ្គត់ផ្គង់របស់ខ្លួនឱ្យអនុវត្តវិធានការតម្រូវនៅក្នុងអាជីវកម្មដ្ឋានរបស់ផ្ទាល់របស់ខ្លួន ឬនៅកន្លែងអ្នកផ្គត់ផ្គង់ខ្សែខាងលើ។ម្យ៉ាងវិញទៀត គោលការណ៍ដែលភ្ជាប់កិច្ចសន្យាទៅនឹងការខូចខាតរបស់ភាគីទីបីគឺមិនមានសុពលភាព ក៏ត្រូវបានប្រើប្រាស់នៅទីនេះផងដែរ។ ម្យ៉ាងវិញទៀត ការផ្ទេរកាតព្វកិច្ចដែលមិនបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពសមស្រប និងប្រសិទ្ធភាពសម្រាប់សហគ្រាសដែលតម្រូវដោយច្បាប់នេះ។ នេះគឺដោយសារតែ នៅក្នុងបរិបទ

នៃវិធានការកែតម្រូវជាពិសេស ប្រសិទ្ធភាព និងសមាមាត្រនៃការបែងចែកថ្លៃចំណាយស្របគ្នាទៅនឹងលក្ខណៈវិនិច្ឆ័យនៃប្រសិទ្ធភាព និងភាពសមស្របគឺជាចំណុចសំខាន់។

ឧទាហរណ៍ទី 4

### វិធានការតម្រូវចំពោះអ្នកផ្គត់ផ្គង់នៅក្នុងប្រទេសអាឡឺម៉ង់

ហាងលក់រាយអាហារដ៏ធំមួយរបស់អាឡឺម៉ង់ទទួលការផ្គត់ផ្គង់ផលិតផលក្នុងរដូវកាលទំពាំងបារាំង និងស្ត្របឺរីពីកសិដ្ឋាននានាក្នុងតំបន់។ តាមរបាយការណ៍ប្រព័ន្ធផ្សព្វផ្សាយ សហគ្រាសនេះបានដឹងថា អ្នកផ្គត់ផ្គង់ផ្ទាល់មួយរបស់ខ្លួនត្រូវបានគេរៀបរាប់ថាបានរំលោភលើប្រាក់ឈ្នួលអប្បបរិមាស្របច្បាប់ និងបទប្បញ្ញត្តិសុខភាព និងសុវត្ថិភាពការងារទៅលើកម្មករតាមរដូវកាលដែលខ្លួនបានជួល។ កាលពីកន្លងទៅ អ្នកផ្គត់ផ្គង់បានជូនដំណឹងដល់សហគ្រាសជាប់កាតព្វកិច្ចនៅក្នុងកម្រងសំណួរវាយតម្លៃខ្លួនឯង និងក្រោយមកបានប្តេជ្ញាចិត្តបែបកិច្ចសន្យាថានឹងធ្វើការដើម្បីបំពេញតាមស្តង់ដារសិទ្ធិមនុស្ស និងបរិស្ថានជាក់លាក់។ នៅក្នុងចំណោមលក្ខខណ្ឌតម្រូវទាំងនេះគឺ ការបង់ប្រាក់ឈ្នួលអប្បបរិមាស្របច្បាប់ និងបំពេញតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់ផ្នែកសុខភាព និងសុវត្ថិភាពការងារ។ ការព្រមព្រៀងបែប កិច្ចសន្យាដែលមានប្រសិទ្ធភាពស្របច្បាប់ក៏អនុញ្ញាតឱ្យមានការចុះទៅពិនិត្យនៅទីតាំងដោយមិន ប្រកាសដើម្បីតាមដានអនុលោមភាពដោយសហគ្រាសជាប់កាតព្វកិច្ច។ យ៉ាងណាមិញ ការព្រមព្រៀង នេះក៏រួមបញ្ចូលនូវកាតព្វកិច្ចសម្រាប់សហគ្រាសជាប់កាតព្វកិច្ចឱ្យប្រើប្រាស់ការអនុវត្តការទិញប្រកបដោយការទទួលខុសត្រូវដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមាន និងគាំទ្រអ្នកផ្គត់ផ្គង់ឱ្យបំពេញតាមស្តង់ដារ។ សហគ្រាសជាប់កាតព្វកិច្ចមានសិទ្ធិក្នុងការបញ្ចប់ទំនាក់ទំនងកិច្ចសន្យាតែក្នុងករណីនៃការបំពានធ្ងន់ធ្ងរដែលមិនអាចធ្វើការកែប្រែបាន និងតែក្នុងករណីមានការបដិសេធក្នុងកិច្ចសហការពីអ្នកផ្គត់ផ្គង់ម្តងហើយម្តងទៀតតែប៉ុណ្ណោះ។

ដោយសារតែមានស្តង់ដារនៃការការពារខ្ពស់នៅកន្លែងផលិត និងទំនាក់ទំនងពាណិជ្ជកម្មយូរអង្វែងដោយគ្មានការតវ៉ា សហគ្រាសជាប់កាតព្វកិច្ចមិនទាន់បានប្រើប្រាស់សិទ្ធិរបស់ខ្លួនដើម្បីចុះពិនិត្យ ទីតាំងផ្ទាល់នៅឡើយទេ ប៉ុន្តែពឹងផ្អែកទាំងស្រុងទៅលើការធានារបស់អ្នកផ្គត់ផ្គង់។

ព្រោះតែរបាយការណ៍របស់បណ្តាញផ្សព្វផ្សាយ សហគ្រាសជាប់កាតព្វកិច្ចបានចុះត្រួតពិនិត្យទីតាំងផ្ទាល់។ ដើម្បីមិនឱ្យប៉ះពាល់ដល់គោលបំណងនៃការចុះពិនិត្យនេះ សហគ្រាសជាប់កាតព្វកិច្ចមិនបាន ធ្វើការប្រកាសជាមុនទេ។ ការត្រួតពិនិត្យនៅទីតាំងផ្ទាល់ ការប្រឹក្សាជាមួយបុគ្គលិកនៅក្នុងបរិយាកាស ដែលគួរឱ្យជឿទុកចិត្ត និងការវាយតម្លៃទៅលើរបាយការណ៍ប្រាក់ខែបានបញ្ជាក់ថា អ្នកផ្គត់ផ្គង់បំពានលើ បទប្បញ្ញត្តិសុខភាព និងសុវត្ថិភាពការងារដូចជា ការផ្តល់ម៉ាស់ និងថ្នាំសម្លាប់មេរោគ ក៏ដូចជាខ្យល់ ចេញចូលគ្រប់គ្រាន់នៅក្នុងបន្ទប់ស្នាក់នៅ និងការបង់ប្រាក់ឈ្នួលជូនកម្មកររបស់ខ្លួនទាបជាងប្រាក់ឈ្នួលអប្បបរមាដោយសារតែមានការកាត់ចេញដោយមិនសមរម្យនូវតម្លៃតបស្នងមិនមែនរូបិយវត្ថុ។

នៅពេលពិភាក្សាពីមូលហេតុជាមួយអ្នកផ្គត់ផ្គង់ វាក្លាយជាភាពជាក់ស្តែងដែលថ្លៃទិញថេរមិនអាចឱ្យអ្នក ផ្គត់ផ្គង់ផ្តល់ហិរញ្ញប្បទានដល់ការដំឡើងប្រាក់ឈ្នួលអប្បបរមាចុងក្រោយ និងវិធានការពារដែលតម្រូវ ដោយការរាតត្បាត SARS-Cov-2 បាន។

នៅពេលនោះ ដើម្បីកែប្រែស្ថានភាពនេះសហគ្រាសជាប់កាតព្វកិច្ចបានយល់ព្រមជាមួយអ្នកផ្គត់ផ្គង់ ទៅលើថ្លៃទិញដែលគ្រប់ដណ្តប់លើថ្លៃដើម និងពេលវេលានិងផែនការសកម្មភាពដើម្បីកែលម្អការ ការពារសុខភាព និងកម្លាំងពលកម្ម។ ដើម្បីទប់ស្កាត់បញ្ហាទាំងនេះនៅថ្ងៃអនាគត កិច្ចព្រមព្រៀងបន្ថែមត្រូវបានសម្រេច ដោយក្នុងនោះ ក្នុងចំណោមកត្តាផ្សេងៗ (ដែលយើងហៅថា មាត្រានៃការឡើងថ្លៃ) អ្នកលក់រាយអាហារត្រូវរ៉ាប់រងក្នុងការលៃតម្រូវថ្លៃទិញ នៅក្នុងករណីនៃការឡើងប្រាក់ឈ្នួលអប្បបរមា និងអតិផរណាខ្ពស់។ ក្រៅពីនេះសហគ្រាសជាប់កាតព្វកិច្ចត្រូវបង្កើតទំនាក់ទំនងផ្ទាល់ជាមួយនឹងមជ្ឈមណ្ឌលប្រឹក្សាដែលមានទំនាក់ទំនងជាមួយកម្មករតាមរដូវកាលដើម្បីទទួលបានដំណឹងអំពីការបំពានសិទ្ធិមនុស្ស និងបរិស្ថាននៅដំណាក់កាលដំបូងបន្ថែមពីលើនីតិវិធីបណ្តឹងរបស់ខ្លួន។

### i. ការបែងចែកថ្លៃចំណាយសមស្រប

សហគ្រាសជាប់កាតព្វកិច្ចត្រូវបានតម្រូវឱ្យបង្កើតសំណើរស្របតាមគោលការណ៍នៃភាពសមស្រប និងប្រសិទ្ធភាពទៅលើការបែងចែកថ្លៃចំណាយរវាងពួកគេ និងអ្នកផ្គត់ផ្គង់របស់ខ្លួន នៅពេលដែល ត្រូវអនុវត្តវិធានការតម្រូវ ឬរវាងពួកគេនិងអ្នកផ្គត់ផ្គង់អន្តរការីផ្សេងទៀតនៅពេលដែលត្រូវអនុវត្ត វិធានការតម្រូវ។ គួរកត់សម្គាល់ផងដែរថា សហគ្រាសជាប់កាតព្វកិច្ចមានភារកិច្ចគ្រប់គ្រាន់ ទាក់ទងនឹងអ្នកផ្គត់ផ្គង់ផ្ទាល់ក្នុងករណីមានចំណេះដឹងគ្រប់គ្រាន់ និងប្រយោលរបស់ពួកគេ។ ដោយហេតុនេះ សហគ្រាសជាប់កាតព្វកិច្ចជាទូទៅមិនទទួលជោគជ័យដោយសារវិធានការតម្រូវឡើយ។ យ៉ាងណាមិញ ភាពជោគជ័យនៃវិធានការនេះមិនត្រូវដកចេញតាំងពីដំបូងឡើយ នេះគឺជាការពិត ឧ. ប្រសិនបើថ្លៃចំណាយទៅលើវិធានការដែលបានរៀបរាប់ត្រូវបានដាក់ចេញជាឯកតោភាគីទៅលើអ្នកចូលរួមទីផ្សារផ្សេងទៀត ដូច្នេះ វាអាចមើលឃើញថាជាការការពារការអនុវត្តប្រកបដោយប្រសិទ្ធភាពរបស់ខ្លួន។ ការបែងចែកថ្លៃចំណាយដូចនេះមិនអនុលោមតាមលក្ខខណ្ឌតម្រូវនៃប្រសិទ្ធភាពដែលបានកំណត់នៅក្នុងច្បាប់នោះទេ។

ជាមួយនឹងច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ អ្នកបង្កើតច្បាប់បានធ្វើការសម្រេច ជាមូលដ្ឋានសហគ្រាសដែលតម្រូវដោយច្បាប់នេះត្រូវធ្វើការកំណត់ហានិភ័យ និងការរំលោភបំពានបែប បុរេសកម្មនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់របស់ពួកគេ និងដោះស្រាយបញ្ហាទាំងនោះដោយប្រើប្រាស់វិធានការ។ យ៉ាងណាមិញ ជំហរផ្លូវច្បាប់ផ្នែកបរិស្ថាន និងសិទ្ធមនុស្សនៃច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវដែលមានការការពារជាច្រើន ត្រូវបានផ្សារភ្ជាប់ទៅនឹងការប្រកាន់ខ្ជាប់ទៅតាមច្បាប់ជាតិដែលពាក់ព័ន្ធ។ ក្នុងករណីផ្សេងទៀត មានផ្នែកខ្លះនៃច្បាប់ជាតិដែលមានគោលបំណងការពារដូច ឬស្រដៀងគ្នា។

ឧទាហរណ៍ ប្រសិនបើអ្នកផ្គត់ផ្គង់រំលោភលើកាតព្វកិច្ចសុខភាព និងសុវត្ថិភាពការងារដែលមានជាធរមាន ស្ថិតក្រោមច្បាប់នៃកន្លែងធ្វើការ ហើយវាបណ្តាលឱ្យមានហានិភ័យនៃគ្រោះថ្នាក់នៅកន្លែងធ្វើការ ឬគ្រោះថ្នាក់សុខភាពទាក់ទងនឹងការងារ វានឹងមានទាំង៖ ការរំលោភលើច្បាប់ជាតិដោយអ្នកផ្គត់ផ្គង់ និងការរំលោភលើជំហរផ្លូវច្បាប់ដែលបានការពារស្ថិតក្រោមច្បាប់នៃការត្រួតពិនិត្យភាពត្រឹម ត្រូវដោយសហគ្រាសជាប់កាតព្វកិច្ច។ សហគ្រាសទាំងពីរ ដោយផ្អែកលើមូលដ្ឋានច្បាប់ផ្សេងគ្នា និងឯករាជ្យពីគ្នាទៅវិញទៅមក នឹងត្រូវមានកាតព្វកិច្ចចាត់វិធានការ។ ដោយយោងទៅលក្ខណៈវិនិច្ឆ័យនៃ ប្រសិទ្ធភាព និងភាពសមស្រប វាអាចនឹងគ្រប់គ្រាន់សម្រាប់សហគ្រាសជាប់កាតព្វកិច្ចក្នុងការទទួលបន្ទុក តែមួយផ្នែកនៃថ្លៃចំណាយដែលកើតឡើងដោយវិធានការតម្រូវ ហើយមួយចំណែកផ្សេងទៀតនៃថ្លៃ ចំណាយត្រូវរ៉ាប់រងដោយអ្នកផ្គត់ផ្គង់។ Constellations ដែលអ្នកផ្គត់ផ្គង់រំលោភលើស្ថានភាពផ្លូវច្បាប់ដែលបាន ការពារ នោះគឺខ្លួនមានកាតព្វអនុវត្តតាមច្បាប់ ឬដែល អ្នកផ្គត់ផ្គង់មានអតិថិជនជាប់កាតព្វកិច្ចជាច្រើន ក៏អាចកើតមានផងដែរ។

នៅពេលបែងចែកថ្លៃចំណាយសម្រាប់វិធានការតម្រូវ សហគ្រាសគួរពិចារណាថាតើមានការបំពេញ តាមលក្ខណៈវិនិច្ឆ័យនៃភាពសមស្របកម្រិតណាទាក់ទងនឹងសហគ្រាសនានាដែលពាក់ព័ន្ធ (សហគ្រាស ជាប់កាតព្វកិច្ច និងអ្នកផ្គត់ផ្គង់ដែលជាប់ ឬមិនជាប់កាតព្វកិច្ច)។ គួរកត់សម្គាល់នៅក្នុងនេះផងដែរថា លក្ខណៈវិនិច្ឆ័យភាពសមស្របមិនមានឋានានុក្រមជាក់លាក់ទេ ហើយគួរត្រូវបានពិចារណាស្មើៗគ្នា។ វាទំនងជាខុសគ្នាពីសហគ្រាសមួយទៅសហគ្រាសមួយទៀតដែលពាក់ព័ន្ធនឹងការកែប្រែ។

លក្ខណៈ និងវិសាលភាពនៃលក្ខណៈវិនិច្ឆ័យនៃសកម្មភាពអាជីវកម្មរួមមានលក្ខណៈវិនិច្ឆ័យទាក់ទង នឹងធនធាន និងហានិភ័យ។ នៅក្នុងបរិបទនៃការបែងចែកថ្លៃចំណាយសមស្រប វាអាស្រ័យទៅលើកម្រិតនៃភាពពាក់ព័ន្ធរបស់សហគ្រាសក្នុងការកែប្រែ អាចកែប្រែស្ថានភាពពាក់ព័ន្ធនឹងធនធានរបស់ខ្លួន។ ជាពិសេសត្រូវពិចារណាទៅលើធនធាន ហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្សដែលមានសម្រាប់សហគ្រាសផ្សេងៗ ។ សហគ្រាសដែលមានសមត្ថភាពច្រើន ត្រូវបានគេរំពឹងថានឹងធ្វើកាន់តែច្រើន។ ជាពិសេសពាក់ព័ន្ធនឹងអ្នកផ្គត់ផ្គង់នៅក្នុងបណ្តាប្រទេសនៅសកលលោកខាងត្បូង សហគ្រាសជាប់កាតព្វកិច្ចគួរពិចារណា យ៉ាងយកចិត្តទុកដាក់ពីកម្រិតដែលអ្នកផ្គត់ផ្គង់អាចចូលរួមបែបសេដ្ឋកិច្ចទៅក្នុង វិធានការតម្រូវ។ លក្ខខណ្ឌពាក់ព័ន្ធនឹងហានិភ័យនៅក្នុងលក្ខណៈវិនិច្ឆ័យនេះជាទូទៅមិនជាប់ពាក់ព័ន្ធនៅពេលដោះស្រាយបញ្ហានៃការបែង

ចែងថ្លៃចំណាយសមស្របទេ។ លក្ខខណ្ឌវិនិច្ឆ័យទាំងនេះមានសារសំខាន់ជាមូលដ្ឋាន សម្រាប់សំណួរដែលថាតើវាត្រូវចំណាយសរុបប៉ុន្មានសម្រាប់វិធានការតម្រូវ ក៏ដូចជាកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវផ្សេងទៀត។[48]

សហគ្រាសដែលមានសមត្ថភាពបញ្ចុះបញ្ចូលខ្លាំងជាង ជាទូទៅត្រូវបានគេរំពឹងថានឹងធ្វើកាន់តែច្រើន ដើម្បីសម្រេចការកែប្រែ។ សមត្ថភាពក្នុងការបញ្ចុះបញ្ចូលក៏ជាការសម្រេចទៅលើប្រភេទនៃវិធានការដែល អាចអនុវត្តបានផងដែរ។ ក្នុងការកំណត់សមត្ថភាពក្នុងការបញ្ចុះបញ្ចូល កម្រិតនៃការលប់លើទីផ្សារដើរតួ នាទីសំខាន់។ ភាពពាក់ព័ន្ធជាពិសេស គឺសមាមាត្រនៃទំហំការបញ្ជាទិញរបស់សហគ្រាសជាប់កាតព្វកិច្ច ធៀបទៅនឹងចំណូលអាជីវកម្មសរុបនៃអ្នកផ្គត់ផ្គង់នេះ។ ដូចនេះ នៅក្នុងបរិបទនៃកំណត់ការបែងចែកថ្លៃ ចំណាយសមស្រប ត្រូវធ្វើការប្រៀបធៀបទំហំនៃការបញ្ជាទិញនីមួយៗរបស់សហគ្រាសដែលជាប់ពាក់ព័ន្ធជាមួយនឹងអ្នកផ្គត់ផ្គង់នេះ។

លក្ខណៈវិនិច្ឆ័យទាក់ទង់នឹងការបំពាននៃ**ភាពធ្ងន់ធ្ងរ និងលទ្ធភាពដែលអាចកើតឡើង** រួមគ្នាជាមួយនឹង លក្ខណៈវិនិច្ឆ័យផ្សេងទៀតនៃភាពសមស្រប គ្រប់គ្រងកម្រិតសកម្មភាពសមស្របសម្រាប់ការកែប្រែ ក៏ដូចជាកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវផ្សេងទៀត។ យ៉ាងណាមិញ ពួកវាមិនពាក់ព័ន្ធសម្រាប់ ការកំណត់ការបែងចែកថ្លៃចំណាយសមស្របទេ ដោយសារតែពួកវាត្រូវបានបំពេញស្មើៗគ្នាសម្រាប់សហគ្រាសដែលចូលរួមទាំងអស់ទាក់ទងទៅនឹងការបំពានដូចគ្នា។[49]

**លក្ខណៈនៃការចូលរួមចំណែកជាបុព្វហេតុ** គឺអំពីការកំណត់ថាតើសហគ្រាសដែលពាក់ព័ន្ធមានការទទួល ខុសត្រូវច្រើនប៉ុនណាចំពោះគ្នាទៅវិញទៅមក។ សហគ្រាសដែលមានការទទួលខុសត្រូវធំជាងសម្រាប់ការបំពានត្រូវចូលរួមចំណែកច្រើនជាងសហគ្រាសដែលមានការទទួលខុសត្រូវតិចជាង។ លក្ខណៈនៃការចូលរួមចំណែកជាបុព្វហេតុត្រូវបានប្រកាសជាពិសេសនៅពេលដែលការបំពានត្រូវបានបង្កឡើងផ្ទាល់ដោយសហគ្រាសតែមួយ។ យ៉ាងណាមិញ សហគ្រាសនានាក៏អាចបង្ក ឬចូលរួមចំណែកក្នុងការបំពានរួមគ្នា ជាមួយអ្នកផ្សេងផងដែរ។ ឧទាហរណ៍ ការចូលរួមចំណែកអាចមាននៅក្នុងករណីដែលអ្នកទិញបង់ថ្លៃ ទិញទំនិញដែលរារាំងអ្នកផ្គត់ផ្គង់ពីការបង់ប្រាក់ឈ្នួលរស់នៅសមស្រប ឬក្នុងការអនុលោមតាមបទប្បញ្ញត្តិ ការពារកម្លាំងពលកម្ម និងបរិស្ថាន។

លើសពីនេះ ការផ្លាស់ប្តូរស្តីពីការជូនដំណឹងរយៈពេលខ្លីសម្រាប់រយៈពេលផលិត និងលក្ខខណ្ឌជាញឹកញាប់ចូលរួមចំណែកនៅក្នុងហានិភ័យ និងការបំពាន ឧទាហរណ៍ នៅពេលការផ្លាស់ប្តូរបណ្តាលឱ្យ មានការថែមម៉ោងនៅផ្នែកអ្នកផ្គត់ផ្គង់ដែលលើសពីម៉ោងធ្វើការអតិបរមាដែលកំណត់ដោយច្បាប់។ ក្នុងករណីនៃការបំពាននៅផ្នែកអ្នកផ្គត់ផ្គង់ករណីភាគច្រើន គឺមានការរួមចំណែកជាបុព្វហេតុរបស់អ្នកផ្គត់ផ្គង់។ ត្រង់នេះ ត្រូវមានការកំណត់ថាតើវាសមស្របសម្រាប់កម្រិតណាសម្រាប់ពួកគេក្នុងការចូលរួមចំណែកនៅក្នុងថ្លៃចំណាយ។

ទោះជាយ៉ាងណា ដោយសារលក្ខខណ្ឌត្រូវតែពិចារណាឱ្យបានស្មើគ្នា ត្រូវយកចិត្តទុកដាក់ជាពិសេស ទៅលើលក្ខខណ្ឌនៃលក្ខណៈ និងវិសាលភាពនៃសកម្មភាពអាជីវកម្ម។ ការធ្វើបែបនេះព្រោះតែអ្នកផ្គត់ផ្គង់ប្រហែលជាពុំមានធនធានដែលចាំបាច់សម្រាប់ការកែប្រែនេះ។

[48] ព័ត៌មានបន្ថែមស្តីពីលក្ខណៈវិនិច្ឆ័យ និងវិសាលភាពនៃសកម្មភាពអាជីវកម្មអាចរកបាននៅក្នុងគោលការណ៍ណែនាំស្តីពីភាពសមស្របរបស់ BAFA
[49] បន្ថែមស្តីពីលក្ខណៈវិនិច្ឆ័យនៃភាពធ្ងន់ធ្ងរ និងលទ្ធភាពដែលអាចកើតឡើងអាចរកបាននៅក្នុងគោលការណ៍ណែនាំស្តីពីភាពសមស្រប p.10

## ប្រអប់ព័ត៌មានទី ៩៖ ការផ្តល់លទ្ធភាពមុនដកកិច្ចសន្យា

1. **លក្ខណៈ និងវិសាលភាពនៃសកម្មភាពអាជីវកម្ម**

តើធនធានណាខ្លះដែលអាចប្រើប្រាស់បានសម្រាប់វិធានការតម្រូវចំពោះសហគ្រាសដែលចូលរួមនីមួយៗ?

2. **សមត្ថភាពប្រើឥទ្ធិពល** (ability to influence)

តើសហគ្រាសដែលចូលរួមនីមួយៗអាចមានឥទ្ធិពលលើភាគីដែលទទួលខុសត្រូវផ្ទាល់សម្រាប់ការបំពានដល់កម្រិតណា?

តើអត្រានៃបរិមាណបញ្ជាទិញរបស់សហគ្រាសដែលបានចូលរួមនីមួយធៀបនឹងចំណូលសរុបនៃភាគីដែលទទួលខុសត្រូវផ្ទាល់មានកម្រិតដូចម្តេច ប្រសិនបើធៀបគ្នាទៅវិញទៅមក?

3. **ភាពធ្ងន់ធ្ងរនិងលទ្ធភាពដែលអាចកើតឡើងជាធម្មតាដែលត្រូវរំពឹងទុក**

- មិនមានភាពខុសគ្នារវាងសហគ្រាសដែលចូលរួមទេ ដោយសារតែលក្ខណៈវិនិច្ឆ័យនេះត្រូវបានប្រកាសនៅក្នុងវិសាលភាពដូចគ្នាទាក់ទងនឹងការបំពានដូចគ្នា

4. **លក្ខណៈនៃការចូលរួមចំណែកជាបុព្វហេតុ**

តើសហគ្រាសដែលចូលរួមបានចូលរួមចំណែកក្នុងការបំពានកម្រិតណា?

តើសហគ្រាសមួយបង្កការបំពាន តែម្នាក់ឯង ឬភាគច្រើនតែម្នាក់ឯង?

តើការប្រព្រឹត្តិរបស់សហគ្រាសដែលបានចូលរួមផ្សេងទៀតចូលរួមចំណែកក្នុងការបំពានកម្រិតណា?

ឧទាហរណ៍ទី 5

## ការចូលរួមចំណែកថ្លៃចំណាយ

ក្រុមហ៊ុនផលិតសូកូឡាមួយបានរកឃើញថាមានពលកម្មកុមារនៅក្នុងការប្រមូលផលកាកាវនៅកន្លែងអ្នកផ្គត់ផ្គង់របស់គេមួយនៅអាហ្វ្រិកខាងលិចតាមរយៈការវិភាគហានិភ័យរបស់ខ្លួន។ ដោយសារតែការបង្ហាញអំពីលក្ខណៈវិនិច្ឆ័យភាពសមស្របយ៉ាងរឹងមាំ ពួកគេសម្រេចចិត្តអនុវត្តវិធានការ កែប្រែ។

ការប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារតម្រូវឱ្យមានវិធានការដែលស្មុគស្មាញ ពីព្រោះពលកម្មកុមារអាច លុបបំបាត់បានតែតាមរយៈការលប់បំបាត់មូលនៃពលកម្មកុមារតែប៉ុណ្ណោះ។ ក្រុមហ៊ុនផលិតនេះបានពិចារណា៖ ការជំរុញឡើងចំណូលនៃកម្មករពេញវ័យ និងកសិករធុនតូច ក៏ដូចជាបង្កើតឱកាសថៃទាំ កុមារសម្រាប់កូនៗរបស់ខ្លួនផងដែរ។ ក្រុមហ៊ុនផលិតសូកូឡាគឺជាសហគ្រាសមួយក្នុងចំណោមសហគ្រាសជាច្រើនដែលទិញកាកាវពីអ្នកផ្គត់ផ្គង់នេះ ហើយកំពុងតែមានចម្ងល់ថាតើពួកគេអាចជំរុញទឹកចិត្តអ្នកទិញផ្សេងទៀតឱ្យចូលរួមនៅក្នុងវិធានការបានដែរ ឬទេ។

ពួកគេក៏ឆ្ងល់ទៀតដែរថា តើពួកគេត្រូវតែអនុវត្តវិធានការតម្រូវនៅក្នុងកម្រិតដែលទៅដល់អ្នករងផល ប៉ះពាល់ទាំងអស់បានដែរឬទេ ប្រសិនបើអ្នកទិញដទៃទៀតមិនចូលរួមនៅក្នុងវិធានការនេះ។

លើសពីនេះ ក្រុមហ៊ុនផលិតសូកូឡាចង់ដឹងថាតើអ្នកផ្គត់ផ្គង់អាចត្រូវបានរំពឹងទុកថាចូលរួមចំណែក ទៅក្នុងថ្លៃចំណាយក្នុងកម្រិតណា ឬទំនងថាថ្លៃចំណាយសមស្របដែលក្រុមហ៊ុនផលិតត្រូវរ៉ាប់រងអាច នឹងត្រូវកាត់បន្ថយទៅតាមចំនួនទឹកប្រាក់ដែលអាចរំពឹងទុកពីអ្នកផ្គត់ផ្គង់។ ក្រុមហ៊ុនផលិតសូកូឡាបានទូទាត់ថ្លៃទិញដែលខ្ពស់ជាងតម្លៃទីផ្សារជាមធ្យមរួមហើយ ព្រោះអ្នកផ្គត់ផ្គង់មានការបញ្ជាក់ដោយអនុលោមតាមស្តង់ដារនិរន្តរភាពស្របទៅនឹងការមិនមានពលកម្មកុមារកើតឡើងនៅទីនោះ។

ដើម្បីឆ្លើយទៅនឹងសំណួរទាំងនេះ ក្រុមហ៊ុនផលិតសូកូឡាវាយតម្លៃថាតើថ្លៃទិញ និងការបញ្ជាក់ បានចូលរួមចំណែកក្នុងការបង្ការពលកម្មកុមារដែរឬទេ។ ដូចគ្នាទៅនឹងសហគ្រាសជាច្រើនដែរក្រុមហ៊ុនផលិតសូកូឡាទិញកាកាវផៅតាមរយៈការផ្លាស់ប្តូរទំនិញ។ នៅជំហានបន្ទាប់ ក្រុមហ៊ុនបានវិភាគគោលនយោបាយកំណត់តម្លៃ និងបង្កើតឡើងថាតម្លៃទិញ ទោះបីជាលើសតម្លៃទីផ្សារ គឺមិនគ្រប់គ្រាប់ដើម្បីប្រាក់ឈ្នួលសមរម្យទេ។ ដូចនេះ ក្រុមហ៊ុនផលិតសូកូឡាបានកំណត់វិសាលភាព ដែលក្រុមហ៊ុនត្រូវបង្កើនតម្លៃទិញដោយផ្អែកលើមូលដ្ឋាននៃតម្លៃការរស់នៅក្នុងស្រុក និងតាមច្បាប់។ លើសពីនេះ ពួកគេគ្រោងធ្វើការទំនាក់ទំនងជាមួយនឹងអ្នកទិញផ្សេងទៀតទាក់ទងនឹងវិធានការរួមដែលមានសក្តានុពលបន្ថែមទៀត។

RESPONSIBLE
BUSINESS HUB
CAMBODIA
RBH NETWORK

## ii. កិច្ចសហការក្នុងការអនុលោមតាមច្បាប់ស្តីពីការប្រកួតប្រជែងរបស់អាឡឺម៉ង់

ប្រសិនបើការបំពានសិទ្ធិមនុស្ស ឬបរិស្ថាននៅផ្នែកអ្នកផ្គត់ផ្គង់ត្រូវបានរៀបចំឡើងតាមវិធីដែលសហគ្រាស ជាប់កាតព្វកិច្ច មិនអាចបញ្ចប់វានៅក្នុងពេលវេលាដែលអាចស្មានទុកជាមុនបាន វាគឺជាកាតព្វកិច្ចស្របច្បាប់ក្នុងការរៀបចំនិងអនុវត្តគោលគំនិតសម្រាប់ការបញ្ចប់ និងកាន់បន្ថយការបំពាន។[50]

ពួកគេត្រូវវាយតម្លៃបន្ថែមអំពីសម្ព័ន្ធភាពជាមួយសហគ្រាសនានានៅក្នុងបរិបទនៃគំនិតផ្តួចផ្តើមតាមវិស័យ និងស្តង់ដារដើម្បីបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការជះឥទ្ធិពលដល់ភាគីដែលទទួលខុសត្រូវផ្ទាល់។ ការធ្វើបែបនេះមិនមែនមានន័យថាជា ការរួមបញ្ចូលគ្នាជារចនាសម្ព័ន្ធអចិន្ត្រៃយ៍នៅក្នុងអត្ថន័យនៃច្បាប់គ្រប់គ្រងការរួមបញ្ចូលគ្នានោះទេ ប៉ុន្តែវាជាកិច្ចសហការទៅលើប្រធានបទជាក់លាក់ទៅលើទិដ្ឋភាពជាក់លាក់។

ដែនកំណត់ដាច់ខាតនៃកិច្ចសហការនេះស្ថិតក្រោមច្បាប់ស្តីពីការប្រកួតប្រជែង ត្រូវបានរកឃើញនៅក្នុងការ អំពាវនាវឱ្យធ្វើពហិការនៅពេលដែលសហគ្រាសដែលចូលរួមមិនមានសេរីភាពក្នុងការធ្វើការសម្រេចចិត្តដោយខ្លួនឯងទៀតទេ។ កិច្ចសហការនេះក៏មិនត្រូវបំពានលើច្បាប់ពីការប្រកួតប្រជែងផងដែរ។[51] ការផ្លាស់ប្តូរព័ត៌មានអំពីប៉ារ៉ាម៉ែត្រទាក់ទងនឹងការប្រកួតប្រជែងក្នុងគោលបំណងកាត់បន្ថយភាពមិនច្បាស់លាស់ អំពីឥរិយាបថទីផ្សារនាពេលអនាគតរបស់អ្នកប្រកួតប្រជែង គឺជាមធ្យោបាយធម្មតាមួយនៃការសម្របសម្រួលដែលត្រូវបានហាមឃាត់ក្នុងការបំពានច្បាប់ពីការប្រកួតប្រជែង។[52] ការកំណត់តម្លៃបែបបញ្ឈរក៏ត្រូវបានហាមឃាត់ផងដែរលើកលែងតែវាអាចត្រូវបានលើកលែងពីការហាមឃាត់ស្តីពីការបំពានច្បាប់ពីការប្រកួតប្រជែង នៅក្នុងករណីលើកលែងនានា។ ក្នុងករណីនៃការបំពានបែបនេះ សហគ្រាសពាក់ព័ន្ធប្រឈមមុខនឹងការពិន័យរហូតដល់ ដប់ភាគរយនៃចំណូលប្រចាំឆ្នាំរបស់ខ្លួន។

នៅពេលធ្វើកិច្ចសហការនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គត់ វាគឺជាការសម្រេចចិត្តរបស់សហគ្រាសផ្ទាល់ក្នុងការត្រួតពិនិត្យឡើងវិញ និងវាយតម្លៃហានិភ័យដោយយកចិត្តទុកដាក់ទៅលើការផ្លាស់ប្តូរព័ត៌មានរសើប (ដូចជា ការផ្លាស់ប្តូរអំពីប្រភពលទ្ធកម្មជាក់លាក់ ឬតម្លៃទិញ) និងដើម្បីជៀសវាងការបំពានច្បាប់ពីការប្រកួតប្រជែង ដែលអាចកើតឡើង។ ពួកគេតម្រូវឱ្យធានាអនុលោមភាពទៅនឹងលក្ខខណ្ឌតម្រូវនៃច្បាប់ប្រកួត ប្រជែងនៅក្នុងក្របខណ្ឌដែលគេហៅថា ការវាយតម្លៃខ្លួនឯងតាមបែបការត្រួតពិនិត្យតាមច្បាប់ដោយ ឯករាជ្យ និងដោយមានជំនួយពីគោលការណ៍ណែនាំ និងបទប្បញ្ញត្តិដែលមានជាទូទៅ។

សហគ្រាសគួរគោរពតាម "គោលការណ៍ណែនាំស្តីពីការអនុវត្តមាត្រា 101 នៃសន្ធិសញ្ញាស្តីពីការប្រព្រឹត្ត ទៅនៃសហភាពអឺរ៉ុបចំពោះកិច្ចព្រមព្រៀងសហប្រតិបត្តិការផ្តេក (គោលការណ៍ណែនាំផ្តេក) ជាពិសេស ពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូរជាមួយគូប្រជែងនៅក្នុងបរិបទនេះ។ គោលការណ៍ទាំងនេះ មាននូវព័ត៌មាន ដ៏មានតម្លៃអំពីការវាយតម្លៃការប្រកួតប្រជែងនៃការផ្លាស់ប្តូរព័ត៌មាន។ ទោះបីជាការផ្លាស់ប្តូរព័ត៌មានគឺជា ឧបករណ៍ទូទៅនៃទីផ្សារប្រកួតប្រជែងជាច្រើន និងអាចនាំឱ្យទទួលបានប្រសិទ្ធភាពបែប ផ្សេងគ្នា។ យ៉ាងណាមិញ នៅក្នុងស្ថានភាពដែលការផ្លាស់ប្តូរព័ត៌មានទីផ្សារអាចផ្តល់ជូនក្រុមហ៊ុននូវ ការយល់ដឹងទៅលើយុទ្ធសាស្ត្រទីផ្សាររបស់គូប្រជែង វាក៏មានហានិភ័យនៃផលប៉ះពាល់ដែលដាក់កម្រិត លើការប្រកួតប្រជែងផងដែរ។

ក្រៅពីនេះ គោលការណ៍ណែនាំផ្តេក មានលក្ខខណ្ឌតម្រូវបន្ថែមទាក់ទងនឹងកិច្ចសហការប្រភេទផ្សេងគ្នា ឧ. ទាក់ទងនឹងទិដ្ឋភាពនៃការកំណត់ស្តង់ដារ និងនិរន្តរភាព។ ការស្នើសុំព័ត៌មានដែលស្របគ្នាក៏គួរមានការ

[50] ផ្នែក 7 § 2 នៃច្បាប់នេះ

[51] ផ្នែកទី 1 នៃច្បាប់ស្តីពីការប្រកួតប្រជែង មាត្រា 101 § 1 TFEU.

[52] តុលាការសហព័ន្ធអាឡឺម៉ង់ ដីកាថ្ងៃ 13 កក្កដា 2020KRB 99/9 គោលការណ៍ណែនាំ (ភាសាអាឡឺម៉ង់)។

ត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នធៀបទៅនឹងហេតុការណ៍នេះផងដែរ។

ធៀបទៅនឹងហេតុការណ៍នេះ ការផ្លាស់ប្តូរស្ថិតក្នុងក្របខណ្ឌនៃគំនិតផ្តួចផ្តើមតាមវិស័យ ជាគោលការណ៍គួរបន្តគោលដៅនៃការអនុវត្ត (រួមគ្នា) នៃកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវដោយយោងតាមច្បាប់។ ការផ្លាស់ប្តូរព័ត៌មានគ្នាជាក់ស្តែងក៏គួរតែមានភាពសមរម្យសម្រាប់គោលបំណងនេះ និងត្រូវបានកំណត់ចំពោះវិសាលភាពដែលមិនអាចខ្វះបានសម្រាប់គោលបំណងនេះ។

ក្នុងចំណោមកត្តាផ្សេងទៀត ការព្រមព្រៀង ឬការផ្លាស់ប្តូរព័ត៌មានទៅលើការចេញលក់ផលិតផលថ្មីដែល បានគ្រោងទុក សមាសធាតុ ដំណើរការ ក៏ដូចជាតម្លៃ អាចចាត់ទុកជាបទល្មើសរដ្ឋបាលដែលអាចត្រូវបាន ដាក់ទោសដោយការពិន័យជាប្រាក់ ដូចនេះហើយគួរតែជៀសវាង។ ប្រសិនបើការផ្លាស់ប្តូរព័ត៌មានរសើប ជាក់លាក់មិនអាចខ្វះបានសម្រាប់កិច្ចសហការសហគ្រាសពាក់ព័ន្ធគួរចាត់តាំងភាគីទីបីអព្យាក្រឹតដែលនឹងបញ្ជូនទិន្នន័យទៅកាន់ពួកគេតែក្នុងទម្រង់រួមតែប៉ុណ្ណោះ។

សហគ្រាសក៏អាចងាកទៅរកអាជ្ញាធរក្រុមជួញដូរមានសមត្ថកិច្ចជាមួយនឹងការស្នើសុំធ្វើការត្រួតពិនិត្យព័ត៌មានក្នុងករណីនៃមានគម្រោងសហប្រតិបត្តិការជាក់ស្តែងគ្រប់គ្រាន់ ឬការផ្លាស់ប្តូរព័ត៌មានគ្នាដោយចេតនាទៅលើខ្លឹមសារ (ក៏ដូចជា) ទាក់ទងនឹងច្បាប់ប្រកួតប្រជែង ប្រសិនបើនៅមានភាពមិនច្បាស់លាស់ស្ថិតក្រោមច្បាប់ពីការប្រកួតប្រជែងទោះបីជាមានការណែនាំផ្នែកច្បាប់ក៏ដោយ។[53]

## 4. វិធីសាស្ត្រសម្រាប់នីតិវិធីបណ្តឹង

ដើម្បីអាចអនុវត្តនីតិវិធីបណ្តឹង តួអង្គផ្សេងៗត្រូវសហការនៅពេលដែលសហគ្រាសជាប់កាតព្វកិច្ចត្រូវការ ព័ត៌មានពីអ្នកផ្គត់ផ្គង់របស់ខ្លួនដើម្បីកំណត់ក្រុមគោលដៅនៃនីតិវិធី និងរៀបចំវាតាមរបៀបដែលពួកគេអាចចូលទៅប្រើប្រាស់បាន។ ក្រៅពីនេះ សហគ្រាសជាប់កាតព្វកិច្ចត្រូវការការគាំទ្រពីអ្នកផ្គត់ផ្គង់របស់ខ្លួនប្រសិនបើពួកគេចង់បញ្ជូនព័ត៌មានទៅកាន់ក្រុមគោលដៅអំពីលទ្ធភាពក្នុងការចូលទៅប្រើប្រាស់នីតិវិធី និងដំណើរការរបស់វា។ នៅក្នុងបរិបទនេះ មានបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងខ្សែចង្វាក់ផ្គត់ផ្គង់ដែលកាន់តែស៊ីជម្រៅ។ ជាថ្មីម្តងទៀត អ្នកផ្គត់ផ្គង់ អាចពឹងថានឹងទទួលបានការទាក់ទងពីអតិថិជនរបស់ខ្លួនអំពីសំណួរ និងការស្នើសុំជំនួយ។ ភាគីដែលពាក់ព័ន្ធក៏អាចគ្រប់គ្រងកិច្ចការនេះនៅក្នុងក្រុមប្រតិបត្តិអ្នកផ្គត់ផ្គង់ ឬការព្រមព្រៀងបែបកិច្ចសន្យាបន្ថែម។

ស្រដៀងគ្នាទៅនឹងការវិភាគហានិភ័យ នៅពេលទទួលបានការទាក់ទងដើម្បីស្នើសុំព័ត៌មាន អ្នកផ្គត់ផ្គង់គួរពិនិត្យដោយ ប្រុងប្រយ័ត្នថាតើព័ត៌មានអ្វីដែលដៃគូបែបកិច្ចសន្យារបស់ខ្លួនត្រូវការ និងថាតើអត្ថប្រយោជន៍ស្របច្បាប់អាចប៉ះពាល់នឹងការបង្ហាញព័ត៌មានរបស់ខ្លួន ឬទេ។ ស្ថានភាពនេះ ជារឿយៗពួកគេគួរគោរពគោលការណ៍សេដ្ឋកិច្ចទិន្នន័យក្នុងការធ្វើបែបនេះ ពួកគេក៏អាចប្រើប្រាស់កិច្ចព្រមព្រៀងរក្សាការសម្ងាត់ដែលជាធម្មតាគ្របដណ្តប់គោលបំណងនៃការប្រើប្រាស់ព័ត៌មាន។

ក្នុងអំឡុងពេលនៃ**ការផ្សព្វផ្សាយ និងការធ្វើឱ្យភាគីពាក់ព័ន្ធតាមបណ្តោយខ្សែចង្វាក់ផ្គត់ផ្គង់អាចចូលទៅប្រើប្រាស់នីតិវិធីបណ្តឹងបាន** សហគ្រាសជាប់កាតព្វកិច្ចពឹងផ្អែកទៅលើការចូលរួមពីអ្នកផ្គត់ផ្គង់របស់ខ្លួន។ គួរកត់សម្គាល់ថា ផលប្រយោជន៍

[53] ឧទាហរណ៍នៃសមាគមឧស្សាហកម្មដែលមានខ្លឹមសារស្រដៀងគ្នាទៅនឹងគោលបំណងនៃច្បាប់គឺរបាយការណ៍ករណីរបស់ការិយាល័យកាតែលសហព័ន្ធស្តីពី ក្រុមការងារនៃអាជីវកម្មលក់រាយអាល្លឺម៉ង់ គំនិតផ្តួចផ្តើមនិរន្តរភាពដើម្បីលើកកម្ពស់ប្រាក់ឈ្នួលការរស់នៅនៅក្នុងវិស័យដំណាំចេក (តម្លៃការរស់នៅ) នៃថ្ងៃទី08 មីនា ឆ្នាំ2022 អាចរកមើលអនឡាញបាននៅ (ភាសាអាល្លឺម៉ង់)៖ https://www.bundeskartellamt.de/SharedDocs/Entscheidung/DE/Fallberichte/Kartellverbot/2022/B2-90-21.pdf

ក្នុងការបង្ហាញព័ត៌មានទៅលើការដំណើរការ និងលទ្ធភាពក្នុងការចូលទៅប្រើប្រាស់នីតិវិធីបណ្ដឹងអាចនឹងត្រូវបានជំទាស់ដោយផលប្រយោជន៍សំខាន់ៗ របស់អ្នកផ្គត់ផ្គង់ដើម្បីជៀសវាងការទំនាក់ទំនងផ្ទាល់រវាងអ្នកផ្គត់ផ្គង់នៅខាងលើ និងសហគ្រាសជាប់កាតព្វកិច្ច។ នៅក្នុងករណីនេះ សហគ្រាស ជាប់កាតព្វកិច្ចគួរផ្ដល់ដំណោះស្រាយដូចជាការចូលរួមគ្នានៅក្នុងនីតិវិធីបណ្ដឹងខាងក្រៅ (ឧ. គំនិតផ្ដួចផ្ដើមភាគីពាក់ព័ន្ធចម្រុះ) ឬរួមគ្នាជាក់បញ្ចូលតួអង្គផ្សេងទៀតដែលសកម្មនៅក្នុងតំបន់ ឬវិស័យ (ឧ. សហជីព)។ ដោយសារតែបុគ្គលិក និងអ្នករស់នៅក្នុងសហគមន៍នៅជិតអ្នកផ្គត់ផ្គង់ ជាធម្មតាប្រើតែនីតិវិធីបណ្ដឹងរបស់សហគ្រាសជាប់កាតព្វកិច្ចតែប៉ុណ្ណោះប្រសិនបើគេដឹងថាសហគ្រាសនេះគឺជាសហគ្រាសនៅក្នុងចំណោមអ្នកទិញរបស់អ្នកផ្គត់ផ្គង់ សហគ្រាសជាប់កាតព្វកិច្ចគួរតម្រូវឱ្យអ្នកផ្គត់ផ្គង់របស់ខ្លួនធ្វើឱ្យព័ត៌មាននេះមានតម្លាភាពទៅកាន់ក្រុមមនុស្សទាំងនេះ។

ស្រដៀងគ្នានេះ អ្នកផ្គត់ផ្គង់អាចរំពឹងទុកថាអ្នកទិញជាប់កាតព្វកិច្ចរបស់ខ្លួនរំពឹងថានឹងមានវិធានការការពារ សម្រាប់អ្នករាយការណ៍ ព្រោះថា សហគ្រាសជាប់កាតព្វកិច្ចត្រូវរៀបចំនីតិវិធីផ្ទាល់ខ្លួនតាមរបៀបដែលអាចការពារការសម្ងាត់ក្នុងការកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់សក្ដានុពល និងការពារប្រកបដោយប្រសិទ្ធភាពប្រឆាំងទៅនឹងផលលំបាក និងការពិន័យក្នុងការប្រើប្រាស់នីតិវិធី។[54] ដោយសារតែផលវិបាក ឬការដាក់ពិន័យ នីតិវិធីបណ្ដឹងជារឿយៗ អាចមកពីអ្នកផ្គត់ផ្គង់ ឬពីតួអង្គនៅក្នុងបរិស្ថានរបស់ខ្លួន ដូចជា ប្រធានផ្នែក កងកម្លាំងសន្តិសុខ អ្នកផ្ដល់សេវា ឬអ្នកទិញផ្សេងទៀត អ្នកផ្គត់ផ្គង់អាចរំពឹងថាសហគ្រាសជាប់កាតព្វកិច្ចនឹងតម្រូវឱ្យពួកគេការពារបុគ្គលិក និងអ្នករស់នៅក្នុងសហគមន៍នៅជិតអ្នកផ្គត់ផ្គង់។

ប្រសិនបើអ្នកផ្គត់ផ្គង់បានទទួលបណ្ដឹងតាងនាមឱ្យអ្នកទិញដើម្បីបញ្ជូនបណ្ដឹងទាំងនោះ ការការពារការសម្ងាត់នៃអត្តសញ្ញាណរបស់អ្នករាយការណ៍ដើរតួនាទីសំខាន់។ នៅក្នុងករណីនេះ អ្នកផ្គត់ផ្គង់ត្រូវគិតថាសហគ្រាសជាប់កាតព្វកិច្ចនឹងទាមទារឱ្យមានវិធានការការពារពិសេស។

វិធានការគាំទ្រអាចនាំឱ្យមានថ្លៃចំណាយសម្រាប់អ្នកផ្គត់ផ្គង់។ មិនដូចថ្លៃចំណាយសម្រាប់វិធានការតម្រូវ ដែលអាចជាការតម្រូវ និងបង្ហាញអំពីហេតុផលនៃការចូលរួមរបស់សហគ្រាសមួយចំនួន រួមទាំងអ្នកផ្គត់ផ្គង់នៅពេលដែលត្រូវអនុវត្តសកម្មភាព ថ្លៃចំណាយនៅទីនេះពាក់ព័ន្ធនឹងកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវដែលជាការទទួលខុសត្រូវទាំងស្រុងរបស់សហគ្រាសជាប់កាតព្វកិច្ច។ ដូច្នេះហើយ សហគ្រាសជាប់កាតព្វកិច្ចត្រូវទទួលបន្ទុកលើថ្លៃចំណាយ។ ថ្លៃចំណាយទាំងនេះរួមមាន ថ្លៃសម្រាប់ការផ្ដល់ព័ត៌មាន និងវិធានការការពារ។ កិច្ចការនេះនឹងត្រូវវាយតម្លៃខុសៗគ្នានៅក្នុងករណីនីតិវិធី សារទុក្ខខាងក្រៅ (ជាមួយគ្នានឹងសហគ្រាសនានា ឬនៅក្នុងក្របខណ្ឌនៃគំនិតផ្ដួចផ្ដើមក្នុងវិស័យ និងឆ្លងវិស័យ)។ នៅក្នុងករណីនេះសហគ្រាសដែលចូលរួមត្រូវកំណត់ថ្លៃចំណាយ និងបែងចែងវាឱ្យបានសមស្រប។ អ្នកផ្គត់ផ្គង់ក៏អាចចូលរួមផងដែរនៅក្នុងនីតិវិធីបណ្ដឹងខាងក្រៅរួមគ្នាជា មួយសហគ្រាសជាប់កាតព្វកិច្ច។

ជាថ្មីម្ដងទៀត ដូចបានរៀបរាប់ខាងលើនៅក្នុងវិធីសាស្ត្រនៃសកម្មភាពកែប្រែលក្ខណៈវិនិច្ឆ័យភាពសមស្រប ផ្ដល់នូវជំនួយបន្ថែម។

## V. គន្លឹះសម្រាប់អ្នកផ្គត់ផ្គង់ដើម្បីអនុវត្តនីតិវិធីត្រួតពិនិត្យភាពត្រឹមត្រូវ

លក្ខខណ្ឌតម្រូវនៃត្រួតពិនិត្យភាពត្រឹមត្រូវដែលបានបញ្ជាក់នៅក្នុងច្បាប់ គឺចាំបាច់សម្រាប់តែសហគ្រាស ដែលស្ថិតក្នុងវិសាលភាពនៃការអនុវត្តតែប៉ុណ្ណោះ។ មិនមានលក្ខខណ្ឌតម្រូវផ្នែកច្បាប់សម្រាប់អ្នកផ្គត់ផ្គង់ ដែលនៅក្រៅវិសាលភាពឱ្យបង្ហាញពីកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវរបស់ខ្លួនឡើយ។ យ៉ាងណាមិញ សហគ្រាសគ្រប់ទំហំ និងគ្រប់វិស័យ អាចមាន

[54] ផ្នែក 8 ទ 4 ប្រយោគទី 2 នៃច្បាប់នេះ

ផលប៉ះពាល់វិជ្ជមានទៅលើការគោរពសិទ្ធិមនុស្ស និងបរិស្ថាន ដោយមិនគិតពីកាតព្វកិច្ចនៃច្បាប់ត្រួតពិនិត្យភាពត្រឹមត្រូវនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ទេ។ លក្ខខណ្ឌនេះ ស្របទៅនឹងគោលការណ៍ណែនាំ OEDC សម្រាប់សហគ្រាសចម្រុះជាតិសាសន៍ គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស និងការពឹងទុករបស់រដ្ឋាភិបាលសហព័ន្ធដែលបានដាក់ចេញនៅក្នុង NAP។ រដ្ឋាភិបាលសហព័ន្ធបានបង្កើតផ្នែកជំនួយអំពីធុរកិច្ចនិងសិទ្ធិមនុស្សដើម្បីគាំទ្រដល់សហគ្រាសនានា។

ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គមដ៏រឹងមាំក៏ផ្តល់នូវផលប្រយោជន៍សម្រាប់សហគ្រាសផងដែរៈ វាជួយពួកគេក្នុងការកំណត់អត្តសញ្ញាណ និងដោះស្រាយហានិភ័យ និងការបំពានឱ្យបានទាន់ពេល។ ប្រព័ន្ធគ្រប់គ្រងបែបនេះ អាចនឹងនាំឱ្យមានគុណសម្បត្តិប្រកួតប្រជែងផងដែរ ជាពិសេស ទាក់ទងនឹងការចាប់ផ្តើមទំនាក់ទំនងអាជីវកម្ម និងអតិថិជន ជាមួយសហគ្រាសជាប់កាតព្វកិច្ច ប៉ុន្តែក៏ទាក់ទាញអ្នកវិនិយោគផងដែរ។ ការយល់ពីលក្ខខណ្ឌតម្រូវនៃប្រព័ន្ធគ្រប់គ្រងហានិភ័យការត្រួតពិនិត្យភាពត្រឹមត្រូវអាចសម្រួលដល់ការចចារជាមួយអតិថិជនសម្រាប់សហគ្រាសមិនជាប់កាតព្វកិច្ច។

វាក៏សមហេតុផលផងដែរសម្រាប់សហគ្រាសមិនជាប់កាតព្វកិច្ចក្នុងការយល់ពីលក្ខខណ្ឌតម្រូវនៃច្បាប់នេះ និងធ្វើការពិចារណាថាតើពួកគេអាចបង្កើតយុទ្ធសាស្ត្រសមស្របសម្រាប់ដោះស្រាយការស្នើសុំពីសហគ្រាសជាប់កាតព្វកិច្ចបានដោយរបៀបណា។ ប្រព័ន្ធគ្រប់គ្រងហានិភ័យដ៏រឹងមាំអនុញ្ញាតិឱ្យពួកគេសហការជាមួយ សហគ្រាសជាប់កាតព្វកិច្ចដោយឈរលើគោលការណ៍ស្មើភាពគ្នា។

នៅក្នុងការអនុវត្តជាក់ស្តែង សហគ្រាសមិនជាប់កាតព្វកិច្ចមួយចំនួនមិនអាចបង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យបែបនេះដោយប្រើប្រាស់ធនធានផ្ទាល់ខ្លួនបានទេ។ នៅក្នុងករណីទាំងនេះ វាអាចមានប្រយោជន៍ប្រសិនបើ សហគ្រាសជាប់កាតព្វកិច្ចជួយដល់អ្នកផ្គត់ផ្គង់របស់ខ្លួន។ ជាពិសេសសម្រាប់អ្នកផ្គត់ផ្គង់មិនជាប់កាតព្វកិច្ច និងជាពិសេសសម្រាប់ប្រទេសឬវិស័យដែលមានហានិភ័យខ្ពស់វាអាចមានប្រយោជន៍ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការដើម្បីបង្កើតរចនាសម្ព័ន្ធផ្ទាល់ខ្លួនរបស់ខ្លួនខណៈពេលកំពុងដោះស្រាយការទទួលខុសត្រូវរបស់សហគ្រាសជាប់កាតព្វកិច្ចដើម្បីកែលម្អស្ថានភាពនៅនឹងកន្លែង។

អ្នកផ្គត់ផ្គង់មិនជាប់កាតព្វកិច្ចដែលមិនអាចអនុវត្តប្រព័ន្ធគ្រប់គ្រងបែបនេះបាន គួរវាយតម្លៃថាតើពួកគេអាច យ៉ាងហោចណាស់អនុវត្តជាគុមួយចំនួននៃប្រព័ន្ធនេះបានដែរឬទេ។ ជាញឹកញាប់ ពួកគេអាចត្រៀមខ្លួនសម្រាប់ការទាមទារពីសហគ្រាសជាប់កាតព្វកិច្ចជាមួយនឹងជំហានមួយចំនួន។ ឧទាហរណ៍ វាអាចមានប្រយោជន៍ក្នុងការធ្វើការវិភាគហានិភ័យយ៉ាងហោចណាស់សម្រាប់ផ្នែកមួយចំនួននៃខ្សែចង្វាក់ផ្គត់ផ្គង់ដើម្បីត្រៀមខ្លួនឱ្យរួចរាល់សម្រាប់ការស្នើសុំពីអ្នកទិញជាប់កាតព្វកិច្ច ឬដើម្បីអនុវត្តវិធានការទប់ស្កាត់នៅក្នុងករណីនៃការកំណត់អត្តសញ្ញាណហានិភ័យ។

អ្នកផ្គត់ផ្គង់មិនជាប់កាតព្វកិច្ច ជាបឋមអាចផ្តោតលើផ្នែកដែលមានហានិភ័យខ្ពស់នៃខ្សែចង្វាក់ផ្គត់ផ្គង់ ហើយពង្រឹងកិច្ចខិតខំរបស់គេនៅត្រង់នោះ។ ទាំងការវិភាគហានិភ័យផ្ទាល់ខ្លួននៃផលប៉ះពាល់អវិជ្ជមានទៅលើសិទ្ធិមនុស្ស និងបរិស្ថាន និងឥទ្ធិពលពីខាងក្រៅ (ឧ. ការទាមទារពីអ្នកទិញជាប់កាតព្វកិច្ច) អាចត្រូវបានកំណត់ជាអាទិភាព។ ឈរលើ មូលដ្ឋាននេះ សហគ្រាសទាំងពីរអាចអនុវត្តវិធានការទប់ស្កាត់ និងកែប្រែរួមគ្នាទៅលើអ្នកផ្គត់ផ្គង់ (ឧ. សវនកម្ម ការបណ្តុះបណ្តាលអ្នកផ្គត់ផ្គង់) និងបែងចែកថ្លៃចំណាយដោយយោងតាមលក្ខណៈវិនិច្ឆ័យភាពសមស្រប។ ប្រសិនបើសហគ្រាសមិនជាប់កាតព្វកិច្ចមិនអាចបង្ហាញអំពីអ្នកផ្គត់ផ្គង់បន្ត ពួកគេអាចបញ្ជូនបន្តធនធានហិរញ្ញវត្ថុ សម្រាប់ការអនុវត្តវិធានការនៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ខាងលើ។ ទោះបីយ៉ាងណា សហគ្រាសជាប់កាតព្វកិច្ច នៅក្នុងករណីនេះត្រូវការព័ត៌មានត្រឹមត្រូវអំពីការប្រើប្រាស់ថវិកាឱ្យបានសមស្របសម្រាប់គោលបំណងដែលបានគ្រោងទុក។ ឧទាហរណ៍ វាអាចយល់បានក្នុងការផ្តល់ របាយការណ៍សវនកម្ម ឬរបាយការណ៍ប្រាក់ខែដែលព័ត៌មានរសើបត្រូវបានបិទបាំង។

RESPONSIBLE BUSINESS HUB CAMBODIA
RBH NETWORK

ការកំណត់ការទទួលខុសត្រូវ និងដំណើរការ ក៏ដូចជាការប្រើប្រាស់ធនធានហិរញ្ញវត្ថុ ពេលខ្លះអាចខុសប្លែកគ្នា គួរឱ្យកត់សម្គាល់នៅក្នុងការអនុវត្តកាតព្វកិច្ចត្រួតពិនិត្យភាពត្រឹមត្រូវផ្ទាល់ខ្លួន។ ស្របពេលដែលនៅក្នុងសហគ្រាសធំៗ ប្រធានបទនៃការត្រួតពិនិត្យភាពត្រឹមត្រូវ អាចត្រូវបានដាក់នៅទីតាំងមួយដែលត្រូវបានបង្កើតជាពិសេសនៃមន្ត្រីសិទ្ធិមនុស្ស និងគណកម្មាធិការឆ្លងនាយកដ្ឋាន (ឧ. គណកម្មាធិការសិទ្ធិមនុស្ស) អមជាមួយការអនុវត្ត បច្ចេកទេសនៅក្នុងដំណើរការស្នូលនៃសហគ្រាស មិនជាប់កាតព្វកិច្ចអាចដាក់កំណត់ខ្លួនឯងទៅរករចនាសម្ព័ន្ធដែលបង្កើតគុណតម្លៃអតិថិជនកាន់តែច្រើន (Leaner structure) ឧទាហរណ៍ តាមរយៈការបញ្ចូលគ្នានៃការទទួលខុសត្រូវលើគុណភាព និរន្តរភាព និងការទិញទៅឱ្យមនុស្សតែម្នាក់។

យ៉ាងណាមិញ វាក៏អាចមានសារសំខាន់ផងដែរសម្រាប់សហគ្រាសតូចៗក្នុងការកំណត់បណ្តុំអប្បបរមានៃ ដំណើរការដើម្បីឱ្យប្រព័ន្ធអាចផ្ទៀតផ្ទាត់បាន និងដំណើរការបានដោយឯករាជ្យពីមនុស្ស (ឧ. ប្រសិនបុគ្គលដែលទទួលខុសត្រូវចាកចេញពីក្រុមហ៊ុន)។

នៅក្នុងបរិបទនេះ សហគ្រាសនានាអាចអនុវត្តតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស NAP និង គោលការណ៍ OECD ដែលពាក់ព័ន្ធ សម្រាប់ការនាំផ្លូវ។

# ឧបសម្ព័ន្ធ៖ ទិដ្ឋភាពរួមជាមួយនឹងឯកសារយោងសម្រាប់សេវាជំនួយដែលមានស្រាប់

*ព័ត៌មានស្តីពីការត្រួតពិនិត្យភាពត្រឹមត្រូវលើខ្សែចង្វាក់ផ្គត់ផ្គង់៖*

- សំណួរនិងចម្លើយពីការត្រួតពិនិត្យភាពត្រឹមត្រូវលើខ្សែចង្វាក់ផ្គត់ផ្គង់ (FAQs) (ជាភាសាអាឡឺម៉ង់)៖ https://www.bafa.de/DE/Lieferketten/FAQ/haeufig_gestellte_fragen_node.html
- ការណែនាំបន្ថែម BAFA ពីការត្រួតពិនិត្យភាពត្រឹមត្រូវលើខ្សែចង្វាក់ផ្គត់ផ្គង់៖
  - ការណែនាំស្តីពីការវិភាគហានិភ័យ "ការកំណត់អត្តសញ្ញាណ ការវាស់ទំហំនិងការធ្វើចំណាត់អាទិភាពគ្រោះថ្នាក់"៖ https://www.bafa.de/SharedDocs/Downloads/EN/Supply_Chain_Act/guidance_risk_analysis
  - ការណែនាំស្តីពីនីតិវិធីបណ្តឹង "ការរៀបចំ ការអនុវត្ត និងការវាយតម្លៃនីតិវិធីនៃបណ្តឹង" https://www.bafa.de/SharedDocs/Downloads/EN/Supply_Chain_Act/guidance_complaints_p
  - ការណែនាំស្តីពីគោលការណ៍នៃភាពសមរម្យតាមតម្រូវការនៃការត្រួតពិនិត្យភាពត្រឹមត្រូវលើខ្សែចង្វាក់ផ្គត់ផ្គង់ https://www.bafa.de/SharedDocs/Downloads/EN/Supply_Chain_Act/guidance_appropriatene
- តារាងព័ត៌មានពីកម្រងសំណួរ (ជាភាសាអាឡឺម៉ង់)៖ https://www.bafa.de/SharedDocs/Downloads/DE/Lieferketten/lksg_berichtspflicht_fragebogen.h
- ការត្រួតពិនិត្យភាពត្រឹមត្រូវលើខ្សែចង្វាក់ផ្គត់ផ្គង់- អត្ថបទនីតិប្បញ្ញត្តិ៖ https://www.bmas.de/SharedDocs/Downloads/DE/Internationales/act-corporate-due-diligence-obligations-supply-chains.pdf?__blob=publicationFile&v=4
- សេចក្តីព្រាងច្បាប់របស់រដ្ឋាភិបាលសហព័ន្ធ (រួមទាំងអនុស្សរណៈពន្យល់) Deutscher BundestagDrucksache 19/28649 (ជាភាសាអាឡឺម៉ង់)៖ https://www.bafa.de/SharedDocs/Downloads/DE/Lieferketten/gesetzesentwurf.pdf

*សេវាគាំទ្រ និងប្រឹក្សាសម្រាប់ការអនុវត្ត៖*

- Helpdesk របស់អាឡឺម៉ង់ពីអាជីវកម្មនិងសិទ្ធិមនុស្ស៖ ទំនាក់ទំនងសំខាន់សម្រាប់អនុវត្តការត្រួតពិនិត្យភាពត្រឹមត្រូវលើខ្សែចង្វាក់ផ្គត់ផ្គង់ ដំបូន្មានឥតគិតថ្លៃ និងមានភាពសម្ងាត់ដល់ក្រុមហ៊ុន និងសមាគមអាជីវកម្មលើការអនុវត្តជាក់ស្តែងនៃដំណើរការត្រួតពិនិត្យភាពត្រឹមត្រូវ ការផ្តល់មូលនិធិ និងហិរញ្ញប្បទាន ការបណ្តុះបណ្តាលផ្ទាល់ខ្លួន ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកដោយឥតគិតថ្លៃ ព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹង និងឧបករណ៍អនឡាញជាច្រើនដោយឥតគិតថ្លៃ៖ http://www.helpdeskwimr.com/

  បណ្តាញបង្រួមសកលរបស់អង្គការសហប្រជាជាតិអាឡឺម៉ង់៖ បោះពុម្ពផ្សាយ (ឧទាហរណ៍ "តើការត្រួតពិនិត្យភាពត្រឹមត្រូវទៅលើសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាពមើលទៅដូចសម្រាប់សហគ្រាសធុនតូច និងមធ្យម? 5 យោបល់យល់ដឹងពីការអនុវត្ត ": UNGCD_Insights_Series_human_rights_due_diligence_SME.pdf

(globalcompact.de), សិក្ខាសាលា និង webinars: https://www.globalcompact.de/en

- ការផ្តួចផ្តើមពីភាពសាមគ្គីជាសកល៖ : https://www.giz.de/en/downloads/giz2023-en-igs-factsheet.pdf
- ជនបង្គោលនៃអាជីវកម្មសម្រាប់ការអភិវឌ្ឍ៖ ការណែនាំអំពីការចូលរួមប្រកបដោយនិរន្តរភាពរបស់ក្រុមហ៊ុននៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ លើការផ្តល់ហិរញ្ញប្បទាន ហិរញ្ញប្បទាន និងកិច្ចសហប្រតិបត្តិការ និងលើការភ្ជាប់ក្រុមហ៊ុនជាមួយដៃគូអាជីវកម្មដែលមានសក្តានុពល (ជាភាសាអាឡឺម៉ង់)៖ https://www.bmz.de/de/themen/privatwirtschaft/kammern-und-verbaende/business-scouts-for-development-70214

*ឧបករណ៍និងធនធាន៖*

- អាជីវកម្ម និងការរុករកព័ត៌មានពីសិទ្ធិមនុស្ស៖http://www.bhr-navigator.unglobalcompact.org/
- ត្រីវិស័យសម្រាប់សហគ្រាសធុនតូច និងមធ្យម, ត្រីវិស័យសម្រាប់ការត្រួតពិនិត្យភាពត្រឹមត្រូវ": http://www.kompass.wirtschaft-entwicklung.de/en/due-diligence-compass/develop-a-strategy
- ត្រីវិស័យសម្រាប់សហគ្រាសធុនតូច និងមធ្យម ត្រីវិស័យស្តង់ដារ"៖ http://www.kompass.wirtschaft-entwicklung.de/en/standards-compass/what-can-standards-achieve
- ទំនួលខុសត្រូវសាជីវកម្មសង្គមក្នុងការពិនិត្យមើលហានិភ័យ៖ កំណត់អត្តសញ្ញាណសហគ្រាស ផលិតផល និងហានិភ័យជាក់លាក់របស់ក្រុមហ៊ុន៖ www.mvorisicochecker.nl/en/start-check
- អាជីវកម្មនិងមជ្ឈមណ្ឌលធនធានសិទ្ធិមនុស្ស (BHRRC)៖ សមត្ថភាពក្នុងការស្រង់

  របាយការណ៍តាមប្រទេស វិស័យ និងប្រធានបទ៖ http://www.business-humanrights.org/

*ជំនួយការក្នុងការកំណត់អត្តសញ្ញាណប្រទេសដែលប្រឈមហានិភ័យខ្ពស់៖*

- អង្គការពលកម្មអន្តរជាតិ (ILO)
  - សូចនាករ SDG 8.8.2 (សិទ្ធិរបស់កម្មករ)៖ https://www.ilo.org/shinyapps/bulkexplorer33/?lang=en&id=SDG_0882_NOC_RT_A
  - សូចនាករ SDG 8.7.1 (ពលកម្មកុមារ)៖ https://ilostat.ilo.org/topics/child-labour/#
  - សូចនាករ SDG 8.8.1 (ការរងរបួសនៅកន្លែងការងារ) https://ilostat.ilo.org/topics/safety-and-health-at-work/
  - ទិន្នន័យពីប្រាក់ការងារទូទាំងពិភពលោក៖ https://ilostat.ilo.org/topics/wages/
- អង្គការតម្លាភាពអន្តរជាតិ សន្ទស្សន៍នៃការយល់ឃើញអំពីអំពើពុករលួយ៖ https://www.transparency.org/en/cpi/
- Yale មជ្ឈមណ្ឌលសម្រាប់ច្បាប់ និងគោលនយោបាយបរិស្ថាន សន្ទស្សន៍ការអនុវត្តបរិស្ថាន៖ http://www.epi.yale.edu/
- ITUC CSI IGB, ITUC សន្ទស្សន៍សិទ្ធិសកល៖ https://www.globalrightsindex.org/

- Walk Free, សន្ទស្សន៍ទាសភាពសកល: http://www.globalslaveryindex.org/
- កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ សន្ទស្សន៍ការអភិវឌ្ឍមនុស្ស៖https://hdr.undp.org/data-center/human-development-index#/indicies/HDI
- ធនាគារពិភពលោក សូចនាករអភិបាលកិច្ចពិភពលោក៖ https://info.worldbank.org/governance/wgi/Home/Documents
  - សំឡេង និងគណនេយ្យភាព
  - ស្ថិរភាពនយោបាយ និងភាពគ្មានអំពើហិង្សា/ភេរវកម្ម
  - ប្រសិទ្ធិភាពរបស់រដ្ឋាភិបាល
  - គុណភាពនៃបទបញ្ញត្តិ
  - នីតិរដ្ឋ
  - ការគ្រប់គ្រងអំពើពុករលួយ
- មូលនិធិបេតិកភណ្ឌ សន្ទស្សន៍សេរីភាពសេដ្ឋកិច្ច៖ https://www.heritage.org/index/
- Freedom House ពិន្ទុសេរីភាពពិភពលោក៖ https://freedomhouse.org/countries/freedom-world/scores
- វេទិកាសេដ្ឋកិច្ចពិភពលោក របាយការណ៍សកលពីគម្លាតយេនឌ័រ៖ https://www.weforum.org/reports/global-gender-gap-report-2022/
- Bertelsmann Stiftung សន្ទស្សន៍ការផ្លាស់ប្តូរ (ជាភាសាអាឡឺម៉ង់)៖ https://bti-project.org/de/

*ការផ្តួចផ្តើមរបស់សហគ្រាស៖*

- កិច្ចសន្ទនាតាមវិស័យឧស្សាហកម្មយានយន្ត៖ https://www.csr-in-deutschland.de/EN/Business-Human-Rights/Implementation-support/Sector-dialogues/Automotive-Industry/automotive-Industry.html
- Chemie3-ការផ្តួចផ្តើមពីនិរន្តរភាពនៃឧស្សាហកម្មគីមីអាឡឺម៉ង់ (ជាភាសាអាឡឺម៉ង់)៖ https://www.chemiehoch3.de/
- កិច្ចសន្ទនាតាមវិស័យឧស្សាហកម្មថាមពលអាឡឺម៉ង់ (ជាភាសាអាឡឺម៉ង់)៖ https://www.csr-indeutschland.de/DE/Wirtschaft-Menschenrechte/Umsetzungshilfen/Branchendialoge/Energiewirtschaft/energiewirtschaft.html
- ការផ្តួចផ្តើមរបស់អាឡឺម៉ង់ស្តីពីផ្លែកាកាវប្រកបដោយនិរន្តរភាព៖https://www.kakaoforum.de/en/
- វេទិកានៃប្រេងដូងប្រកបដោយនិរន្តរភាព៖ https://www.forumpalmoel.org/en/welcome
- ភាពជាដៃគូសម្រាប់វិស័យវាយនភ័ណ្ឌប្រកបដោយនិរន្តរភាព៖ https://www.textilbuendnis.com/en/

*ការផ្តួចផ្តើមក្នុងវិស័យឧស្សាហកម្មឆ្លងវិស័យ៖*

- ពាណិជ្ជកម្ម៖ ការផ្តួចផ្តើមពាណិជ្ជកម្មដែលមិនរំលោភនិតិវិធីនៃក្រមសីលធម៌៖

https://www.ethicaltrade.org/sites/default/files/shared_resources/Alleged%20code%20violation%

- សិទ្ធិរបស់កម្មករ៖ ដំណើរការបណ្តឹងរបស់ភាគីទីបីនៃសមាគមការងារយុត្តិធម៌៖ https://www.fairlabor.org/accountability/fair-labor-investigations/tpc/
- ពាណិជ្ជកម្ម៖ អេមហ្វូរីកម្មវិធីការនិយាយដើម្បីការផ្លាស់ប្តូរ៖ https://amfori-.foleon.com/speak-for-change/scgm/
- ប្រេងដូង៖ កម្មវិធីតុមូលស្តីពីការប្តឹងតវ៉ានិងនីតិវិធីបណ្តឹងឧទ្ធរណ៍អំពីនិរន្តរភាពប្រេងដូង៖ https://rspo.org/who-we-are/complaints/
- ធនធានរ៉ែ៖យន្តការដោះស្រាយបណ្តឹងអំពីការផ្តួចផ្តើមរ៉ែប្រកបដោយការទទួលខុសត្រូវ៖ https://www.responsiblemineralsinitiative.org/rmap/grievance-mechanism/

*ឯកសារយោងអន្តរជាតិ៖*

- អង្គការពលកម្មអន្តរជាតិស្តីពី សិទ្ធិជាមូលដ្ឋាន និងគោលការណ៍នៅកន្លែងការងារ៖ https://www.ilo.org/declaration/lang--en/index.htm
- គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីអាជីវកម្ម និងសិទ្ធិមនុស្ស (2011)៖ https://www.ohchr.org/sites/default/files/Documents/Publications/GuidingPrinciplesBusinessHR_EN.pdf
- ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស៖ ការទទួលខុសត្រូវរបស់សាជីវកម្មក្នុងការគោរពសិទ្ធិមនុស្ស។ ការណែនាំបែបបកស្រាយ (នៅលើ UNGP)៖ https://www.ohchr.org/sites/default/files/Documents/Issues/Business/RtRInterpretativeGuide.pdf
- ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស៖ សំណួរដែលសួរញឹកញាប់ (FAQ) អំពីគោលការណ៍ណែនាំស្តីពីអាជីវកម្ម និងសិទ្ធិមនុស្ស (2014)៖ https://www.ohchr.org/sites/default/files/Documents/Publications/FAQ_PrinciplesBussinessHR.pdf
- អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ៖ OECD-គោលការណ៍ណែនាំសម្រាប់សហគ្រាសពហុជាតិស្តីពីការប្រតិបត្តិអាជីវកម្មដែលមានទំនួលខុសត្រូវ (2023)៖ https://read.oecd-ilibrary.org/finance-and-investment/oecd-guidelines-for-multinational-enterprises-on-responsible-business-conduct_81f92357-en
- អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ៖ OECD គោលការណ៍ណែនាំសម្រាប់សហគ្រាសពហុជាតិ (2011)៖ https://www.oecd-ilibrary.org/governance/oecd-guidelines-for-multinational-enterprises_9789264115415-en
- សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ៖ ស្តង់ដារការអនុវត្តលើនិរន្តរភាពរបស់បរិស្ថាន និងសង្គម(2011)៖ https://www.ifc.org/en/insights-reports/2012/publications-handbook-pps
- សេចក្តីប្រកាសត្រីភាគីអំពីគោលការណ៍ទាក់ទងនឹងសហគ្រាសពហុជាតិ និងគោលនយោបាយសង្គម (សេចក្តីថ្លែងការណ៍MNE) (2022)៖ https://www.ilo.org/empent/Publications/WCMS_094386/lang--en/index.htm

*ការណែនាំរបស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ៖*

- អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍពីសេចក្តីណែការត្រួតពិនិត្យភាពត្រឹមត្រូវទៅលើទំនួលខុសត្រូវសម្រាប់ការអនុវត្តអាជីវកម្ម (2018)៖ http://mneguidelines.oecd.org/OECD-Due-Diligence-Guidance-for-Responsible-Business-Conduct.pdf
- អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍពីសេចក្តីណែនាំការត្រួតពិនិត្យភាពត្រឹមត្រូវទៅលើទំនួលខុសត្រូវក្នុងខ្សែចង្វាក់ផ្គត់ផ្គង់រ៉ែពីតំបន់ដែលមានវិវាទនិងគ្រោះថ្នាក់ខ្ពស់ (2019)៖ https://www.oecd.org/daf/inv/mne/OECD-Due-Diligence-Guidance-Minerals-Edition3.pdf
- អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ-សំណួរដែលសួរញឹកញាប់សេចក្តីណែនាំពីទំនួលខុសត្រូវក្នុងខ្សែចង្វាក់ផ្គត់ផ្គង់កសិកម្ម (2016)៖ https://www.oecd.org/publications/oecd-fao-guidance-for-responsible-agricultural-supply-chains-9789264251052-en.htm
- អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍពីសេចក្តីណែនាំការត្រួតពិនិត្យភាពត្រឹមត្រូវទៅលើការចូលរួម ដ៏មានអត្ថន័យរបស់ភាគីពាក់ព័ន្ធក្នុងវិស័យទាញយកវត្ថុធាតុដើម (2017)៖ https://www.oecd.org/publications/oecd-due-diligence-guidance-for-meaningful-stakeholder-engagement-in-the-extractive-sector-9789264252462-en.htm

- អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍពីសេចក្តីណែនាំការត្រួតពិនិត្យភាពត្រឹមត្រូវទៅលើទំនួលខុសត្រូវរបស់ខ្សែចង្វាក់ផ្គត់ផ្គង់នៅក្នុងវិស័យសម្លៀកបំពាក់ និងស្បែកជើង (2020)៖ https://www.oecd.org/publications/oecd-due-diligence-guidance-for-responsible-supply-chains-in-the-garment-and-footwear-sector-9789264290587-en.htm
- ទំនួលខុសត្រូវនៃការអនុវត្តអាជីវកម្មសម្រាប់អ្នកវិនិយោគស្ថាប័ន (2018)៖ https://mneguidelines.oecd.org/RBC-for-Institutional-Investors.pdf
- ការត្រួតពិនិត្យភាពត្រឹមត្រូវទៅលើទំនួលខុសត្រូវក្នុងការផ្តល់កម្ចីសាជីវកម្មនិងធានាលើមូលបត្រ (2020)៖ https://mneguidelines.oecd.org/due-diligence-for-responsible-corporate-lending-and-securities-underwriting.pdf

Deutsche Gesellschaft für Internationale Zusammenarbeit ( GIZ ) GmbH

ការិយាល័យ GIZ ប្រចាំកម្ពុជា

អគារការិយាល័យ Oval Office ជាន់ទី 10 អគារលេខ 1 ផ្លូវ 360 សង្កាត់បឹងកេងកង 1
ប្រអប់ P.O. លេខ 81 លេខកូដតំបន់ 120102 រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ៖ +855 23 860 110
អ៊ីមែល៖ giz-kambodscha@giz.de
គេហទំព័រ៖ www.giz.de/cambodia